ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩**

**សវនាការលើកទី៧៥**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CATWRIGHT)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

កញ្ញា ណាតាសា វីស៊ែល រីសឺ

*(Ms. Natacha WEXELS-RISER)*

លោក ម៉ាតេអូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត *(Mr.William SMITH)*

**ជនជាប់ចោទ៖**

លោក កាំង ហ្កេកអ៊ាវ

លោក ហុង គឹមសួន

**មេធាវីការពារជនជាប់ចោទ៖**

លោក ការីម ខាន *(Mr. Karim KHAN)*

លោក ការ សាវុត្ថ

លោកស្រី ស៊ីលឃិ ស្ទូតហ្សីនស្គី *(Ms. Silke STUDZINSKY)*

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ម៉ាទីន ហ្សាកកាំង *(Ms. Martine JACQUIN)*

លោកស្រី ហេឡឺន អ៊ុយណាក់ *(Ms. Heleyn UÑAC)*

លោក ហ្វីលីព កាណុន *(Mr. Philippe CANNONE)*

លោក ចាន់រ៉ាវុធ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ីនណា

លោក គង់ ពិសី

កញ្ញា  ម៉ុច សុវណ្ណារី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ការ សាវុត្ថ | ខ្មែរ |
| លោកស្រី ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។

អញ្ជើញក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី ដែលត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ នៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់ឈើរាងក្រចកសេះ ដែលត្រៀមរៀបចំទុកសម្រាប់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះនៅទីនោះ។

ជាកិច្ចបន្ត សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិឡើងបន្តធ្វើសេចក្តីថ្លែងការណ៍ស្តីពីសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ សូមអញ្ជើញ។

**លោក វីលៀម ស្មីត៖**

សូមគោរពលោកប្រធាន អស់លោក លោកស្រីចៅក្រម, ម្សិលមិញយើងបានបញ្ចប់សារណារបស់យើងទាក់ទងទៅនឹងភស្តុតាងទាក់ទងទៅនឹងឧក្រិដ្ឋកម្មនិងយុត្តាធិការ។ គឺឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាក់ទងទៅនឹងភស្តុតាង ទាក់ទងទៅនឹងការចូលរួមរបស់ជនជាប់ចោទនៅក្នុងការប្រព្រឹត្តឧក្រិដ្ឋ-កម្មទាំងនេះ។ ដើម្បីបញ្ចប់សារណាយើងខ្ញុំនៅថ្ងៃនេះ យើងខ្ញុំសូមលើកឡើងនូវចំណុចពីរ។

ទីមួយ ថាតើជនជាប់ចោទចូលរួមនៅក្នុងការប្រព្រឹត្តកម្មទាំងអស់នេះ អាចមានលក្ខណៈស្របតាមផ្លូវច្បាប់ដោយរបៀបណា? ទាក់ទងទៅនឹងការទទួលខុសត្រូវផ្ទាល់របស់ជនជាប់ចោទ ស្របតាមមាត្រា២៩នៃច្បាប់បង្កើត អ.វ.ត.ក។

និងទីពីរ យើងខ្ញុំក៏ចង់លើកឡើង ថាតើកត្តាណាដែលអង្គជំនុំជម្រះនឹងយកមកពិចារណាទាក់ទងទៅនឹងការផ្តន្ទាទោសុំ

លោក លោកស្រីចៅក្រម, ដោយសារតែការសម្រាកមិនមានបានរៀបចំស្រួលបួលកាលពីម្សិលមិញ ខ្ញុំជឿថា យើងនៅមានពេលមួយម៉ោង និងម្ភៃប្រាំនាទី ហើយខ្ញុំនឹងបញ្ចប់ទៅតាមពេលវេលាដែលបានចែកជូននេះ។

[០៩:០៥:០៧]

ជាសង្ខេប មុននឹងខ្ញុំចាប់ផ្តើម ខ្ញុំចង់ធ្វើការកែប្រែទៅលើសារណារបស់យើងខ្ញុំកាលពីម្សិលមិញពីរចំណុច។ ទីមួយទាក់ទងទៅនឹងភស្តុតាងនៃការប្រព្រឹត្តផ្ទាល់ខ្លួនរបស់ជនជាប់ចោទលើអ្នកជាប់ឃុំនៅស-២១ គឺការវាយដំអ្នកទោសជាមួយនឹងដំបង រំពាត់នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំលើកឡើងឧប្បត្តិហេតុនេះទាក់ទងទៅនឹងភស្តុតាងរបស់ ឡាច មាន, ជន ផល និង ញ៉ែម អេន។ ភស្តុតាងដែលបានយោងនៅក្នុងអង្គហេតុ គឺសំដៅទៅលើ ញ៉ែម អេន ដែលអាចរកបាននៅក្នុងសវនាការអត្ថបទជាភាសាអង់គ្លេសថ្ងៃទី៤ សីហា ២០០៩ នៅត្រង់ប្រតិចារឹក ទំព័រ១១៩ និង១២០ និង១២៨។

លោក លោកស្រីចៅក្រមជនជាប់ចោទ ក៏ត្រូវបានចោទប្រកាន់តាមមាត្រា២៩ ទាក់ទងទៅនឹងការញុះញង់ ការបញ្ជា ការជួយជ្រោមជ្រែង និងជាអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅស-២១។

និយាយឲ្យងាយស្តាប់ ប្រសិនណាជាយើងនៅចាំបានថា ការចូលរួមពាក់ព័ន្ធក្នុងការចាត់ចែងមន្ទីរស-២១ ចាប់តាំងពីការកកើតដំបូងរហូតមកថ្ងៃចុងក្រោយ ភស្តុតាងបានបញ្ជាក់យ៉ាងច្បាស់ថាគាត់បានចូលរួមទទួលខុសត្រូវក្នុងទម្រង់ទាំងអស់នេះ ដូចដែលបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

គាត់បានធ្វើសកម្មភាពនេះ ក្នុងមធ្យោបាយជាច្រើន ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ ដែលគាត់បានចូលរួមពាក់ព័ន្ធនៅក្នុងការបង្កើតពន្ធនាគារនេះ។ គាត់រៀបរាប់ចាត់ចែងតាំងពីទំហំពន្ធនាគារព្រមទាំងបុគ្គលិកនៅស-២១ និង២៤ ក៏ដូចជាទំហំនៃការប្រតិបត្តិការនៅក្នុងពន្ធនាគារនេះ ហើយជនជាប់ចោទ គឺថាមានតួនាទីដោយផ្ទាល់។ ទោះបីនេះជាលក្ខណៈដ៏សាមញ្ញមួយ ក៏យើងមានចំណុចលម្អិតដែលត្រូវយកខាងអង្គច្បាប់ដែលត្រូវយកមកអនុវត្ត ថាតើការចូលរួមរបស់គាត់ហ្នឹង ឆ្លើយតបទៅនឹងទម្រង់នៃការទទួលការខុសត្រូវបានដោយរបៀបណា? ដូចមានលើកឡើងនៅក្នុងសារណារបស់យើងដែលដាក់ជូនពីរសប្តាហ៍កន្លងមកហើយ។

លោក លោកស្រីចៅក្រម, ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ក្នុងនាមជាថ្នាក់លើដែលខកខានមិនបានការពារ ឬក៏មិនបានផ្តន្ទាទោស កូនចៅរបស់គាត់ពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ហើយគ្មានអ្វីដែលគួរសង្ស័យទាំងអស់នោះទេ គឺថាគាត់មានការគ្រប់គ្រងទាំងស្រុងទៅលើបុគ្គលិករបស់គាត់នៅ

ស-២១ និងនៅស-២៤ ហើយគាត់បានដឹងយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មទាំងអស់នេះ ពិតជានឹងត្រូវបានប្រព្រឹត្ត ឬមិនត្រូវបានប្រព្រឹត្តឡើង។ នេះគឺជាការពិត ដែលគាត់ចង់ឲ្យកូនចៅរបស់គាត់ប្រព្រឹត្តនៅឧក្រិដ្ឋកម្មទាំងអស់នេះ។

[០៩:០៨:១៨]

ឥឡូវនេះ ខ្ញុំសូមងាកទៅពិភាក្សាលម្អិតអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ ហៅថាការចូលរួមប្រព្រឹត្ត។ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមបញ្ជាក់នៅក្នុងសេចក្តីសម្រេចនូវការទទួលខុសត្រូវពេញលេញ នៃសកម្មភាពរបស់ជនឧក្រិដ្ឋដោយស្វែងរកឲ្យឃើញពិរុទ្ធភាពរបស់គាត់ ចំពោះឧក្រិដ្ឋកម្មនៅស-២១ ថាជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួម។

ទម្រង់នៃការទទួលខុសត្រូវនេះ ដូចដែលលោក លោកស្រីចៅក្រមបានដឹងហើយ ត្រូវបានកំណត់សម្រេចដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិ ថាជាទម្រង់មួយនៃការចូលរួមប្រព្រឹត្ត។ ថាតើហេតុអីបានចំណុចនេះ វាមានសាសំខាន់? នេះគឺដោយសារតែករណីរបៀបនេះ វាមានការឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់ទៅលើអង្គហេតុ និងគ្របដណ្តប់ទៅលើសារសំខាន់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ។ ជនជាប់ចោទមិនមែនធ្វើសកម្មភាពតែឯងទេ ហើយសកម្មភាពស-២១ ក៏មិនអាចសម្រេចឲ្យមានប្រសិទ្ធភាពទៅបាន ដោយមិនមានជនជាប់ចោទចូលរួមនៅក្នុងការធ្វើផែនការ និងការធ្វើការរួមគ្នាជាមួយនឹងថ្នាក់លើរបស់គាត់ផ្ទាល់ ក៏ដូចជាមួយកូនចៅផ្ទាល់របស់គាត់ផងដែរ។

លោក លោកស្រីចៅក្រម, នេះគឺជាសហកម្មដែលមានលក្ខណៈធំធេង ដែលអំពើឧក្រិដ្ឋគឺជាគោលបំណងរបស់វា។ ការទទួលស្គាល់ផ្លូវច្បាប់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយការចូលរួមនៅក្នុងការធ្វើផែនការ ឬក៏ក្នុងសហកម្ម វាជាផ្នែកនៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិតាំងពីនៅសវនាការតុលាការនូរ៉ឺប៊ឺកម៉្លែះ ហើយត្រូវបានអនុវត្តនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនៅអតីតយូហ្គោស្លាវី តុលាការអន្តរជាតិ នៅអតីតប្រទេសរ៉្វាន់ដា ដែលលក្ខន្តិកៈនេះ គឺមានលក្ខណៈដូចគ្នាទម្រង់នៃការទទួលខុសត្រូវក៏ដូចជានៅតុលាការនៅបូស្នៀរ-ហឺហ្ស៊ីកូវីណា តុលាការនៅសេរ៉ាឡេអូន ផងដែរ។ ដែលលក្ខន្តិកៈទាំងអស់នេះ គឺថាវាដូចគ្នាទម្រង់នៃការទទួលខុសត្រូវ ដែលមានចែងនៅក្នុងមាត្រា២៩នៃច្បាប់បង្កើត អ.វ.ត.ក ដោយការប្រើប្រាស់ភាសារបស់តុលាការ*អាយស៊ីធីវ៉ាយ* អ្នកតាក់តែងច្បាប់ អ.វ.ត.ក ពិតជាមានបំណងចង់ឲ្យមានការបកស្រាយ និងអនុវត្តច្បាប់នេះ ស្របគ្នាទៅនឹងច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។

[០៩:១០:៤៥]

ការអនុវត្តការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម គឺមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងបទដ្ឋានព្រហ្មទណ្ឌអន្តរជាតិ ដែលបានអនុវត្តនៅចំពោះមុខតុលារព្រហ្មទណ្ឌអន្តរជាតិ។ ជាការពិតណាស់ដោយសារអង្គហេតុនៃរឿងក្តីនេះ ការបដិសេធមិនអនុវត្តទម្រង់នៃការទទួលខុសត្រូវ អាចធ្វើឱ្យតុលាការនេះមានការមិនស៊ីសង្វាក់គ្នា ជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយនិងនាំឱ្យមានកំហុសនៅក្នុងការអនុវត្តច្បាប់។ សារសំខាន់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម គឺថាបុគ្គលមានតួនាទីដែលត្រូវទទួលខុសត្រូវពេញលេញទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួន។

ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម កើតចេញមកពីទស្សនៈព្រហ្មទណ្ឌដ៏ធំធេងរបស់ខ្លួន វាកើតចេញពីការរំលោភអំណាច តាមរយៈការជ្រើសរើសអ្នកដទៃឱ្យធ្វើជាឧបករណ៍ដើម្បីសម្រេចនូវគោលបំណងឧក្រិដ្ឋរបស់ខ្លួន។ ទម្រង់នៃការទទួលខុសត្រូវនេះ គឺកើតចេញមកពីសហកម្មឧក្រិដ្ឋកម្ម ដែលមានលក្ខណៈជាលំដាប់លំដោយ មានលក្ខណៈធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មព្រហ្មទណ្ឌរបស់បុគ្គល ឬក៏ការប្រព្រឹត្តឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល។ ការអនុវត្តឧក្រិដ្ឋកម្ម សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងករណីនេះ គឺមានលក្ខណៈសមស្រប ដោយសារវាអាចគ្របដណ្តប់ទៅលើទំហំនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយជនជាប់ចោទ។ វាក៏គ្របដណ្តប់ទៅលើការវិវត្តនូវឧក្រិដ្ឋកម្មទាំងអស់ និងមធ្យោបាយដែលជនជាប់ចោទបានរៀបចំផែនការឧក្រិដ្ឋកម្មនៅក្នុងរយៈពេលនោះ ដើម្បីកំណត់សត្រូវថ្មីៗ និងកំចាត់ពួកគេចោល។

[០៩:១២:២៩]

មេធាវីការពារមិនអាចត្អូញត្អែរ រអ៊ូរទាំថា មានការខ្វះខាតការជូនដំណឹងបានទេ សហព្រះរាជអាជ្ញាបានលើកឡើងពីអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួមតាំងពីការដាក់សារណាចុងក្រោយរបស់នៅក្នុងឆ្នាំ២០០៨នោះ។ នៅពេលដែលសហព្រះរាជអាជ្ញាប្តឹងជំទាស់ទៅនឹងដីកានេះកាលពីឆ្នាំទៅ គឺចំពោះឧក្រិដ្ឋកម្មជាតិ ឬក៏ទម្រង់នៃការទទួលខុសត្រូវ ជនជាប់ចោទនៅក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ គឺមិនមានការចាំបាច់ដូចដែលសហព្រះរាជអាជ្ញា អាចលើកបញ្ហានេះនៅក្នុងសវនាការនេះទេ។ នៅពេលបើកសវនាការសហព្រះរាជអាជ្ញាបានលើកអំពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ហើយគឺបានជំទាស់យ៉ាងតឹងតែងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះ។

យើងខ្ញុំមិនយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងទៅលើបញ្ហា ជេ.ស៊ី.អ៊ី (JCE) ហើយនិងសូមអញ្ជើញឱ្យស្វែងរកឱ្យឃើញពិរុទ្ធភាពរបស់ជនជាប់

ចោទ នៅក្នុងការចូលរួមប្រព្រឹត្ត នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនេះ ហើយជាផលវិបាកជនជាប់ចោទ គឺចាប់ពីឆ្នាំ២០០៨មក ជនជាប់ចោទគឺថាមិនអាចជំទាស់ថា មិនមានការជូនដំណឹងឲ្យបានគ្រប់គ្រាន់ ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវនេះទេ។

[០៩:១៣:៥៣]

លោក លោកស្រីចៅក្រម, ទាក់ទងទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់របស់ជនជាប់ចោទ គឺថាវាមានទាក់ទងតិចណាស់ ទាក់ទងទៅនឹងចំនួននោះ ក៏ប៉ុន្តែអំពើគឺមានទំហំធំធេង។ ខ្ញុំបានថ្ងៃនេះគឺបានដាក់ជូននៅក្នុងសារណាជាលាយលក្ខណ៍អក្សរនូវភស្តុតាង ដែលបង្ហាញយ៉ាងច្បាស់អំពីការប្រព្រឹត្តិអមនុស្សធម៌ និងការធ្វើទារុណកម្មអ្នកទោស នៅពេលដែលគាត់បានទះកំផ្លៀង វាយដំ ធាក់ទាត់។ ជាផលវិបាក អំពើទាំងអស់នេះគឺត្រូវបានរកឃើញថា មានពិរុណភាពនៅក្រោមទម្រង់នៃការចូលរួមប្រព្រឹត្តដោយផ្ទាល់។

ហេតុដូច្នេះខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមស្វែងរកឲ្យឃើញពិរុទ្ធភាពទៅលើជនជាប់ចោទ នៅគ្រប់បទចោទទាំងអស់ទាក់ទងទៅនឹងការប្រព្រឹត្តិ ការធ្វើផែនការ ការបញ្ជា ដើម្បី និងការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មទៅលើកូនចៅរបស់ខ្លួនក្នុងនាមជាមេ។ ទោះបីជាសហកម្មភាពរបស់ជនជាប់ចោទបានបង្ហាញយ៉ាងច្បាស់ថា ការចូលរួមរបស់គាត់នៅក្នុងការជួយជ្រោមជ្រែង ការឧបត្ថម្ភ និងជ្រោមជ្រែង យើងខ្ញុំសូមស្នើថា ទម្រង់នៃការទទួលខុសត្រូវផ្ទាល់នេះ គឺថាវាមានលក្ខណៈល្អប្រសើរជាង ហើយវាអាចគ្របដណ្តប់ដោយផ្ទាល់ទៅលើការទទួលទង្វើរបស់ជនជាប់ចោទ។ យើងខ្ញុំសុំដាក់ជូនឲ្យលើសពីវិមតិសង្ស័យដែលថាជនជាប់ចោទ គឺមានការទទួលខុសត្រូវទៅលើព្រហ្មទណ្ឌចំពោះបទល្មើសដូចខាងក្រោមនេះ៖

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានជាអាទិ៍ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ បទរំលោភសេពសន្ថវៈ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារតែមូលហេតុនយោបាយ ឬជាតិសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀត។

ទាក់ទងទៅនឹងការការរំលោភបំពានធ្ងន់ធ្ងរទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ទៅនឹងជនស៊ីវិលវៀតណាម ក៏ដូចជាឈ្លើយសឹកវៀតណាម មានដូចជាការសម្លាប់ដោយចេតនា ទារុណកម្ម អំពើអមនុស្សឃាត ការបង្កឲ្យមានរបួសធំធេងដល់រូបរាងកាយ និងសុខភាព ការកដហូតសិទ្ធិសេរីភាពរបស់អ្នកទោសសង្គ្រាម ឬក៏ជនស៊ីវិល ដែលត្រូវទទួលបានការកាត់សេចក្តីឲ្យបានត្រឹមត្រូវ និងទៀង

ទាត់ ក៏ដូចជាការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់។ ទារុណកម្មហើយនិងអំពើមនុស្សឃាដ ដែលផ្ទុយទៅនឹងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

អស់លោក លោកស្រីចៅក្រម, ខ្ញុំចូលទៅផ្នែកទី២នៃសារណារបស់យើងខ្ញុំ គឺបញ្ហានៃការផ្តន្ទាទោស។ ការវិនិច្ឆ័យទោសទៅលើឧក្រិដ្ឋកម្មទាំងអស់នេះគឺមិនមានអ្វីបង្ហាញនៅក្នុងប្រវត្តិតុលាការកម្ពុជាទេ ហើយក៏មិនមានគោលកាណ៍ណែនាំនៅក្នុងច្បាប់ជាតិ ជាពិសេសទាក់ទងទៅនឹងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការរំលោភបំពានទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ។ ក្រៅពីការដាក់ផ្តន្ទាទោសជាអតិបរមា និងអប្បបរមា ដែលមានចែងនៅក្រោមច្បាប់បង្កើត អ.វ.ត.ក ពីប្រាំឆ្នាំទៅដប់ឆ្នាំ។ ច្បាប់បង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុងក៏មិនបានចែងឲ្យមានជំនួនអ្វីផ្សេងក្រៅពីនេះទៀតដែរ។ ហេតុដូច្នេះអង្គជំនុំជម្រះមានកាតព្វកិច្ចពិនិត្យមើលទៅលើគោលការណ៍ផ្តន្ទាទោសដែលអាចរកឃើញនូវក្នុងតុលាការអន្តរជាតិដទៃទៀតទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រហាក់ប្រហែលគ្នានេះ។

[០៩:១៧:១៨]

ឥឡូវនេះ ខ្ញុំសូមចូលទៅលើផ្នែកគោលការណ៍នីមួយៗ។ ភាពធ្ងន់ធ្ងរ វាជាការ ពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ការផ្តន្ទាទោសត្រូវឆ្លុះបញ្ចាំងនូវភាពធ្ងន់ធ្ងរនៃទង្វើឧក្រិដ្ឋរបស់ជនជាប់ចោទ។ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មគឺ ជាចំណុចចាប់ផ្តើមសម្រាប់ការពិចារណារបស់អង្គជំនុំជម្រះទាក់ទងទៅនឹងទំហំនៃការផ្តន្ទាទោសឲ្យបានសមស្រប។ នៅក្រោមយុត្តាធិការអន្តរជាតិ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋគឺត្រូវបានវាយតម្លៃដោយពិចារណាទៅលើកត្តាបី ទីមួយសារសំខាន់នៃឧក្រិដ្ឋកម្ម និងមធ្យោបាយក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។ ពីរ ទំហំនៃផលប៉ះពាល់មកលើជនរងគ្រោះ និង បី កម្រិតនៃការចូលរួមរបស់ជនជាប់ចោទ។

[០៩:១៨:១៤]

ឥឡូវនេះ ខ្ញុំសូមចូលទៅពិនិត្យមើលកត្តានីមួយៗឲ្យដាច់ដោយឡែកពីគ្នា។ ទាក់ទងទៅនឹងសារជាតិនៃឧក្រិដ្ឋកម្ម ហើយនិងមធ្យោបាយដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះ មិនមានអ្វីវាគួរឲ្យសង្ស័យទេដែលថាឧក្រិដ្ឋកម្មនៅស-២១ គឺជាឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរបំផុតទាំងពីចំនួន ទាំងពីប្រភេទនៃឧក្រិដ្ឋ-កម្ម។ ដែលអាយុជីវិតមនុស្សជាងដប់ពីរពាន់នាក់ត្រូវបានកម្ទេចចោល។ ចំនួនភាគរយដ៏ច្រើននៃជនរងគ្រោះគឺត្រូវបានធ្វើទារុណកម្មយ៉ាងឃោឃៅ។ អ្នកទាំងអស់នោះត្រូវបានទទួលនូវស្ថានភាពឈឺចាប់ស្ទើរតែមិនអាចនិយាយបាន។ ជាពិសេសឧក្រិដ្ឋកម្មទាំងអស់នេះ មិនមែនជាឧក្រិដ្ឋកម្មតែបុគ្គលម្នាក់ទេ

ដែលកើតឡើងតែម្តងម្កាលនោះទេ ឬក៏បង្កើតឡើងដោយមិនមានការរៀបចំនោះទេ។

ឧក្រិដ្ឋកម្មទាំងអស់នេះកើតនៅក្នុងរយៈពេល៤១ខែ នៃប្រតិបត្តិការនៃពន្ធនាគារនេះ។ ទាំងអស់នេះគឺជាឧក្រិដ្ឋកម្មយ៉ាងឃោឃៅ និងគួរឲ្យរន្ធត់បំផុត។ ទាក់ទងទៅនឹងផលប៉ះពាល់ទៅលើជនរងគ្រោះ និងសាក្សី ជាពិសេសដោយពិចារណាទៅលើនូវការប៉ះពាល់ផ្លូវកាយក៏ឈឺផ្លូវការដែលមានរយៈពេលវែង ផលប៉ះពាល់នេះបានលាតសន្ធឹងទៅក្រុមគ្រួសារ និងមិត្តភក្តិរបស់ជនរងគ្រោះ ក៏ដូចជាសហគមន៍ទាំងមូល។

ដូចដែលយើងបានដឹងហើយ សម្រាប់អ្នកទោសនៅស-២១ កន្លែងនេះគឺថា ទៅហើយមិនអាចត្រឡប់មកវិញបានទេ។ មានតែមួយចំនួនតូចប៉ុណ្ណោះដែលរស់រានមានជីវិត។ អ្នករស់រានមានជីវិតបីនាក់ គឺបានផ្តល់សក្ខីកម្មដែលមានការភ័យខ្លាចទាំងផ្លូវកាយផ្លូវចិត្តជាប្រចាំ ពីការជាប់ពន្ធនាគារ និងការការប្រព្រឹត្តិអមនុស្សធម៌របស់ខ្លួន។ អ្នកទាំងអស់នេះ បានផ្តល់សក្ខីកម្មលម្អិតទាក់ទងទៅនឹងការឈឺចាប់ដែលខ្លួនបានទទួលរង ដែលខ្លួនស៊ូទ្រាំរហូតមកដល់សព្វថ្ងៃនេះ។ ជាពិសេសគឺការមិនមានស្ថិរភាពផ្លូវអារម្មណ៍ មានកំហឹង មានការក្រេវក្រោធ មានសុបិនអាក្រក់ ដែលការរស់រានរបស់គាត់ គឺថាជាឱកាសដ៏កម្រ។ សម្រាប់ជនរងគ្រោះនៅស-២១ ដែលមានរស់រានមានជីវិត សមាជិកគ្រួសារដែលមានជំងឺភ័យខ្លាច និងក៏ដូចជាមិត្តភក្តិគឺថាបានលាតសន្ធឹង មិនមែនតែក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ តែនៅទូទាំងពិភពលោក។

[០៩:២០:២១]

ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ឃាដកម្មមកលើអ្នកជាទីស្រឡាញ់របស់ខ្លួននោះ គឺបានធ្វើឲ្យខ្លួនបាក់បែកក្រុមគ្រួសារ។ ភស្តុតាងបានបង្ហាញឲ្យឃើញថា ការឈឺចាប់បាននាំឲ្យសមាជិកក្រុមគ្រួសាររបស់ជនរងគ្រោះឈានទៅដល់ធ្វើអត្តឃាដដែលជាមធ្យោបាយមួយដើម្បីដោះស្រាយនៅទុក្ខសោកសង្រេងរបស់ខ្លួន។ ចំនួនសាច់ញាតិ និងមិត្តភក្តិដែលទទួលផលប៉ះពាល់នៅស-២១ ដោយផ្ទាល់គឺមិនអាចដឹងចំនួនទេ ប៉ុន្តែវាអាចមានចំនួនដល់រាប់សិប បើមិនថ្នាក់ដល់រាប់រយរាប់ពាន់នោះទេ។ ហើយក៏មិនត្រូវភ្លេចផងដែរថា មានសមាជិកថ្នាក់ទាបនៅស-២១ ជាច្រើន ដែលអ្នកទាំងនោះមកពីប្រវត្តិក្រុមគ្រួសារកសិករក្រីក្រ ដែលត្រូវបង្ខំឲ្យចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះប្រឆាំងទៅនឹងឆន្ទៈរបស់ខ្លួន ដែលគេទទួលរងគ្រោះមកដល់សព្វថ្ងៃនេះ ហើយដែលគេ ដែលត្រូវបានបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ។

ច្បាស់ណាស់ថាផលវិបាកនៃឧក្រិដ្ឋកម្មនៅស-២១ សម្រាប់សហគមន៍ទាំងមូលនេះគឺថានៅតែទទួលរងមកដល់ថ្ងៃនេះ។ ឧទាហរណ៍ ដុកទ័រ ឈឹម សុធារ៉ា បានផ្តល់សក្ខីកម្មយ៉ាងវែងអំពីដំណើរមិនប្រក្រតីនៃការប៉ះពាល់ទៅដល់ផ្លូវចិត្ត ដែលរងគ្រោះដោយសារជនរងគ្រោះនៃឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា។ កាលនោះ ស-២១ គឺជាផ្នែកមួយនៃឧក្រិដ្ឋកម្មដែលបន្សល់ទុកនូវការភ័យខ្លាច អំពើហិង្សា ការធុញថប់ផ្លូវអារម្មណ៍ ការបាក់បែក ការបំផ្លិចបំផ្លាញ អត្តសញ្ញាណគ្រួសារ វប្បធម៌ និងសង្គម។

លោក លោកស្រីចៅក្រម, វិសាលភាពនៃការចូលរួមរបស់ជនរងគ្រោះត្រូវតែយកមកពិចារណានៅក្នុងការផ្តន្ទាទោស។ នៅក្រោមច្បាប់អន្តរជាតិ ករណីជាច្រើនគឺថាវាមានលក្ខណៈពីរ។ ទីមួយគឺជនជាប់ចោទបង្កការឈឺចាប់មកលើជនរងគ្រោះដោយផ្ទាល់ដៃ និងទីពីរជនជាប់ចោទ ដោយសារតែខ្លួនមានតួនាទីជាមេ អាចបង្កការឈឺចាប់តាមរយៈអ្នកដទៃទៀត។ នៅពេលដែលជនជាប់ចោទជាអ្នកធ្វើជាមេ និងជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ គឺថាគេត្រូវតែទទួលការស្តីបន្ទោសកាន់តែខ្លាំងៗឡើង។ ដូចគ្នានេះដែរ ជនជាប់ចោទបង្ហាញនូវការអបអរសារទរពេញចេញនូវពេលដែលចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ។ ដូចគ្នានោះដែរ នៅពេលដែលជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយស្ម័គ្រចិត្តដោយដឹងជាមុន និងដោយមានការគិតគូទុកជាមុន។ ដូចដែលខ្ញុំបានពន្យល់ពីដើមទី គឺជនជាប់ចោទបានចូលរួម និងបានធ្វើការជាមួយបក្សកុម្មុយនីស្តកម្ពុជាដោយមានការដឹងយ៉ាងពេញលេញអំពើហិង្សា ដើម្បីសម្រេចនូវគោលបំណងរបស់ខ្លួន។

[០៩:២៣:០៨]

នៅក្នុងការចូលរួមនេះ គឺគាត់បានធ្វើការជារហូតបានទទួលឋានានុក្រមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ក្លាយជាអ្នកជំនាញសន្តិសុខដែលគួរឲ្យទុកចិត្តបំផុតពីសំណាក់មេដឹកនាំជាន់ខ្ពស់បំផុតរបស់បក្ស។ នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ ជនជាប់ចោទគឺថាមានការពេញចិត្ត និងមានការអបអរសាទរក្នុងនាមជាគ្រូបង្រៀនម្នាក់ គាត់បានបណ្តុះបណ្តាលសាបព្រោះបុគ្គលទាំងនោះឲ្យក្លាយទៅជាអ្នកធ្វើទារុណកម្ម និងជាឃាតក។ គាត់ជាមនុស្សឥតខ្ចោះ ដែលក្នុងការធានាឲ្យមានការចាត់ចែងស-២១ ឲ្យបានត្រឹមត្រូវទាក់ទងទៅនឹងការបញ្ជាឲ្យធ្វើទារុណកម្ម ហើយនិងបច្ចេកទេសធ្វើទារុណកម្ម និងការសួរចម្លើយ។

តួនាទីក្នុងនាមជាប្រធាន ជនជាប់ចោទមានការទទួលខុសត្រូវក្នុងការពង្រីកបណ្តាញនៃការភ័យខ្លាច និងការឈឺចាប់នៅក្នុងប្រទេសកម្ពុជា។ ដោយសារតែការវិភាគនូវចម្លើយសារភាព និងអនុសាសន៍

មនុស្សរាប់ពាន់នាក់ត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម និងចុងបញ្ចប់ត្រូវគេសម្លាប់ចោល។ នៅក្នុងស-២១ គាត់បានបញ្ជាឲ្យកូនចៅរបស់គាត់សួរចម្លើយនិងសម្លាប់។ ដោយសារការទទួលសារភាពដោយផ្ទាល់ គាត់បានទៅពិនិត្យមើលនូវបន្ទប់តូចៗសួរចម្លើយ ហើយគាត់បានផាក់ទាត់អ្នកទោសដោយផ្ទាល់។

សេចក្តីស្មោះត្រង់របស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាគឺមិនមានគុណវិបត្តិអីនោះទេ វាអនុញ្ញាតឲ្យគាត់ប្រព្រឹត្តយ៉ាងពេញលេញដើម្បីទទួលបាននូវតួនាទីទាំងអស់នេះ។ បើពិនិត្យទៅមើលទាំងមូល គឺថាគាត់ចូលរួមដ៏ធំធេងនៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ ធ្វើឲ្យគាត់ក្លាយទៅជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីស្វែងរកចាប់ខ្លួន និងសម្លាប់ខ្មាំង។

ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយជនជាប់ចោទនៅស-២១ គឺពិបាកនឹងប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រដ៏ទំនើបទាក់ទងទៅនឹងភាពឃោឃៅ ទំហំ រយៈពេលការគិតទុកជាមុន។

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់កាលៈទេសៈរបស់ជនជាប់ចោទ ដែលជាកត្តាសម្រាប់ការធ្វើការផ្តន្ទាទោស ជាពិសេសទាក់ទងទៅនឹងអាយុ ហើយនិងការអប់រំរបស់គាត់នៅពេលដែលគាត់ចូលរួមនៅស-២១។ ខុសពីបុគ្គលិកដទៃទៀតដែលគាត់បានជ្រើសរើស ជនជាប់ចោទមានការយល់ចេះដឹងខ្ពស់ ឆ្លាតវាងវៃ ជាមនុស្សមានហេតុមានផល ហើយច្បាស់ណាស់គាត់មានលទ្ធភាពក្នុងឈានឆ្ពោះទៅកាន់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ងាកចេញពីបក្សកុម្មុយនីស្តកម្ពុជា គាត់ជាអ្នកធ្វើការជ្រើសរើស។ នៅពេលដែលគាត់ឈប់ធ្វើការនៅស-២១ គាត់មានអាយុជាង៣០ឆ្នាំ។ គាត់មិនមែនជាមនុស្សឆោតល្ងង់ ខុសពីអ្នកទាំងឡាយដែលគាត់បានជ្រើសរើស និងគាត់បានបំពាក់បំប៉នមនោគមវិជ្ជា។

[០៩:២៦:០៣]

ដោយការចំណាយអស់រយៈពេលបួនឆ្នាំក្នុងនាមជាប្រធានម-១៣ គាត់ដឹងថាអ្វីដែលគាត់ចង់បាន។ ប្រហែលជាវាមានលក្ខណៈស្មុគស្មាញជាងប្រតិបត្តិការនៅស-២១។ ម-១៣ មានគោលបំណងគឺវិធីប្រតិបត្តិការដូចគ្នា។ គោលបំណងគឺដើម្បីចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ខ្មាំងនៃបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឆ្លងតាមបទពិសោធន៍នេះជនជាប់ចោទមិនមែនគ្រាន់តែអ្នកបានបញ្ជាឲ្យធ្វើទារុណកម្ម ឬក៏ធ្វើទារុណកម្ម ឬក៏សម្លាប់-- ប៉ុន្តែគាត់បានប្រព្រឹត្តអំពើនេះដោយផ្ទាល់ខ្លួន។

ហេតុដូច្នេះ ចាប់ពីពេលដែលគាត់ត្រូវបានស្នើសុំឲ្យបង្កើតស-២១ ការធ្វើទារុណកម្ម ការសម្លាប់ដែលជាកន្លែងសម្លាប់លើកទីពីរ ជនជាប់ចោទបានយល់ដឹងអំពីសារសំខាន់នៃការទទួលខុសត្រូវ ហើយគាត់មានចេតនាទទួលយកនូវកិច្ចការនេះ។ ជាការពិត គឺគាត់ជាអ្នកដែលមានបញ្ញាវាងវៃ ដែលទទួល

ខុសត្រូវមានការអប់រំខ្ពស់នៅពេលដែលគាត់សម្រេចចិត្តជ្រើសរើសទាក់ទងទៅនឹងបញ្ហានេះ ដែលជាបញ្ហាសម្រាប់ឲ្យអង្គជំនុំជម្រះពិចារណានៅក្នុងបរិបទនៃការធ្វើការផ្តន្ទាទោស។

ទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស កម្រិតនៃការចូលរួមរបស់ជនជាប់ចោទនិងកាលៈទេសៈ។ ឥឡូវនេះ ខ្ញុំសូមចូលទៅដល់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលពិចារណាជាស្ថានទំងន់នៅក្នុងការពិចារណាទៅលើការផ្តន្ទាទោសឲ្យបានសមស្រប។ មានកត្តាស្ថានទំងន់បីដែលត្រូវបានទទួលស្គាល់នៅក្នុងករណីទាក់ទងបែបនេះ។ ទីមួយ គឺការរំលោភអំណាចរបស់ជនជាប់ចោទ។ ទីពីរ ការបង្កការឈឺចាប់ដ៏ឃោរឃៅ និងទីបី ភាពគ្មានទីពឹងរបស់ជនរងគ្រោះ។

ការរំលោភបំពានអំណាច។ បើទោះណាអង្គហេតុតែមួយដែលថា ជនជាប់ចោទមានអំណាច អំណាចជនជាប់ចោទតែមួយមិនមែនជាកត្តាស្ថានទំងន់ ប៉ុន្តែចរិកលក្ខណៈនៅក្នុងការអនុវត្តអំណាចនេះអាចជាស្ថានទំងន់បាន។

[០៩:២៨:០៧]

ជនជាប់ចោទ ក្នុងនាមជាមេគុក មានកាតព្វកិច្ចផ្លូវច្បាប់ និងសីលធម៌ក្នុងការការពារទៅដល់សិទ្ធិរបស់អ្នកជាប់ឃុំឃាំង។ ប៉ុន្តែ ក្នុងតថភាពពិតនោះ គឺគាត់បានគ្រប់គ្រងទៅលើការប្រព្រឹត្តិជាហូរហែ ការធ្វើទារុណកម្ម និងការសម្លាប់ អ្នកដែលត្រូវគាត់ធ្វើការទទួលការថែទាំនោះ។ គ្មានចំណុចណាមួយក្នុងនាមជាប្រធានដែលអាចនិយាយបានថា គាត់មានចេតនាដើម្បីការពារទៅដល់សុខមាលភាពរបស់ជន របស់អ្នកទោសនោះទេ។ ជនជាប់ចោទ មិនបានគិត គាត់បានគិតផ្ទុយពីនេះទៅវិញ។ គោលបំណងរបស់គាត់ មិនមែនការពារទេ ប៉ុន្តែគឺជាការបន្ទាបបន្ថោក ធ្វើទារុណកម្មសម្លាប់អ្នកដែលគួរតែត្រូវទទួលបានការការពារពីគាត់មកវិញនោះ។

ទីពីរ ទាក់ទងទៅនឹងភាពឃោរឃៅ ដែលឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានប្រព្រឹត្តឡើង យុត្តាធិការអន្តរជាតិលើកឡើងថា ការបង្កការឈឺចាប់អាចចាត់ទុកថាជាកត្តាស្ថានទំងន់។ ការឈឺចាប់បែបនេះ គឺវាលើសពីការប្រព្រឹត្តិឧក្រិដ្ឋកម្មជាធម្មតា ជាពិសេសបញ្ហាញឲ្យឃើញនូវភាពឃោរឃៅ ឃើញអ្នកដទៃសប្បាយ និងឃើញអ្នកដទៃឈឺចិត្តនឹងការគ្មានមេត្តាធម៍។ ហើយភាពឃោរឃៅនេះអាចចាត់ទុកថាវាប៉ះពាល់ទាំងផ្លូវកាយនិងផ្លូវចិត្ត។

ប្រភេទនៃអំពើឃោរឃៅដែរប្រើប្រាស់ដោយអ្នកយាម និងអ្នកសួរចម្លើយនៅស-២១ គឺពិតជាឃោរឃៅមែន។ អ្នកទោសគឺជាកម្មវត្ថុទៅនឹងអំពើឃោរឃៅ វាយដំដោយមានឈាមនៅលើស្នាមរបួស

របស់ខ្លួន ក្រចកជើងនិងក្រចកដៃរបស់គេ ត្រូវបានដកដោយដង្កាប់។ អ្នកទាំងអស់នោះត្រូវបានបង្ខំឲ្យគោរពរូបសំណាកសត្វឆ្កែ និងឧបករណ៍ដទៃទៀត។ អ្នកទោសខ្លះទៀតត្រូវបានឆក់នឹងខ្សែភ្លើង រហូតដល់សន្លប់បាត់ស្មារតី ហើយអ្នកដទៃទៀតត្រូវបានជ្រមុជទឹកស្ទើរស្លាប់។ ជាពិសេសអំពើឃោរឃៅទាក់ទងទៅនឹងការបង្ខំឲ្យអ្នកទោសបរិភោគលាមកខ្លួនឯង។ អ្នកទោសក៏បានទទួលនូវអំពើឈឺចាប់នទូទាំងអាយុជីវិតរបស់គេ ជាពិសេសការកាត់បង្ហូរឈាម ដែលនាំឲ្យអ្នកទាំងអស់នោះទទួលមរណភាពយឺតៗ និងឃោរឃៅបំផុត។

[០៩:៣០:៣៧]

ភាពឃោរឃៅនៅស-២១ មួយនេះ គឺថាវាឈឺចាប់យ៉ាងខ្លាំង ការភ័យខ្លាច ការរន្ធត់ ភាពច្របូកច្របល់ ដែលជនរងគ្រោះបានទទួល គឺថាវាលើសពីក្តីយើងស្រមៃ។ អ្នកទោសទាំងអស់នេះត្រូវបានដាក់ឃុំនៅក្នុងបន្ទប់តូចៗ ដឹងអំពីទារុណកម្ម ឈឺចាប់ ការឈឺចាប់នៅជុំវិញខ្លួន និងឃើញមានអ្នករងរបួស ឃើញសំឡេងធ្ងន់ធ្ងររបស់អ្នកទោសដទៃទៀត។ ការបន្ទាបបន្ថោក និងស្ថានភាពគ្មានអនាម័យធ្វើឲ្យអ្នកទោសទទួលធ្លាក់ខ្លួនឈឺ អ្នកទោសខ្លះបានស្លាប់នៅក្នុងស្ថានភាពទាំងអស់នេះ ហើយសាកសពរបស់គេត្រូវបានទុកចោលនៅក្នុងខ្នោះឃ្នាងដាក់ជើងរួមគ្នាជាច្រើនម៉ោងមុននឹងយកចេញទៅ។

ដោយពិចារណារទៅលើអ្នកទោសម្នាក់ៗ ដែលធ្លាក់ខ្លួនឈឺ ដែលដោយមានខ្នោះជើង នៅពេលដែលអ្នកទោសដទៃទៀតបាត់ខ្លួន អ្នកទាំងនោះគិតថា តើថាដល់ណាដែលពេលគេត្រូវហៅខ្លួនទៅ? អ្នកទោសខ្លះទៀតសម្រេចធ្វើមនុស្សឃាត ដែលខ្លួនគិតថាស្លាប់ទៅប្រសើរជាជាងការឈឺចាប់ទាំងនៅរស់។

ជាថ្មីម្តងទៀត ការប៉ះពាល់ទៅដល់ផ្លូវចិត្តទាំងអស់នេះ ដោយសារតែការសួរចម្លើយជាច្រើនច្រើនសា ការធ្វើទារុណកម្ម គឺជាអំពើហិង្សាដ៏ឃោរឃៅ ដែលអ្នកទោសទាំងអស់នេះបានស៊ូទ្រាំ។ អ្នកទោសខ្លះត្រូវបានចងមុខ និងដាក់ខ្នោះដៃ ហើយបង្ខំឲ្យលុតជង្គង់នៅទីងងឹត មុននឹងធាក់ទម្លាក់ទៅក្នុងរណ្តៅ។ ពួកគេត្រូវរង់ចាំនៅទីនោះរហូតដល់គេត្រូវវាយនឹងត្បូងចប ឬកាបរទេះ ពីខាងក្រោយក្បាល ហើយមុននឹងគេត្រូវធាក់ទម្លាក់ចូលទៅក្នុងរណ្តៅ។

លោក លោកស្រី ចៅក្រម, កត្តាទីបីនិងចុងក្រោយសម្រាប់ការពិចារណា គឺភាពគ្មានទីពឹងរបស់ជនរងគ្រោះ។ អ្នកទោសទាំងអស់នេះមិនមានការពារដោយមានការអត់ឃ្លាន ជាប់ខ្នោះ ធ្វើទារុណកម្ម ពួកគេគ្មានលទ្ធភាពនឹងការពារខ្លួន ពួកគេគ្មានអ្នកជួយគេបានឡើយ។

លោក លោកស្រីចៅក្រម, យើងខ្ញុំសូមលើកឡើងថា នៅក្នុងករណីទាំងអស់នេះ កត្តាស្ថានទម្ងន់

ទាំងបី គឺមានការបំពានអំណាច ភាពឃោរឃៅនៃឧក្រិដ្ឋកម្ម ភាពគ្មានទីពឹងរបស់ជនរងគ្រោះ វាមានភាពពាក់ព័ន្ធដោយផ្ទាល់ ហើយយើងត្រូវយកមកពិចារណាទៅពេលសម្រេចផ្តន្ទាទោសជនជាប់ចោទ។

[០៩:៣៣:១៩]

លោក លោកស្រីចៅក្រម, យើងត្រូវពិចារណាទៅលើស្ថានទម្ងន់ទោស នៅពេលដែលលោក លោកស្រីចៅក្រមសម្រេចលើការផ្តន្ទាទោស ហើយក៏ត្រូវពិចារណាទៅលើស្ថានសម្រាលផងដែរប្រសិនបើមាន។ មេធាវីការពារក្តីអាចតវ៉ាថា ជនជាប់ចោទប្រព្រឹត្តអំពើរបស់ខ្លួនក្រោមការបង្ខិតបង្ខំ ហើយដោយសារតែគាត់បំពេញការងារតាមបញ្ជារបស់ថ្នាក់លើ។ បន្ថែមពីលើនេះ មេធាវីការពារក្តីអាចស្នើសុំឱ្យលោក លោកស្រីចៅក្រមពិចារណាទៅលើការសហការរបស់គាត់ ការសារភាពលើអង្គហេតុវិប្បដិសារី និងផលដែលកត្តាទាំងនេះអាចមានទៅលើការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា។

ខ្ញុំនឹងរៀបរាប់អំពីការបង្ខិតបង្ខំ។ ដូចដែលខ្ញុំបានពន្យល់យ៉ាងច្រើនរួចមកហើយ ជនជាប់ចោទអះអាងថា គាត់ស្អប់ខ្ពើមការងារគាត់ ហើយការប្រព្រឹត្តអំពើទាំងអស់នេះក្រោមការបង្ខិតបង្ខំ ដោយសារការភ័យខ្លាចដែលគេនឹងសម្លាប់គាត់ ប្រសិនបើគាត់មិនគោរពតាមបញ្ជា។ ដូចដែលខ្ញុំបានបញ្ជាក់មុននេះ ភ័ស្តុតាងមិនបានគាំទ្រទៅលើការបកស្រាយអង្គហេតុតាមរបៀបនេះឡើយ។ ការអះអាងដែលជនជាប់ចោទលើកឡើងថា ជាចំណាប់ថ្នូរ និងជាអ្នកទោស បក្សកុម្មុយនីស្តកម្ពុជា ទោះបីជានៅដំណាក់ដំបូង នៅពេលដែលគាត់ពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋនោះក៏ដោយ ចំណុចទាំងអស់នេះ គឺវាផ្ទុយទៅការរៀបរាប់របស់ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលជាអ្នកទោស និងមនុស្សទុកចិត្តរបស់ជនជាប់ចោទនៅម-១៣។ គាត់សរសេរថា ការភិតភ័យចាប់ពីពេលនោះ កាន់តែមានអំណាចខ្លាំងឡើង។ គាត់បានយកការភិតភ័យមកអនុវត្តជំនួសគោលការណ៍សីលធម៌ និងការគោរពបញ្ជា។ លោក ប៊ីហ្សូ មិនគិតថាគាត់ជាមនុស្សដែលមានការភ័យខ្លាចនោះទេ ប៉ុន្តែគាត់ជាបុរសដែលធ្វើឱ្យគេភ័យខ្លាច។ ការអះអាងរបស់ជនជាប់ចោទ ថាគាត់មានការភ័យខ្លាចនៅស-២១ គឺវាផ្ទុយទៅនឹងចម្លើយរបស់គាត់ ដែលគាត់ផ្តល់ជូនសហចៅក្រមស៊ើបអង្កេត។ គាត់បានប្រាប់ចៅក្រមស៊ើបអង្កេតថា ខ្ញុំសូមដកស្រង់សម្តី “ខ្ញុំទទួលរងប៉ះពាល់អារម្មណ៍ បន្ទាប់ពីឃើញការចាប់កម្មាភិបាលពីភូមិភាគឧត្តរទាំងឈុត នៅថ្ងៃ៣១ មករា ឆ្នាំ១៩៧៧។ ខ្ញុំមានអារម្មណ៍អាណិតអាសូរចំពោះពួកគេ ខ្ញុំមានការភិតភ័យ ហើយបន្ទាប់ពីការចាប់ខ្លួន វ៉េត យូ ហៅ ហុង នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨ និង វន វ៉េត នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្ញុំចាប់ផ្តើមមានការភិតភ័យអាយុជីវិតរបស់ខ្ញុំ”។

[០៩:៣៦:០៣]

ហេតុដូច្នេះ តាមពាក្យរបស់គាត់ គាត់បានចាប់ផ្ដើមភ័យខ្លាចនឹងអាយុជីវិតរបស់គាត់នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨។ ចំណុចនេះទំនងត្រូវនឹងការពិត ហើយវាត្រូវគ្នានឹងការវិភាគរបស់បណ្ឌិត ឆេនដ័ល័រ នៅពេលតវ៉ាអំពីការភិតភ័យ ការបង្ខិតបង្ខំ មេធាវីការពារក្ដីអះអាងថា ការភ័យខ្លាចបណ្ដាលមកពីបរិយាកាសនៃការភ័យខ្លាចនៅក្នុងរបប។ ប៉ុន្តែ បរិយាកាសនេះយើងឃើញវាពិតជាមានមែន ហើយវាបានបង្ហាញរយៈសាក្សី និងអ្នកជំនាញនៅពេលធ្វើសវនាការ ហើយយើងឃើញថាវាមានមែន នៅលើចំណុចហ្នឹង។ ប៉ុន្តែ អ្វីដែលមេធាវីការពារក្ដីមិនបានបង្ហាញ គឺថាជនជាប់ចោទគាត់មិនទទួលនូវការភិតភ័យនោះទេ។ តាមពិតទៅភ័ស្តុតាងបង្ហាញថា គាត់មិនទទួលរងអារម្មណ៍នោះឡើយ។ ភ័ស្តុតាងបង្ហាញថា គាត់មិនមែនជាជនរងគ្រោះនៃការភ័យខ្លាចទេ តែជនបង្កការភ័យខ្លាច។ ជនជាប់ចោទដែលជាអ្នកការពារមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ទទួលការងារប្រមូលព័ត៌មានស៊ើបការណ៍និងសន្តិសុខរដ្ឋ។ តួនាទីរបស់គាត់បានធ្វើឱ្យគាត់ តាមសម្ដីរបស់ អេលីហ្សាប៊ែត បេកយ័រ ជននេះជាមេដឹកនាំជាន់ខ្ពស់មួយរូបក្នុងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅក្នុងប្រទេស។ ដោយយើងយកមកពិចារណារួមគ្នាភ័ស្តុតាងមិនបានបង្ហាញថា គាត់ជាមនុស្សមានការភ័យខ្លាចនោះទេ។ ផ្ទុយមកវិញ គាត់ជាមនុស្សមានទំនុកចិត្តដែលធ្វើឱ្យមានការភ័យខ្លាចរីករាលដាលពេញផ្ទៃប្រទេសតាមរយៈការងាររបស់គាត់នៅមន្ទីរស-២១។ ជាបុរសមួយដែលគ្មានអ្នកណាជំនួសតំណែងគាត់បាន។

គេទទួលស្គាល់ថា របបផ្ដាច់ការរក្សាការគ្រប់គ្រងរបស់ខ្លួនតាមរយៈការបំភិតបំភ័យ ហើយគេក៏បានទទួលស្គាល់ថា ប្រព័ន្ធនៃការភិតភ័យនេះ តែងតែជះត្រឡប់មកអ្នកបង្កើតការភិតភ័យវិញ។ ទស្សនាវិទូ និងជនរស់រានមានជីវិតពីរបបហ្វូឡូខូស ឈ្មោះ ហាណា អារ៉េត បានលើកឡើងថា ការភិតភ័យមិនត្រឹមតែកើតឡើងចំពោះខ្មាំងទេ ប៉ុន្តែវាកើតឡើងចំពោះមិត្ត អ្នកគាំទ្ររបបនោះផង។ បរិយាកាសនេះវានឹងទៅដល់ចំណុចកំពូល នៅពេលដែលរដ្ឋចាប់ផ្ដើមហែកហួកូនចៅរបស់ខ្លួន ឬក៏ប្រជាជនរបស់ខ្លួនហើយពេជ្ឈឃាដកាលពីម្សិលក្លាយទៅជាជនរងគ្រោះថ្ងៃនេះ។ ដោយយើងពិចារណាទៅលើប្រព័ន្ធការភ័យខ្លាច ដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាមិនមានអ្វីភ្ញាក់ផ្អើលទេ ដែលថាជនជាប់ចោទនិងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតមានអារម្មណ៍ភ័យខ្លាច។

[០៩:៣៨:៤៧]

ប៉ុន្តែ វាមានការភ្ញាក់ទៅវិញទេប្រសិនបើជនជាប់ចោទមិនមានការភ័យខ្លាច។ ជនជាប់ចោទ

ដែលមានអារម្មណ៍ភិតភ័យនៅក្នុងឆ្នាំ១៩៧៨ មិនមែនថាវាមានឧត្តមភាពទៅលើអង្គហេតុថា គាត់ជាជនដែលមានឆន្ទៈនឹងចូលរួមនៅក្នុងឧក្រិដ្ឋកម្មនោះទេ។ ជនជាប់ចោទមិនអាច រួចយកមកលាក់បាំងនូវភាពភិតភ័យរបស់ខ្លួននោះទេ ហើយគាត់មិនអាចទទួលផលប្រយោជន៍ដោយសារគាត់និយាយថា គាត់មានអារម្មណ៍ភិតភ័យក្នុងឆ្នាំ១៩៧៨នោះទេ ពីព្រោះយើងឃើញថា ឧក្រិដ្ឋកម្មភាគច្រើន វាបានប្រព្រឹត្តរួចទៅហើយ។

ការបង្ខិតបង្ខំ គឺវាទាក់ទងទៅនឹងស្ថានសម្រាលទោស នៃការប្រព្រឹត្តឧក្រិដ្ឋកម្មតាមបង្គាប់របស់ថ្នាក់លើមាត្រា២៩ នៃច្បាប់ អ.វ.ត.ក គឺទុកឱកាសលលទ្ធភាពថា អំពើដែលអនុវត្តតាមបញ្ជាថ្នាក់លើអាចសម្រាលនូវការដាក់ទោស ប៉ុន្តែវាមិនអាចជាការរំលត់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

តាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ កូនចៅដែលព្យាយាមយកបញ្ជារបស់ថ្នាក់លើមកជាស្ថានសម្រាលទោសនោះក៏ត្រូវបង្ហាញថា បញ្ជាទាំងអស់នោះមានឥទ្ធិពលទៅលើអាកប្បកិរិយារបស់គាត់ ប្រសិនបើកូនចៅគាត់រៀបចំអនុវត្តអំពើឧក្រិដ្ឋទៅហើយនោះ មិនមានស្ថានសម្រាលទោសមានឡើយ។

ដូច្នេះ យើងថា ស្ថានភាពនេះគឺវាត្រូវនឹងជនជាប់ចោទរូបនេះ។ ដូចដែលភ័ស្តុតាងបានបញ្ជាក់ជនជាប់ចោទមានបំណងក្នុងការអភិវឌ្ឍ ឬក៏ធ្វើឲ្យធ្វើបដិវត្តន៍នេះដំណើរការទៅមុខ កម្មេចខ្លាំងមិនមែនជាក់លាក់របស់ថ្នាក់លើ ដែលបណ្តាលឲ្យគាត់ចូលរួមក្នុងឧក្រិដ្ឋកម្មរបស់គាត់នោះទេ។ ជននេះជឿទៅលើភាពស្របច្បាប់នៃបញ្ជា ហើយបានផ្តល់យោបល់ណែនាំនៅក្នុងករណីជាច្រើនដែលនាំឲ្យមានការចេញបញ្ជា។ ដោយហេតុផលទាំងអស់នេះ យើងខ្ញុំសូមលើកឡើងថា ស្ថានសម្រាលទាក់ទងទៅនឹងការបំភិតបំភ័យនិងបញ្ជា តាមបញ្ជាថ្នាក់លើមិនអនុវត្តក្នុងរឿងក្តីនេះឡើយ។

នៅពេលនេះ គឺខ្ញុំសូមរៀបរាប់អំពីស្ថានសម្រាលបួនទៀតដែលពាក់ព័ន្ធ ដែលអាចស្នើសុំពីជនជាប់ចោទឲ្យ លោក លោកស្រី ចៅក្រម ពិចារណានៅពេលកំណត់ការផ្តន្ទាទោស។ ទាំងអស់នេះ ស្ថានសម្រាលទាំងអស់នេះរួមមាន ការសហការ ការសារភាពទោស វិប្បដិសារី និងផលប៉ះពាល់ដែលអាចមានការចំពោះការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា។

[០៩:៤១:២៨]

យុត្តិសាស្ត្រអន្តរជាតិបានទទួលស្គាល់យ៉ាងច្បាស់ថា ការសហការរបស់ជនជាប់ចោទជាមួយនឹងសហព្រះរាជអាជ្ញា គឺជាស្ថានសម្រាលដែលយើងត្រូវយកមកពិចារណានៅពេលផ្តន្ទាទោស។ ការផ្តល់ជាប្រយោជន៍ទៅលើចំណុចនេះ វាស្រ័យទៅលើគុណភាព និងបរិមាណនៃព័ត៌មានដែលផ្តល់ជូន

ហើយនិងព័ត៌មាននោះបានផ្ដល់ជូនដោយឆន្ទៈនិងស្មោះត្រង់ដែរឬទេ? ដោយមិនគិតអំពីផលប្រយោជន៍របស់ខ្លួន។ នៅពេលដែលយើងពិចារណាថា ការសហការមានការប្រសិទ្ធភាពដល់ការជំនុំជម្រះ នោះគាត់ទទួលបានផលប្រយោជន៍។ ដូច្នេះការសហការនៅមុនដំបូងវាមានភាពចាំបាច់ ជនជាប់ចោទគាត់បានធ្វើការសហការដោយផ្ដល់ចម្លើយទៅនឹងជនដទៃទៀតនៅកាលជំនុំជម្រះលើកក្រោយ។

ព័ត៌មានរបស់ជនជាប់ចោទ វាអាចជួយឲ្យមានការពង្រឹងទៅលើអង្គហេតុ។ ដូច្នេះ វាជួយសន្សំធនធានរបស់តុលាការ ប៉ុន្តែប្រសិនបើព័ត៌មានមានកម្រិត ហើយវាមិនពិតនោះ ហើយព័ត៌មាននោះវាមិនគ្រប់គ្រាន់ នៅពេលនោះស្ថានសម្រាល គឺវាមិនពិតជាមាននោះទេ។

លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំសូមលើកឡើងថា នៅក្នុងរឿងក្ដីនេះ ភាពងាយស្រួលបំផុតក្នុងការវិភាគទៅលើការសហការរបស់ជនជាប់ចោទ យើងត្រូវពិចារណាទៅលើអំពើរបស់ជននេះមុនពេលដែលគេចាប់ខ្លួន និងអំឡុងពេលស៊ើបអង្កេត និងសវនាការ។ បន្ទាប់ពីជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ជននេះមិនជ្រើសរើសប្រគល់ខ្លួនជូនអាជ្ញាធរនោះទេ ប៉ុន្តែគាត់បែរជាមិនធ្វើដូច្នេះ ចាប់ពីឆ្នាំ១៩៧៩ ដល់ពេលគេរកឃើញគាត់ និងចាប់ខ្លួននៅឆ្នាំ១៩៩៩។ រយៈពេលម្ភៃឆ្នាំ គាត់រស់នៅគេចខ្លួន រយៈពេលដប់ប្រាំឆ្នាំគាត់រស់នៅជាមួយនឹងអតីតមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជា។ ជនជាប់ចោទហើយនិងបុគ្គលកម្មាភិបាលធ្វើការជាមួយគាត់ បាននិយាយថា នៅទសវត្សន៍ទី៩០ ជនជាប់ចោទលាក់បាំងអតីតកាលរបស់គាត់ មិនមានលាតត្រដាងឈ្មោះ ហើយលាក់តួនាទីរបស់គាត់ជាមេទារុណកម្ម និងមេពេជ្ឈឃាដនៅស-២១។ ហើយគាត់បានផ្លាស់ប្ដូរឈ្មោះគាត់ជាញឹកញយ ដើម្បីកុំឲ្យអ្នកសារព័ត៌មានរកគាត់ឃើញ។ ចំណុចនេះ គឺវាប៉ះពាល់ គាត់ថាវាប៉ះពាល់ទៅនឹងសេរីភាពរបស់គាត់។ អ្នកកាសែត នីក ដងឡុប បានរកឃើញជននេះនៅឆ្នាំ១៩៩៩ ហើយចុងក្រោយមកមានការចាប់ខ្លួនជនរូបនេះ។

ក្រោយពីជនជាប់ចោទប្រឈមមុខនឹង នីក ដងឡុប ទៀតទេ ដែលគាត់ផ្ដល់ព័ត៌មាន ភ័ស្ដុតាងថា គាត់ចូលរួមសកម្មភាពនៅស-២១។ ហើយជនជាប់ចោទមិនបានបង្ហាញទៅលើចំណុចនេះឲ្យបានច្បាស់លាស់ ហើយជនជាប់ចោទថា កុំតែ នីក ដងឡុប គាត់មិនត្រូវបានគេយកមកជំនុំជម្រះនោះទេ។ យើងឃើញថា ឯកសារដែលមានបញ្ជាក់ឲ្យ នីក ដងឡុប មាននៅថ្ងៃទី០៣ ខែកញ្ញា ទំព័រ ៥៥ ដល់៥៦ ជាច្រើនឆ្នាំមក ក្រោយពីការចាប់ខ្លួនរបស់ជនជាប់ចោទ វាបង្ហាញថា ជនជាប់ចោទខឹងនឹង នីក ដងឡុប។ ខណៈពេលដែលជនជាប់ចោទជាប់ឃុំ នីក ដងឡុប បានកត់ត្រាក្នុងសៀវភៅរបស់តាមរយៈ

សួរទៅកាន់មេធាវី ការ សាវុត្ថ ដែលជាមេធាវីជនជាប់ចោទ។

លោក ការ សាវុត្ថ បានរៀបរាប់ប្រាប់លោក នីក ដងឡុប ថា ជនជាប់ចោទមានការខឹងនឹងលោក នីក ដងឡុប ដោយសារតែលោក នីក ដងឡុប នេះហើយដែលធ្វើឲ្យជនជាប់ចោទជាប់ឃុំ។

[០៩:៤៥:១៣]

លោក លោកស្រី ចៅក្រម, នៅពេលដែលជាប់ឃុំ ហើយបន្ទាប់ពីគាត់បានប្រឹក្សាផ្នែកច្បាប់ ទើបជនជាប់ចោទបានទទួលស្គាល់ថា គាត់ទទួលខុសត្រូវដោយផ្ទាល់ទៅលើឧក្រិដ្ឋកម្មនៅស-២១ ប៉ុន្តែគាត់ ហើយគាត់ថា គាត់មិនអាចទម្លាក់កំហុសទៅលើគោលនយោបាយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចំពោះអំពើរបស់គាត់នោះទេ។ ជនរូបនេះបានផ្តល់ភ័ស្តុតាងទៅដល់សហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញាអំពីការងារផ្ទៃក្នុងរបស់ស-២១ រចនាសម្ព័ន្ធ គោលនយោបាយរបស់នេះ និងការអនុវត្តគោលនយោបាយក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ហើយជនរូបនេះក៏ផ្តល់ព័ត៌មានផងដែរ និងភ័ស្តុតាងផងដែរ យើងគិតថា វាមានសារសំខាន់ក្នុងការរៀបចំការចោទប្រកាន់ទៅលើមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ ហើយយើងសូមអរគុណទៅលើចំណុចនេះ គាត់ទទួលបានផលប្រយោជន៍ទៅលើចំណុចនេះ។ ប៉ុន្តែ ចំពោះការទទួលខុសត្រូវរបស់គាត់វិញ គាត់បានទទួលស្គាល់ទៅលើចំណុចនេះតែផ្នែកតូចតែប៉ុណ្ណោះ។ ទោះបីជាគាត់ទទួលស្គាល់ការទទួលខុសត្រូវជាទូទៅក៏ដោយ គាត់បានប្រាប់តុលាការថា គាត់ធ្វើរឿងអាក្រក់ជាច្រើន ប៉ុន្តែមិនមែនជាកំហុសរបស់គាត់ទេ គឺជាកំហុសរបស់ថ្នាក់លើរបស់គាត់។ ដូច្នេះ យើងក៏នឹកឃើញផងដែរថា គាត់ទទួលស្គាល់តែឧក្រិដ្ឋកម្មណាដែលវាបានបង្ហាញតាមរយៈភ័ស្តុតាងតែប៉ុណ្ណោះ គាត់មិនទទួលស្គាល់ទៅលើឧក្រិដ្ឋកម្មផ្សេងៗទៀតឡើយ។

ការមិនមានការសហការរបស់ជនជាប់ចោទជាមួយនឹងតុលាការ ហើយសម្រេចទទួលស្គាល់ចំពោះការទទួលខុសត្រូវក្នុងលក្ខណៈកម្រិតរបស់គាត់ ដើម្បីបន្ថយទោសនោះ គឺបង្ហាញថា វាជាយុទ្ធ-សាស្ត្រការពារខ្លួននៅពេលសវនាការ។ មេធាវីការពារក្តីបានព្យាយាមធ្វើការកម្រិតទំហំនៃភ័ស្តុតាង ហើយនិងធ្វើការកម្រិតលទ្ធភាពរបស់អង្គជំនុំជម្រះ ក្នុងការពិចារណាទៅលើអង្គហេតុដែលពាក់ព័ន្ធ។

យើងឃើញថា មេធាវីការពារក្តីធ្វើចំណុចនេះតាមការតតាំងទៅលើបញ្ហាច្បាប់។ ហើយវាបង្ហាញយ៉ាងច្បាស់ថា មេធាវីការពារក្តីធ្វើយ៉ាងនេះ ដើម្បីបន្ថយអំពីឥទ្ធិពលនៃការប៉ះពាល់ចំពោះឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ហើយខ្ញុំនឹងបង្ហាញចំណុចនេះថា វាជាយុទ្ធសាស្ត្រការពារ។

[០៩:៤៧:៣៩]

ដំបូងនៅពេលចាប់ផ្ដើមការជំនុំជម្រះលើរឿងក្ដីនេះ មេធាវីការពារក្ដីស្នើសុំឱ្យលោក លោកស្រីចៅក្រម យល់ឃើញថា មានភស្តុតាងតិចតួចតែប៉ុណ្ណោះក្នុងការកាត់ទោសទៅលើជនរូបនេះ នៅពេលដែលមេធាវីការពារក្ដីតវ៉ាថា ធាតុផ្សំយុត្តាធិការ គឺមិនមានឡើយ។ ហើយម្យ៉ាងវិញទៀត មេធាវីការពារក្ដីលើកឡើងថា ជនជាប់ចោទសហការជាមួយនឹងតុលាការយ៉ាងពិតប្រាកដ។ ហើយមេធាវីការពារក្ដីព្យាយាមធ្វើឱ្យរឿងក្ដីនេះ មិនមានអនុភាពចំពោះ ដាក់បន្ទុកទៅលើជនជាប់ចោទ។

ទីពីរ មេធាវីការពារក្ដីជំទាស់ថា ជនជាប់ចោទមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់ ឬក៏អ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបនេះទេ។ ទីពីរ មេធាវីការពារក្ដីជំទាស់ទៅលើការទទួលយកភស្តុតាងទាំងឡាយទាក់ទងទៅនឹងអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ បួនឆ្នាំនៅមន្ទីរម-១៣ ដែលចំណុចនេះ គឺជាការព្យាយាមក្នុងការបន្ថយលទ្ធភាពរបស់សាលាដំបូងក្នុងការសម្រេច និងពិចារណាទៅលើហេតុផល និងគោលបំណងនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅស-២១។

នៅពេលដែលមេធាវីការពារក្ដីព្យាយាមកម្រិតភស្តុតាងនេះ វាធ្វើឱ្យលោកចៅក្រមមានការពិបាកក្នុងការសម្រេច និងដោះស្រាយទៅលើរឿងក្ដីនេះ ដែលវាទាក់ទងទៅនឹងឆន្ទៈរបស់ជនជាប់ចោទនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅស-២១។ ដូច្នេះហើយយើងឃើញថាជនជាប់ចោទ គឺជាអ្នកធ្វើទារុណកម្ម និងអ្នកសម្លាប់មុនពេលមកដល់ស-២១ ទៅទៀត។ ប៉ុន្តែ មេធាវីការពារក្ដីបានព្យាយាមឱ្យលោក លោកស្រីចៅក្រម ស្ដាប់សាក្សីអត្តចរិតនៅដើមដំបូងដែលគាត់ជាគ្រូនិងជាសិស្ស។

ទីបី ការជំទាស់របស់មេធាវីការពារក្ដី ក្នុងការដាក់ឯកសារសង្ខេបទៅលើសាក្សី ជាពិសេសទៅលើសក្ខីកម្មសម្រាប់អង្គជំនុំជម្រះនោះ គឺមេធាវីចង់កុំមានផលប៉ះពាល់ទៅលើជនជាប់ចោទចំពោះតួនាទីនិងឧក្រិដ្ឋកម្មរបស់ជននេះ។ ដូច្នេះយើងឃើញថា ឯកសាររបស់សហព្រះរាជអាជ្ញា គឺគ្រាន់តែចង់ផ្ដល់ព័ត៌មានសង្ខេបទៅលើភស្តុតាង ជាពិសេសទាក់ទងទៅនឹងសាក្សីដែលវាជាការអនុវត្តសាមញ្ញនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដូច្នេះយើងឃើញថា ការដែលសហព្រះរាជអាជ្ញាចង់ធ្វើដូច្នេះ ដើម្បីចង់ឱ្យអង្គជំនុំជម្រះអាចផ្ដោតទៅលើអង្គហេតុសំខាន់ ហើយមិនធ្វើការវង្វេងទៅលើការពិចារណាភស្តុតាង។

ជាការពិត យើងខ្ញុំគ្រាន់តែចង់ឱ្យអង្គជំនុំជម្រះយល់ទៅលើអង្គហេតុច្បាស់លាស់តែប៉ុណ្ណោះ។ គោលបំណងនៃការជំទាស់របស់មេធាវីការពារក្ដី គឺបង្ហាញយ៉ាងច្បាស់ថា ធ្វើយ៉ាងណាកុំឱ្យអង្គជំនុំជម្រះយល់ច្បាស់ទៅលើរឿងក្ដីនេះ និងតួនាទីរបស់ជនជាប់ចោទ។

[០៩:៥០:៤៩]

ទីបួន មេធាវីការពារក្តីព្យាយាមរារាំងលំហូរនៃភ័ស្តុតាងដាក់ជូនអង្គសវនាការ ដោយជំទាស់ទៅលើបញ្ជីសាក្សីបម្រុងដែលយើងបានស្នើ ហើយការធ្វើដូច្នេះ គឺយើងគ្រាន់តែធ្វើយ៉ាងណាព្យាយាមដើម្បីមានសាក្សីបម្រុងនៅពេលដែលសាក្សីណាគាត់បាត់បង់ការចងចាំ និងមិនបានប្រាប់ការពិត។ ដូច្នេះ ដោយសារតែចំណុចទាំងអស់នេះ យើងគិតថា វាជាចំណុចមួយដែលមានប្រយោជន៍។ នៅក្នុងរឿងក្តីនេះ យើងឃើញថា វាមានគ្រោះថ្នាក់នៅពេលដែលយើងពិចារណាថា សាក្សីជាច្រើន ដែលរស់រានមានជីវិតនោះ គឺជាអតីតបុគ្គលិកស-២១។ យើងនិយាយឲ្យងាយស្រួល វាអាចមានហេតុផលថា សាក្សីទាំងអស់នេះ គាត់អាចមិនផ្តល់សក្ខីកម្មដោយសារតែគាត់មានអារម្មណ៍អៀនខ្មាសទៅនឹងពិរុទ្ធភាពផ្ទាល់របស់គាត់ និងមានអារម្មណ៍អៀនខ្មាសទៅនឹងការចូលរួមនៅក្នុងឧក្រិដ្ឋកម្មស-២១។ ហើយចំណុចនេះវាបង្ហាញដូច្នោះមែន។ នៅពេលដែលសាក្សីបន្តមកផ្តល់សក្ខីកម្ម វាបង្ហាញយ៉ាងច្បាស់ថា សាក្សីមានការស្ទាក់ស្ទើរក្នុងការនិយាយដោយសេរី ជាពិសេសក្នុងសវនាការសាធារណៈ និងនៅពេលដែលមានវត្តមានអតីតមេរបស់ខ្លួន។ ប៉ុន្តែ អ្វីដែលល្អនោះ គឺពួកគេបានផ្តល់សក្ខីកម្មមុនរួចមកហើយនៅក្នុងដំណើរការស៊ើបសួរ ដែលវាជាការអូសទាញពួកគេឲ្យនិយាយកាន់តែការពិតទៅលើហេតុការណ៍ទាំងអស់នោះ។

ចំណុចទីប្រាំ ហើយវាជាអកុសលចំពោះរឿងក្តីនេះ មេធាវីការពារព្យាយាមធ្វើការយកតួនាទីរបស់តុលាការធ្វើការណែនាំទៅដល់សាក្សីទីមួយនៅមន្ទីរស-២១ ដែលជាអ្នកសួរចម្លើយថា ប្រសិនបើគាត់និយាយនោះ គឺគាត់អាចទទួលរងការចោទប្រកាន់នៅតុលាការជាតិ។ ទោះបីជាអង្គហេតុទាំងអស់នេះ វាមានលក្ខណៈដាច់ឆ្ងាយក៏ដោយ ការលើកឡើងអំពីការភិតភ័យដោយមេធាវីការពារក្តីដូចដែលគាត់បានធ្វើឡើងនោះ វាធ្វើឲ្យសាក្សីដំបូងដែលជាបុគ្គលិកស-២១ ហើយវាបានបញ្ជូនសារទៅដល់សាក្សីផ្សេងទៀត ដែលនៅសល់ថា គាត់នឹងប្រឈមនឹងគ្រោះថ្នាក់ ប្រសិនបើគាត់មកផ្តល់សក្ខីកម្ម។

ការព្រមានរបស់មេធាវីការពារក្តីហួសពីកាតព្វកិច្ចរបស់គាត់ គឺគាត់ធ្វើដោយសំអាងហេតុយល់ខុសរបស់គាត់។ ហើយក្នុងគោលបំណងធ្វើការបំភិតបំភ័យសាក្សីពីមន្ទីរស-២១ ក្នុងការលាតត្រដាងឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទនៅមន្ទីរស-២១។ ដូច្នេះ យើងគិតថា ចំណុចទាំងអស់នេះវាជាការព្រមានទៅដល់សាក្សី ហើយវាជាការព្រមានពីមេធាវីការពារ មិនជំរុញសាក្សីទាំងអស់នោះនិយាយការពិត។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើល នៅពេលដែលសាក្សី ម៉ម ណៃ មិនបានប្រាប់ការពិតមេធាវីការពារក្តីមានការពេញចិត្តអំពីការមិនប្រាប់ការពិតរបស់សាក្សី ម៉ម ណៃ។ នេះគឺជាសម្តីរបស់មេធាវីការពារក្តី ក្រោយពីគាត់ផ្តល់សក្ខីកម្ម។

[០៩:៥៤:០៤]

“លោកសហព្រះរាជអាជ្ញា ខ្ញុំសូមអរគុណលោក ប្រសិនបើលោកមានសាក្សីបែបនេះកុំស្ទាក់ស្ទើរអីហៅពួកគេមកទៀត”។ ការលើកឡើងរបស់មេធាវីការពារក្តីនេះ មានការការគួរឲ្យរំខានណាស់ ដោយយើងដឹងហើយថា ម៉ម ណៃ គឺជាសាក្សីដែលមេធាវីការពារក្តីបានព្រមាននៅពេលដែលគាត់មកផ្តល់សក្ខីកម្ម។ ជនជាប់ចោទ និងមេធាវីការពារក្តីអាចលើកឡើងជូនសវនាការថា ពួកគេសហការហើយបានទទួលស្គាល់ការទទួលខុសត្រូវពេញលេញ ហើយបានប្រាប់ការពិតអំពីស-២១ ដើម្បីជួយទៅដល់ប្រទេសនេះ។ ជាពិសេសការផ្សះផ្សាជាតិ ប៉ុន្តែវាពិបាកណាស់ ដោយសារតែវាហាក់ដូចជាមិនមានការប្រាប់ទៅលើការពិតទេ តាមរយៈការបំភិតបំភ័យសាក្សី។

ចំណុចចុងក្រោយ មេធាវីការពារក្តីព្យាយាមកម្រិតទៅលើភ័ស្តុតាង ដែលភ័ស្តុតាងទាំងអស់នោះជាការជួយជ្រោមជ្រែងទៅដល់អង្គសវនាការ។ ឧទាហរណ៍ ឯកសារដែលគាំទ្ររបាយការណ៍អ្នកជំនាញក្រេក អេតឆេសាន់ ហើយនិងឯកសារជម្លោះប្រដាប់អាវុធ និងឯកសារចំណារផ្តាល់របស់ជនជាប់ចោទត្រូវបានជំទាស់ដោយមេធាវីការពារក្តី ដែលលើកឡើងថា មិនមានភាពចាំបាច់ ហើយជាន់គ្នាដដែលៗ។ វាធ្វើឲ្យយើងចំណាយពេលច្រើន ហើយជាទឡ្ហីករណ៍មិនចាំបាច់នៅចំពោះមុខអង្គសវនាការទាក់ទងករណីដែលមេធាវីថា ភ័ស្តុតាងមិនពាក់ព័ន្ធ។

ដូច្នេះ លោក លោកស្រី ចៅក្រម ខ្ញុំសូមសង្ខេបថា ថាតើអនុភាពនៃការសហការរបស់ជនជាប់ចោទជាមួយតុលាការ គឺយ៉ាងម៉េច? យើងអាចពិនិត្យពិចារណាទៅលើចំណុចពីរ៖

ទីមួយ ជនជាប់ចោទបានសហការដោយផ្តល់ភ័ស្តុតាងទាក់ទងទៅនឹងអង្គហេតុ ដែលយើងអាចយល់ពីរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិតេយ្យ គោលនយោបាយឧក្រិដ្ឋ រចនាសម្ព័ន្ធ និងការទំនាក់ទំនងផ្សេងៗ។ ហើយគាត់ក៏បានផ្តល់ព័ត៌មានដទៃទៀតដែលមានតម្លៃ ហើយវាជួយទៅដល់សហព្រះរាជអាជ្ញាក្នុងការស្វែងរកជនសង្ស័យ។ ដូច្នេះគាត់បានផ្តល់ចម្លើយ ដែលមានតម្លៃសម្រាប់ខាងសហព្រះរាជអាជ្ញា។

ចំណុចមួយទៀត គាត់មិនមានការសហការពេញលេញ និងមានភាពស្មោះអំពីតួនាទីរបស់គាត់នៅស-២១ នោះទេ។ គាត់ព្យាយាមការបង្វែរការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មទៅកន្លែងផ្សេង។ យើងឃើញថា គាត់មិនផ្តល់សក្ខីកម្មដោយស្មោះត្រង់ទេ។ នៅពេលគាត់ផ្តល់សក្ខីកម្មស្មោះត្រង់ គឺនៅពេលដែលគាត់ពិបាកក្នុងការចៀសផុតពីការភរកុហកដែលវាមិនអាច ហើយគាត់មិនបានដឹងថា វា

ជាយន្តការនៃការការពារខ្លួន។

[០៩:៥៦:៤៣]

ដូចនេះ ជនជាប់ចោទហាក់ដូចជាមិនបានសហការពេញលេញតាមរយៈការបន្ថយលំហូរនៃភ័ស្តុតាង និងបញ្ជាក់ច្បាស់ទៅលើភ័ស្តុតាង ដើម្បីឲ្យអង្គសវនាការយល់ច្បាស់ទៅលើភាពធ្ងន់ធ្ងរ និងឥទ្ធិពលនៃឧក្រិដ្ឋកម្មទាំងអស់នោះ។ ហើយដូច្នេះ យើងទទួលស្គាល់ថា ការតវ៉ា និងការជំទាស់ គឺជាសិទ្ធិរបស់គាត់ ប៉ុន្តែយ៉ាងណាក៏ដោយ គឺគាត់បានធ្វើការតវ៉ាទៅលើចំណុចទាំងអស់នេះ ហើយបានលើកឡើងថា គាត់សហការ។

ឥឡូវនេះ ខ្ញុំនឹងចូលទៅដល់ស្ថានសម្រាលពីរដែលមានការទាក់ទងគ្នា។

ទីមួយ ការឈានចូលទៅដល់ការសម្តែងការសារភាពពិរុទ្ធភាព ហើយនិងការសម្តែងវិប្បដិសារីរបស់ជនជាប់ចោទ។ ទោះបីជាមិនមានការសម្តែងពីពិរុទ្ធភាពតាមច្បាប់កម្ពុជាក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែពិចារណាលើការកាត់ទោសដ៏សមស្រប។ ការសារភាពទាំងស្រុងពីការទទួលខុសត្រូវ និងការសារភាពពិរុទ្ធភាពឥតលក្ខខណ្ឌអាចមានប្រយោជន៍យ៉ាងពិសេសសម្រាប់ជនរងគ្រោះ ហើយដើរតួយ៉ាងសំខាន់ក្នុងការផ្សះផ្សាជាតិ និងការបង្កើតឯកសារប្រវត្តិសាស្ត្រ។ ខ្ញុំនឹងមិននិយាយឡើងវិញអំពីអង្គហេតុដែលជនជាប់ចោទមិនបាននិយាយស្មោះត្រង់អំពីតួនាទីរបស់គាត់នៅក្នុងការអនុវត្តនៅស-២១ ទេ។ គ្មាននរណាម្នាក់អាចភាន់ច្រឡំជឿជាក់ថា ករណីនេះវាស្មើគ្នាទៅនឹងការសារភាពពិរុទ្ធភាពត្រឹមត្រូវចំពោះមុខតុលាការអន្តរជាតិនោះឡើយ។

យើងសូមរំឭកថា មានការខ្វែងគំនិតសំខាន់ៗរវាងតំណាងអយ្យការ និងមេធាវីការពារ ដែលពាក់ព័ន្ធទៅនឹងការចូលរួមដោយស្ម័គ្រចិត្តយ៉ាងសកម្មនៅក្នុងតួនាទីបទឧក្រិដ្ឋរបស់គាត់។ យើងក៏ទទួលស្គាល់ដែលថា ខណៈពេលដែលដំណើរការកាន់តែវិវឌ្ឍន៍ច្រើនទៅ គាត់កាន់តែសារភាពច្រើន។ ជាពិសេសនៅក្នុងការសួរចម្លើយរបស់សហចៅក្រមស៊ើបអង្កេតនោះដែរ ហើយគាត់មិនបានចូលរួមឲ្យដល់កម្រិតមួយនោះទេ។ ប៉ុន្តែ សូមអង្គជំនុំជម្រះចងចាំថា នៅពេលមានការចុចសួរដេញដោលពីការចូលរួមផ្ទាល់ខ្លួន គាត់បានបន្តការរឹងរូស។ តាមការយល់ដឹងរបស់សហព្រះរាជអាជ្ញា ខ្ញុំសូមយោងទៅដល់ការសួរចម្លើយរបស់ចៅក្រម ខាតវ៉ាយថ៍ អំពីបញ្ហាអត្តចរិតរបស់គាត់ ទោះបីជា ចៅក្រមបានបង្ហាញភ័ស្តុតាងដែលថា អត្តចរិតរបស់គាត់នៅស-២១ លើសពីអ្វីដែលជនធម្មតាអាចនឹងធ្វើទៅបាន។ គាត់មិនដែលបានធ្វើសម្បទានអ្វីមួយ សូម្បីតែមួយក៏មិនបានដែរ ហើយគាត់មិនបាននិយាយដោយស្មោះត្រង់ចំពោះ

អង្គជំនុំជម្រះនោះឡើយ គាត់បានបោះបង់គំនិតនេះចោល។ តើមានអ្វីដែលនៅសេសសល់ ជាពិសេស ជនជាប់ចោទបានអះអាងថា គាត់ត្រូវបានគេបង្ខំឲ្យធ្វើទារុណកម្ម និងសម្លាប់ប្រឆាំងនឹងឆន្ទៈរបស់ខ្លួន។

តាមពិតនៅពេលនេះ គាត់បានសម្រេចយល់ព្រមតាមសំណើរបស់យើងដែលស្នើពីមុន បញ្ជាក់សេចក្តីថ្លែងជាសង្ខេបដែលធ្វើនៅពេលចោទសួរដោយមេធាវី។ ជនជាប់ចោទត្រូវទទួលស្គាល់សច្ចធម៌ដែលបានធ្វើនៅពេលការចោទសួរដោយមេធាវី ជនជាប់ចោទត្រូវទទួលស្គាល់សច្ចធម៌នៅពេលសួរនោះត្រូវទទួលស្គាល់ ហើយការទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួន អង្គជំនុំជម្រះត្រូវវាស់តម្លៃថាតើការទទួលស្គាល់សម្តែងពិរុទ្ធភាពនោះត្រឹមត្រូវដែរឬអត់? ប្រសិនបើការសម្តែងវិប្បដិសារីនោះវាមានការកម្រិតជាការបដិសេធនូវការទទួលខុសត្រូវដែលខ្ញុំបានលើកខាងដើមនោះ។ ភ័ស្តុតាងបានមកពីអ្នកចិត្តសាស្ត្របញ្ជាក់ថា ជនជាប់ចោទមិនមានអារម្មណ៍សម្តែងការអាណិតអាសូរ ប៉ុន្តែអ្នកចិត្តសាស្ត្របាននិយាយដែរថា គាត់ជាអ្នកនិយមសាច់ការ។ ភ័ស្តុតាងនេះបង្ហាញថាគាត់បានប្តូរទៅយកសាសនាគ្រិស្ទៀន ប៉ុន្តែគាត់ប្រកាន់ទស្សនៈថា កុម្មុយនីស្តប្រើកម្លាំងច្រើនពេក។ ក្នុងកម្រិតដែលជនជាប់ចោទបានសម្តែងការសារភាពរបស់ខ្លួនចំពោះអង្គជំនុំជម្រះនេះប៉ុន្តែក្នុងបរិបទក្នុងការមិនព្រមទទួលការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ហើយនិងការកម្រិតក្នុងការបញ្ជាក់អំពីអ្វីដែលថា ការពិចារណានោះត្រូវលើកឡើងនោះ។

[១០:០១:៣៤]

នៅទីបំផុត មេធាវីការពារបានអះអាងថា ការសហការរបស់ជនជាប់ចោទ និងវិប្បដិសារីរបស់គាត់នឹងក្លាយទៅជាវិភាគទានដល់ការផ្សះផ្សាជាតិ ហើយថាការធ្វើបែបនេះនឹងសម្រេចបានដាក់កម្រិតទោសរបស់ជនជាប់ចោទ។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញា ទោះបីជាការផ្សះផ្សាជាតិ គឺជាការពិចារណាធម្មានុរូបសម្រាប់អង្គជំនុំជម្រះក៏ដោយ ក៏អាកប្បកិរិយារបស់ជនជាប់ចោទមិនបានបំពេញបន្ថែមជាដុំកំភួននោះទេ ក្នុងគោលបំណងចម្បងមួយដែលថាអាចនឹងស្វែងរកការពិត ការដាក់ទោសត្រឹមត្រូវសមស្របបញ្ចប់និទ្ទណ្ឌភាព ដំណើរការនោះនឹងចូលរួមដល់ការផ្សះផ្សាជាតិ ហើយយើងទទួលស្គាល់ថា ការកាត់បន្ថយទោសកម្រិតមួយវាមិនរារាំង ពោលគឺជួយឲ្យសម្រេចបាននូវការផ្សះផ្សាជាតិនោះទេ។ ជាដំបូងយើងទទួលស្គាល់ថា គឺជាផលផ្លែផ្កានៃការជំនុំជម្រះទេ ការផ្សះផ្សាជាតិនោះ។ គឺជាកន្លែងមួយដែលថា ការដាក់ទោស ហើយនិងទារុណកម្មបើសិនជាមានពិរុទ្ធភាព។ ហើយអ្វីការជ្រើសរើសដែលបានគាត់បន្តរស់នៅជាមួយខ្មែរក្រហមរហូតដល់រយៈពេលច្រើនឆ្នាំមុនពេលចាប់ខ្លួននោះ ការសហការរបស់គាត់ដែលមិនពេញលេញ ការទទួលស្គាល់ហើយនិងសារភាពគឺជាការបញ្ជាក់ថាគាត់មាន

ប្រយោជន៍ក្នុងការបញ្ជាក់អំពីការប្រព្រឹត្តិនូវបទឧក្រិដ្ឋអន្តរជាតិ ហើយមិនបានបង្កើតផលប្រយោជន៍ច្បាស់ក្នុងការបង្កើតសន្តិភាពនៅកម្ពុជានោះទេ។ ជាពិសេសគាត់មិនបានបង្ហាញពីនីតិវិធីដែលសម្រាលទោស និងផលប៉ះពាល់មួយដល់ការផ្សះផ្សាជាតិទេ ឧទាហរណ៍តើនឹងមានការបដិសេធជាសាធារណៈ និងចលនា ភាពចលនាចលដែរឬទេបើសិនជាយើងមានសេចក្តីសម្រេចមួយមិនត្រឹមត្រូវនោះ។

[១០:០៣:៥១]

មនុស្សជាតិត្រូវតែគោរពដោយធ្វើទណ្ឌកម្មមនុស្សមួយរូបនៅក្នុងនោះ ការធ្វើបែបនោះនឹងផ្តល់ជាផលប្រយោជន៍ច្រើនចំពោះមនុស្សលោកទាំងអស់ រួមទាំងជនជាប់ចោទផងដែរ។ ដូច្នេះអង្គជំនុំជម្រះមិនត្រូវយល់ស្របតាមការអះអាងថា ការដាក់ទោសសមស្របទាបនោះជាមធ្យោបាយនៃការផ្សះផ្សាជាតិឡើយ។

ចំណុចមួយទៀត ខ្ញុំចូលទៅនឹងចំណុចមួយដែលជនជាប់ចោទដែលគាត់បានទទួលរងការឃុំខ្លួនមុនពេលការជំនុំជម្រះ។ អង្គជំនុំជម្រះក៏បានសម្រេចរួចហើយថា នៅពេលកាត់ទោសជនជាប់ចោទមានសិទ្ធិសុំដកចេញនូវរយៈពេលដែលគាត់បានជាប់ឃុំមុនពេលឃុំខ្លួននៅអ.វ.ត.ក តាំងពីថ្ងៃ៣១ កក្កដា ឆ្នាំ២០០៧ ហើយនិងរយៈពេលប្រាំបីឆ្នាំ ពីរខែ និងម្ភៃថ្ងៃ ដែលគាត់ត្រូវបានឃុំខ្លួនតាមដីការបស់តុលាការយោធាមុនបញ្ជូនកាត់មកទីនេះ។

ខ្ញុំនិយាយអំពីនីត្យានុកូលភាព លោក លោកស្រីចៅក្រមជនជាប់ចោទមានសិទ្ធិទារសំណងដើម្បីជួសជុលការខូចខាតដែលបង្កឡើងពីការបំពានធ្ងន់ធ្ងរលើសិទ្ធិរបស់គាត់ដោយសារការឃុំខ្លួនផ្ទុយអំពីច្បាប់ជាធរមាននោះ។

ខ្ញុំសូមលើកទៅករណីតុលាការព្រហ្មទណ្ឌអន្តរជាតិ *បារ៉ាយ៉ាហ្គីស្សា*(Barayagwiza) និង *ខាជេលីជេលី (Kajelijeli)* ដែលមានការពាក់ព័ន្ធយ៉ាងច្បាស់នៅក្នុងករណីនេះ ការកាត់បន្ថយទោសនោះគឺថាម្នាក់ៗទទួលបាន៣៥ឆ្នាំ និង៤៥ឆ្នាំទៅតាមករណីនោះ។ សហព្រះរាជអាជ្ញាទទួលស្គាល់ថា ការបំពានសិទ្ធិលើជនជាប់ចោទក្នុងករណីនេះ គឺមានសារសំខាន់ណាស់ គឺធ្ងន់ធ្ងរជាងករណីទាំងពីរនោះ។

រយៈពេលអតិបរិមានៃការឃុំខ្លួនបណ្តោះអាសន្នតាមច្បាប់កម្ពុជា ចំពោះបទល្មើសទាំងឡាយដែលចោទប្រកាន់ជនជាប់ចោទនោះមានរយៈពេលបីឆ្នាំ តែរយៈពេលនេះបានអូសបន្លាយយ៉ាងហោចណាស់ប្រាំឆ្នាំ ពីរខែ ម្ភៃថ្ងៃ នៃការចាប់ខ្លួនដោយតុលាការយោធា គឺរយៈពេលឃុំខ្លួនខុសច្បាប់។ អង្គជំនុំជម្រះបានចង្អុលបង្ហាញពីភាពមិនប្រក្រតីផ្សេងទៀត ក្នុងការឃុំខ្លួនជនជាប់ចោទដោយសារតុលាការយោធា

ដូចជាការខកខានរបស់អាជ្ញាធរក្នុងការអនុវត្តការស៊ើបអង្កេតឲ្យបានល្អិតល្អន់ជាប្រព័ន្ធទៅលើការចោទប្រកាន់ប្រឆាំងរូបគាត់។

នៅទីនេះចំពោះមុខ អ.វ.ត.ក រាល់តុលាការដែលបានបង្កើតត្រឹមត្រូវតាមច្បាប់អន្តរជាតិនោះ នីតិរដ្ឋត្រូវតែមានប្រៀបលើអ្វីៗទាំងអស់ គោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ និងដ៏ត្រឹមត្រូវត្រូវតែបានអនុវត្ត។ ដូច្នេះ កាលណាជនជាប់ចោទមិនត្រូវបាននាំមកជំនុំជម្រះក្នុងអំឡុងពេលសមស្រប ឬត្រូវឃុំខ្លួនបណ្ដោះដោយគ្មានយុត្តិកម្មសមស្របនោះ ការបំពាននេះត្រូវមានការជួសជុលដោយសារតែមានការបំពានសិទ្ធិរបស់ជនជាប់ចោទមានលក្ខណធ្ងន់ធ្ងរពេក។

[១០:០៧:១៨]

ការឆ្លើយតបសមស្រមតែមួយគត់ គឺត្រូវផ្ដល់ការជួសជុលដែលអាចមានបានចំពោះជនជាប់ចោទទៅលើការកាត់ទោសចុងក្រោយ នៅក្នុង-- គឺការកាត់ទោសឲ្យជាប់គុកមួយជីវិត។ ប៉ុន្តែ គោលការណ៍យ៉ាងច្បាស់ដែលបានបង្កើតឡើងដោយយុត្តិសាស្ត្រអន្តរជាតិ តម្រូវឲ្យអង្គជំនុំជម្រះយកចំណុចនេះ ការបំពាននេះមកពិចារណា។ សហព្រះរាជអាជ្ញាលើកឡើងថា ដំណើរការត្រឹមត្រូវរបស់អង្គជំនុំជម្រះនោះត្រូវកាត់បន្ថយទោសពីជាប់គុកមួយជីវិតទៅត្រឹមកម្រិតឆ្នាំជាប់ពន្ធនាគារជាក់លាក់មួយ។ ការកាត់បន្ថយនេះត្រូវតែចែងបញ្ជាក់ទៅតាមការជួសជុលសមស្របទៅលើសិទ្ធិរបស់ជនជាប់ចោទ។

ចំណុចនេះនាំឲ្យខ្ញុំឈានទៅដល់សេចក្ដីសន្និដ្ឋាន សូមតុលាការរំឭកឡើងថា វាខុសគ្នាពីអ្វីនៅស-២១ដែលជនជាប់ចោទបានបដិសេធរាល់កម្មេចមនុស្សធម៌ទាំងអស់ គាត់បាន-- តែក្នុងពេលនេះគាត់បានជួបប្រទះយុត្តិធម៌មានតម្លាភាពនៅក្នុងតុលាការនេះ។ គាត់ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំពោះមុខតុលាការ ចំពោះមុខចៅក្រមដែលឯករាជ្យ និងអនាគតិ។ ប្រសិនបើគាត់មានទោសគាត់នឹងត្រូវកាត់ទោសឲ្យទទួលទោសសមស្របទៅតាមបទល្មើសរបស់គាត់ ទោះបីគាត់ស្ថិតនៅក្នុងរបបមួយនៃជនឃោរឃៅនៃមនុស្សជាតិក៏ដោយ គាត់នឹងត្រូវកាត់ទោសចំពោះតែបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្ត។

នៅស-២១ អ្នកទោសមិនដែលបានទទួលការយកចិត្តទុកដាក់បែបនេះទេ។ ពួកគេត្រូវបានចោទប្រកាន់ដោយបំពាន ដោយប្រឆាំងនឹងសិទ្ធិ មិនមានមេធាវីការពារគេ មិនមានឱកាសក្នុងការប្រឈមមុខនឹងអ្នកចោទប្រកាន់ ពួកគេមិនមានលទ្ធភាពប្ដឹងឧទ្ធរណ៍ពីសាលក្រម ហើយនិងការកាត់ទោសរបស់គេទៅតុលាការកំពូលទេ។ ផ្ទុយទៅវិញ ជនជាប់ចោទបានទទួលការយកចិត្តទុកដាក់យ៉ាងល្អ តែកាលនោះគាត់បានចាត់ទុកគេជាសត្វ។ ចំពោះជនជាប់ចោទគេចាត់ទុកថាជាខ្មាំងគឺជាសត្វដោយមិនមានក្ដីមេត្តា

នោះឡើយ។ តាមពិតលោក លោកស្រីចៅក្រមគ្មានអ្វីអាចផ្តល់យុត្តិកម្មសម្រាប់អំពើឃោរឃៅ និង អមនុស្សធម៌នៅស-២១ ទេ។ ប៉ុន្តែ ជនជាប់ចោទជឿជាក់យ៉ាងច្បាស់ថា ពីអ្វីដែលយើងមិនអាចស្មាន ដល់ថាជនរងគ្រោះមិនមែនមានយុត្តិកម្មទេ ប៉ុន្តែជាការចាំបាច់។ គ្មានអ្វីធ្វើឲ្យប៉ះពាល់សម្បជញ្ញៈរបស់ គាត់ក្នុងការរៀបចំចងក្រងដោយយកចិត្តទុកដាក់ បង្កើតម៉ាស៊ីនកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ដ៏មានប្រសិទ្ធភាព។

[១០:១០:២០]

ដូចដែលយើងបានចង្អុលបង្ហាញ ការងាររបស់គាត់គឺមិនមចេះចាប់ចេះហើយក្នុងការកំណត់ចាប់ ខ្លួន កម្ទេច និងខ្មាំងដែលគេយល់ថាមិនល្អ ហើយគាត់ក៏បានបង្កើតនូវប្រសិទ្ធភាព ហើយរីកសាយទូទាំង ស-២១ និងកម្ពុជា។ ជនជាប់ចោទបានសម្តែងការសុំទោសដដែលៗ ហើយទឹកភ្នែករបស់គាត់នៅជើង ឯកបង្ហាញថា គាត់ប៉ះពាល់អារម្មណ៍អំពីការឃើញអដ្ឋិធាតុ និងលលាដ៍ក្បាលជាច្រើននៅទីនោះ។ ប៉ុន្តែ នៅទីនេះ គាត់បានសម្តែងវិប្បដិសារី ប៉ុន្តែនៅតែបន្តការបដិសេធយ៉ាងសកម្ម ហើយមិនព្រមទទួលថា ខ្លួនបានចូលរួមបទឧក្រិដ្ឋហ្នឹងដោយពេញចិត្តទេ។ ច្បាស់ណាស់នៅទីនេះ លោក លោកស្រីចៅក្រម, ការបដិសេធពីមូលដ្ឋាននៃបទឧក្រិដ្ឋនៅស-២១ ទោះបីជាមានភស្តុតាងជាក់ស្តែងនៅតុលាការក៏ដោយ ប៉ុន្តែទោះជាយ៉ាងណាក្តី គាត់បានទទួលខុសត្រូវតែក្នុងករណីតែការលក្ខខណ្ឌរបស់គាត់ ប៉ុន្តែគាត់បាន ព្យាយាមគូររូបដោយខ្លួនគាត់ថា គាត់ជាអ្នកចូលរួមដោយមិនមានចេតនា គាត់បានស្ថិតនៅក្នុងម៉ាស៊ីន មួយហើយមិនអាចដកខ្លួនបានទេ រស់ក្នុងភាពភ័យខ្លាច។

លោក លោកស្រីចៅក្រម, មិនត្រូវឲ្យគាត់លាក់កំបាំងនៅខាងក្រោយការអះអាងក្លែងបន្លំនេះទេ តុលាការត្រូវតែរំឭកថា នោះគឺជាគាត់មិនមែនគឺជារងគ្រោះនៃប្រព័ន្ធនោះទេ ប៉ុន្តែគាត់មានភាពស្មោះ ត្រង់ ហើយលះបង់ដើម្បីរបបនោះ។ សូមអនុញ្ញាតឲ្យខ្ញុំដកស្រង់អំពីសេចក្តីយោងមួយដែលថា ជាបញ្ហា ទ្វេគ្រោះមួយចំពោះកិត្តិយសរបស់មនុស្សលោក ដែលប្រឈមមុខទៅនឹងជនជាប់ចោទ ហើយយើង និយាយអំពីលោក *វីល្លៀម សក្រូស្ស (William Shawcross)* ដែលជាសហព្រះរាជអាជ្ញាដឹកនាំនៅ តុលាការនូរឹមប៊ឺក ជាបទឧក្រិដ្ឋសង្គ្រាមនោះ ប្រសិនបើគាត់-- បើដល់ចំណុចមួយដែលគាត់ជាបុរស ដែលត្រូវបដិសេធមិនឆ្លើយនោះមេដឹកនាំរបស់គាត់-- ឆ្លើយទៅនឹងមេដឹកនាំរបស់គាត់ គាត់ក៏ជាអ្នកត្រូវ ឆ្លើយទៅនឹងសម្បជញ្ញៈរបស់គាត់ដែរ។

លោក លោកស្រីចៅក្រម, នៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះជនជាប់ចោទបានបោះបង់ចោល

នូវសម្បជញ្ញៈ បោះបង់ចោលនូវភារកិច្ចអ្វីៗដែលបានគាត់ចង់បានពីមុន។ គោលបំណងចម្បងនៃការជំនុំជម្រះនេះត្រូវតែពិនិត្យលើការភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ផលប្រយោជន៍សំខាន់នេះ ហើយនឹងត្រូវពិនិត្យមើលអំពីចេតនាភាពពេញចិត្តរបស់គាត់នៅក្នុងការអនុវត្ត ហើយនិងឆ្លុះបញ្ចាំងអំពីសម្បជញ្ញៈរបស់គាត់ ការជ្រើសរើសដោយសេរីរបស់គាត់ក្នុងការបោះបង់ចោលនូវការគោរពមនុស្សជាតិ ជីវិតរបស់មនុស្សដោយប្រើអំណាចបំពាន ហើយនិងសម្បជញ្ញៈបំពាន។

[១០:១៣:៣៨]

នៅក្នុងករណីធម្មតា ក្នុងករណីនៃការកាត់ទោសមានតែការដាក់ទោសពន្ធនាគារមួយជីវិតទេទើបសមស្រប។ នៅក្នុងករណីនេះកត្តាជាក់លាក់មួយចំនួនធានាថាឲ្យមានការកាត់បន្ថយទោសពន្ធនាគារទៅកម្រិតទោសជាប់ពន្ធនាគារត្រឹមកម្រិតឆ្នាំជាក់លាក់មួយ។ ជាបឋម យើងស្នើថាការបន្ថយទោសពីជាប់គុកមួយជីវិតមក៤៥ឆ្នាំ អាចជាកត្តាដែលជាក់លាក់សមស្រប អាចវាស់វែងបានចំពោះជនជាប់ចោទ។ ទីពីរ យើងស្នើថា ការកាត់បន្ថយប្រាំឆ្នាំទៀតនឹងត្រូវផ្តល់ជូនទៅគាត់ចំពោះការសហការជាទូទៅ ហើយនិងការទទួលស្គាល់ការទទួលខុសត្រូវ ហើយនិងការផ្តល់វិប្បដិសារីដោយមានលក្ខខណ្ឌ ហើយនិងអាចនឹងជាអំណោយផលដល់ការផ្សះផ្សាជាតិ យើងទទួលស្គាល់ថាការកាត់ទោសគប្បីតែដាក់ទោសជាប់ពន្ធនាគារ៤០ឆ្នាំ។

លោក លោកស្រីចៅក្រម, យើងស្នើឲ្យលោក លោកស្រីចាំអំពីរឿងរ៉ាវអំពីជនរងគ្រោះរាប់ពាន់ដែលរងគ្រោះនៅស-២១ តុលាការត្រូវតែពិចារណាអំពីសេចក្តីប្រាថ្នារបស់អ្នកទាំងអស់នោះ ហើយត្រូវតែចងចាំថាស-២១ មានអំពើឃោរឃៅមិនចេះចប់មិនចេះហើយ គ្មានក្តីមេត្តាចំពោះកុមារ ហើយនិងជនរងគ្រោះដែលគ្មានការការពារខ្លួនសោះ នៅទីបំផុត ហើយនិងចងចាំអំពីការបាត់បង់សមាជិកក្រុមគ្រួសារនៃជនរងគ្រោះទាំងអស់នោះត្រូវមានការឈឺចាប់រហូតមកដល់ថ្ងៃនេះមិនត្រឹមតែជនរងគ្រោះនិងក្រុមគ្រួសាររបស់គេទេ ប៉ុន្តែមនុស្សលោកទាំងមូលត្រូវការការឆ្លើយតបដ៏យុត្តិធម៌សមស្របទៅនឹងបញ្ហានេះ តុលាការនេះត្រូវតែនិយាយក្នុងនាមមនុស្សលោកទាំងនោះ។ តុលាការត្រូវតែដាក់ទោសជនជាប់ចោទឲ្យយុត្តិធម៌ ឆ្លើយតបទៅតាមបទល្មើសរបស់គាត់។ ហើយបទឧក្រិដ្ឋបែបនេះមិនត្រូវកើតឡើងម្តងទៀតទេ។ ពលរដ្ឋកម្ពុជាទាំងអស់ដែលបានចូលមកក្នុងតុលាការនេះមកពីទីក្រុងភូមិជនបទទូទាំងប្រទេស អ្នកខ្លះបានមកពីបរទេសហើយរាប់លានទៀតបានមើលយ៉ាងយកចិត្តទុកដាក់តាមទូរទស្សន៍។ ពួកគេបាន

រង់ចាំនៅយុត្តិធម៌ដែលប្រាប់យើងអំពីថាយុត្តិធម៌មនុស្សលោកត្រូវតែការពារ។ ពួកគេរង់ចាំឲ្យយុត្តិធម៌ប្រាប់គេ ហើយប្រាប់អ្នកទាំងអស់នេះពីចម្ងាយ ឬក៏វិញ្ញាណក្ខន្ធអ្នករងគ្រោះនៅស-២១ យុត្តិធម៌ត្រូវបានរកឲ្យឃើញក្នុងនាមពួកគេម្នាក់ៗ។

លោកប្រធាន លោក លោកស្រីចៅក្រម, សូមឲ្យសាលក្រមរបស់លោកនិយាយអំពីយុត្តិធម៌ ហើយនិយាយអំពីពិរុទ្ធភាព ហើយនិងកំណត់ការកាត់ទោសដែលវាឆ្លុះបញ្ចាំងអំពីការទទួលខុសត្រូវព្រហ្ម-ទណ្ឌចំពោះបទឧក្រិដ្ឋជាងមួយម៉ឺនពីរពាន់។ ហើយដាក់ទោសនេះឲ្យសមស្រប ហើយយើងមិនអាចដកមនុស្សធម៌ចេញពីជនជាប់ចោទទេ ប៉ុន្តែប្រគល់ទៅឲ្យគាត់វិញ ហើយប្រគល់ទៅឲ្យជនរងគ្រោះនៅស-២១។ ចំណុចនេះខ្ញុំឈានទៅដល់សេចក្តីបញ្ចប់នៃសន្និដ្ឋានរបស់តំណាងអយ្យការសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ដោយកិច្ចបន្តត្រូវភាគីខាងជនជាប់ចោទ និងមេធាវីរបស់គាត់ឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នៅកិច្ចពិភាក្សាដេញដោល ហើយពេលវេលាក៏ដូចជាដល់ពេលត្រូវឈប់សម្រាកផង ដើម្បីចៀសវាងនូវការដែលគាត់ឡើងថ្លែងទៅមានការឈប់ពាក់កណ្តាលទី ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចថាសម្រាកត្រឹមនេះ គឺសម្រាកប្រកាសសម្រាករយៈពេលម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨នាទី ដល់ម៉ោង ១០:៤០នាទី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះ នឹងផ្តល់វេទិកាទៅមេធាវីការពារក្តី និងជនជាប់ចោទឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយអង្គជំនុំជម្រះសូមជម្រាបរំឭកដល់ជនជាប់ចោទ និងមេធាវីការពារក្តីថា ពេលវេលាដែលបម្រុងទុកសម្រាប់ធ្វើសេចក្តីសន្និដ្ឋាននេះ សរុបទាំងជនជាប់

ចោទ ទាំងមេធាវីការពារក្តីចំនួនប្រាំពីរម៉ោងកន្លះ។ ហើយអង្គជំនុំជម្រះក៏ចង់ដឹងដែរថាតើជាការចាប់ផ្តើមនេះ តើមេធាវីការពារក្តីធ្វើសេចក្តីថ្លែងការណ៍សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលមុន ឬក៏ប្រគល់ទៅជនជាប់ចោទដើម្បីនិយាយមុន?

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន, សូមលោកប្រធានអនុញ្ញាតឲ្យជនជាប់ចោទធ្វើសេចក្តីថ្លែងការណ៍មុន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញជនជាប់ចោទ! លោកអាចឈរនិយាយបានទេ។ សូមអញ្ជើញ!

**ជនជាប់ចោទ៖**

សូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំបាទបានមានមតិនៅចុងបញ្ចប់នេះ។ ដំបូងខ្ញុំសូមអានអត្ថបទដែលខ្ញុំបានត្រៀមរៀបចំដូចតទៅ៖

អំពីការកាប់សម្លាប់ដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តជាហូរហែ។ សំណួមពរ លាតត្រដាងទិដ្ឋភាពរួមដើម្បីឲ្យទិដ្ឋភាពរួមនេះវាអំណោយឲ្យការយល់ទិដ្ឋភាពដោយឡែក។ តាមគោលការណ៍ និងដោយឡែកអំណោយគ្នាទៅវិញទៅមក។ ទិដ្ឋភាពរួមជាការសម្លាប់ដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តពេញមួយប្រវត្តិរបស់ខ្លួន។ ទិដ្ឋភាពដោយឡែក គឺឧក្រិដ្ឋកម្មពីថ្ងៃ១៧/៤/៧៥ ដល់ ៦/១/៧៩ ជាពិសេសនៅស-២១។ ការកាប់សម្លាប់មុនដប់១៧/៤/៧៥៖

១) បក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមកាប់សម្លាប់មនុស្សចាប់តាំងពីពេលដែលខ្លួនមានតំបន់រំដោះ

២) ពាក្យស្លោកដែលគេប្រើសម្រាប់បិទបាំងឧក្រដ្ឋកម្មរបស់គេ គឺកម្ទេចចេញដើម្បីការពារកម្លាំងបដិវត្តន៍។

៣) ចំរៀងដែលគេផ្សព្វផ្សាយទូលាយមានមូលដ្ឋានបង្អែកគឺចំរៀងអាគិញចង្រៃ។

**I) មនុស្សដែលចូលមកពីតំបន់ លន់ នល់**

៤) ជំនាន់នោះមនុស្សក្នុងដី លន់ នល់ ឲ្យតែចូលតំបន់រំដោះពិតជាគេចាប់បញ្ជូនទៅមន្ទីរនគរបាល។ គេបញ្ជូនតាមខ្សែសេនាជនដែលប្រចាំការបណ្តាក់គ្នាគ្រប់ភូមិ។

៥) មន្ទីរនគរបាលត្រូវរង់ចាំទទួលមនុស្សយកមកឃុំឃាំង សួរចម្លើយ និងកម្ទេច។ កម្ទេចខ្ទាំងជាគោលការណ៍ដែលបក្សកុម្មុយនីស្តកំណត់។

៦) ទិដ្ឋភាពនៃការកាប់សម្លាប់អត់ជំនុំជម្រះបែបនេះ ខ្ញុំជឿថាកើតមានពាសពេញតំបន់រំដោះ ពីព្រោះខ្ញុំបានដឹងច្បាស់ថា មុនកំណើតម-១៣ មានមន្ទីរនគរបាលផ្សេងទៀតយ៉ាងតិចណាស់ក៏ពីរដែរ។

**II. ប្រជាជនតំបន់រំដោះ**

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធានសូមលោកមេត្តាឲ្យជនជាប់ចោទបន្ថយល្បឿនបន្តិចទាន ព្រោះអ្នកបកប្រែបកមិនទាន់ទេ។

**ជនជាប់ចោទ៖**

ទស្សនាវដ្តី--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ។ ឥឡូវនេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកអង្គុយចុះ ពីព្រោះពិបាកអានទូវឯកសារ។ អនុញ្ញាតឲ្យអង្គុយចុះបានទូវការថ្លែងនេះ។ ហើយទីពីរ សូមចាប់ផ្ដើមចំណុចពីរអំមិញឡើងវិញ ហើយសូមឲ្យមានការយឺតបន្តិចពីព្រោះអ្នកបកប្រែបកប្រែភាសារអត់ទាន់។

**ជនជាប់ចោទ៖**

**II) ប្រជាជនតំបន់រំដោះ**

៧) ដោយឡែកនៅខាងកំពង់ចាម កំពង់ធំ ដោយបានអាន និងវិភាគអត្ថបទក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ ឆមាសទីពីរ ឆ្នាំ១៩៧១ ជាពិសេសអត្ថបទដែលស្ដីអំពីការដកពិសោធន៍ក្នុងការបង្ក្រាបចលនាបះបោរប្រដាប់អាវុធរបស់ យុត ឧត្ដមវង្សរតនា នាំឲ្យខ្ញុំជឿថា មានការកាប់សម្លាប់ប្រជាជនក្នុងតំបន់រំដោះតាំងពីដំបូងមកម្ល៉េះ។ ពួកអ្នកដែលកាន់អាវុធប្រឆាំងនឹងគេ គេប្រើកម្លាំងកងទ័ពតំបន់។ ចំណែកប្រជាជនដែលគេសង្ស័យ គេចាប់បញ្ជូនទៅមន្ទីរនគរបាល។

[១០:៤៧:៣៤]

**III) ប្រជាជនមូលដ្ឋានបង្អែក**

៨) ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ជាមូលដ្ឋានបង្អែក។ ការចាប់ចងកូនស្រុក កូនភូមិអ្នកអមលាំង បានចាប់ផ្ដើមជាខ្សែសង្វាក់យ៉ាងរាលដាលគួរឲ្យរន្ធត់ ក្រោយពេលដែលបេ៥២ ទម្លាក់គ្រាប់បែកលើភូមិ ក្រាំងថ្កូវ ដែលជាទីតាំងមន្ទីរភាគ ពេលនោះមានស្លាប់មនុស្ស។

សូមអនុញ្ញាតរាយការណ៍សភាពការណ៍ជាក់ស្ដែងដូចតទៅ៖

បន្ទាប់ពីទម្លាក់គ្រាប់បែកតែមួយថ្ងៃ អ៊ុង ជឿន ហៅ ម៉ុក បានបញ្ជាឲ្យគេចាប់កូនចៅចិនបីនាក់ដែលគាត់សង្ស័យប្រគល់មកម-១៣(ក)។ ម៉ុក បានបញ្ជាឲ្យ ដូ ដេត ហៅ ស៊ី តាមដានការសួរចម្លើយនេះឲ្យជិតដល់ដើម្បីអាចដោះស្រាយបញ្ហាទាន់ពេលវេលា។

ក្នុងសភាពការណ៍ដែលការសង្ស័យ និងការចាប់ចងកំពុងតែរាលដាលស្រាប់តែមានមនុស្សពីរនាក់បានចូលទៅអមលាំង ក្នុងកាលបរិច្ឆេទផ្សេងគ្នាទៅសុំរស់នៅនៅទីនោះ និងមានពីរនាក់ផ្សេងទៀតដែលជាកូនចៅអ្នកអមលាំងបានរត់ម្នាក់ម្តងមកក្នុង មួយរយៈក្រោយមកទើបត្រឡប់ទៅវិញ។ ទាំងបួននាក់នេះត្រូវបានខាងភូមិភាគចាប់បញ្ជូនមកម-១៣(ក)។ បីនាក់បានឆ្លើយថា គេឲ្យចូលមកបង្កប់។

ដោយឡែកអ្នកទីបួន ដែលជាបុរសវ័យកណ្តាលមានកូនធំពេញក្រមុំទៅហើយ បានពង្រត់ប្រពន្ធមិត្តភក្តិម្នាក់របស់គាត់ចូលមកខដុង្គ។ បុរសនេះបានឆ្លើយថា ស័ក្តិប្រាំ ហង្ស យីន និងស័ក្តិបួនកន្លះ សេរីសយ បានបញ្ចេញកាំភ្លើងប្រមាណពីររយដើមមកទុកក្នុងតំបន់រំដោះរួចទៅហើយ។ ម៉ុក និង ស៊ី ជឿចម្លើយនេះ ព្រោះគេទាំងពីរក្តាប់ប្រវត្តិរូបបុគ្គលនេះបាន គាប់ជួនពេលនោះ ម៉ុក កំពុងតែត្រូវការកាំភ្លើងពង្រីកទ័ព ត្រៀមផែនការវាយភ្នំពេញ។ ម៉ុក បានបញ្ជាឲ្យខ្ញុំខំរកកាំភ្លើងតាមចម្លើយនេះឲ្យមែនទែន។

ខ្ញុំនៅចាំបានថា តាំងពីពេលនោះមក ស៊ី បានតម្រូវឲ្យខ្ញុំឡើងទៅរាយការណ៍ឲ្យគាត់ ឲ្យកាន់តែជាប់លាប់។ ស៊ី បានលើកទិសសួរចម្លើយបុគ្គលខ្លះ និងកំណត់របៀបធ្វើទារុណកម្មខ្លះផង។ ខ្ញុំខំស្ទើរតែគ្មានពេលដេក អស់ប្រាំខែ ឬប្រាំមួយខែ តែរកកាំភ្លើងមិនឃើញ។

៩) ក្នុងមួយរយៈពេលនោះ អាយុជីវិតអ្នកអមលាំង បានស្លាប់បាត់បង់យ៉ាងអាណោចអាធ័មអស់ហាសិបប្លាយនាក់ គឺស្លាប់ដោយសារគេសង្ស័យ និងដោយសារចម្លើយសារភាព។ ក្នុងនេះអ្នកភូមិពាម ដែលជាអតីតទីប្រជុំជនស្រុកថ្កូង កាលជំនាន់សីហានុ នល់ នល់ បានស្លាប់បាត់បង់ជីវិតច្រើនជាងជាងភូមិផ្សេងទៀតដែលនៅជុំវិញ។

[១០:៥១:០៥]

១០) ស៊ី បានហៅប្រជាជនដែលស្លាប់បាត់បង់ទៅនោះថា សក្តិភូមិនាយទុន ភាសានេះជាភាសាប្រមាថកម្មាភិបាលម្នាក់ដែលជាកម្មាភិបាលមធ្យមកូនចៅអ្នកស្រុក អ្នកភូមិ អ្នកមូលដ្ឋានបង្អែកបានបន្ទោសប្រជាជនថាបែកចិត្ត។ គាត់ថា កាលពីឆ្នាំ៧១ ចិត្តយើងនៅមូលគ្នាតែមួយ ចាប់ពី៧២មក ចិត្តយើងបែកគ្នាជាពីរ។

១១)វាយតម្លៃប្រជាជនបែបនេះធ្វើឲ្យខ្ញុំហួសចិត្តឥតឧបមា ខ្ញុំគួររូបកណ្តៀផ្គុំគ្នាឲ្យទៅជាអក្សរ

ខ្មែរថាបក្ស។ គំនូរជាគំនូរចំអកចំពោះផ្តាច់ការងងឹតងងល់របស់ ម៉ុក និង ស៊ី ដែលជាកសិករកម្រិលចែត។

១២) ខ្ញុំតក់ស្លុតនឹងវិនាសកម្មនេះណាស់ តែមិនដឹងធ្វើម៉េច មានតែផ្លូវមួយទេ គឺរៀបចំយុទ្ធវិធីសួរចម្លើយឲ្យបានស្រួលបួល។ ខ្ញុំបាននាំមិត្ត ប៊ុន សួរចម្លើយកម្លោះចាស់ម្នាក់ដែលជាអតីតជាអ្នកយកព័ត៌មានកាសែត សួរបណ្តើរដកពិសោធបណ្តើរចំណាយពេលមួយខែប្លាយ។

១៣) ការខ្នះខ្នែងរបស់ខ្ញុំ សមត្ថភាព ដែលប៊ុន និងខ្ញុំសន្សំបានវាបែរជារុញខ្ញុំទាំងពីរនាក់ឲ្យលង់ទៅក្នុងឧក្រិដ្ឋកម្មកាន់តែជ្រៅ។ គេប្រើយើងខ្ញុំគ្មានស្គាល់យប់ស្គាល់ថ្ងៃទេ តែសំខាន់បំផុតគឺការងារដែលប្រើនេះជាការងារឧក្រិដ្ឋ។

**IV) សម្រិតសម្រាំងផ្ទៃក្នុងបក្ស**

មុន១៧ មេសា ១៩៧៥ ក៏មានការចាប់ចងកម្មាភិបាលបក្សដែរ។

១៤) មាគ៌ាសម្រិតសម្រាំងផ្ទៃក្នុងបក្សដែលខ្ញុំនៅចាំមានពីរគឺ៖ មួយ លក្ខណៈសម្បត្តិដប់យ៉ាងសម្រាប់ជ្រើសរើសកម្មាភិបាល ជាគោលចរិតខាងចាត់តាំង ដែលបម្រើឲ្យការជម្រុះចោល និងតម្លើងបក្ខជន និងកម្មាភិបាលតាមតែបក្សសម្រេច។ អាយុបក្សរបស់បក្ខជនម្នាក់លែងមានលក្ខណៈវិនិច្ឆ័យដូចដែលមានចែងក្នុងលក្ខន្តិកៈបក្សឆ្នាំ ១៩៦០ទៀតហើយ។ ពីរ មាគ៌ាមួយទៀត ដែលគោលចរិតខាងទ្រឹស្តីសម្រាប់បក្សសម្រិតសម្រាំងគឺ មាគ៌ាវណ្ណៈណា កម្មាភិបាលវណ្ណៈនោះ ដែលមានសរសេរចុះក្នុងទស្សនាវដ្តីទង់បដិវត្តន៍ឆ្នាំ១៩៧៣។ ក្រោយពីបានសិក្សាផ្ទាល់លើមាគ៌ាទាំងពីរនេះខ្ញុំព្រួយណាស់ តែកាលនោះនៅសង្ឃឹមថាអាចលេខាបក្ស គេត្រឹមត្រូវ សង្កេតលក្ខន្តិកៈបក្សឆ្នាំ១៩៦០ លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងទស្សនាវដ្តីទង់បដិវត្តន៍ឆ្នាំ១៩៧៣មិនត្រូវបានបង្ហាញទេ។ តែលក្ខណៈសម្បត្តិដប់យ៉ាងមាននៅក្នុងលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ មាត្រា៥ ជំពូក២។

[១០:៥៤:២៨]

១៥) នរណាក៏ដោយឲ្យតែបក្សសម្រេចថាខ្មាំងត្រូវតែកម្ទេច ប្រធានមន្ទីរនគរបាលគ្មានសិទ្ធិតវ៉ាទេ។

សូមរំឭកព្រឹត្តិការណ៍កាលពីឆ្នាំ១៩៧៣ រាយការណ៍ជូន។ ឆ្នាំនោះ មានលេខាវរសេនាតូចបានចោទប្រកាន់អនុលេខារបស់ខ្លួនថា បានបាញ់ខ្លួនពេលកំពុងដេក ឲ្យផ្ទុះមុងនិងអង្រឹង។ ម៉ុក ជឿតាមបុគ្គលដែលរាយការណ៍នេះណាស់។ គាត់បានបញ្ជាឲ្យខ្ញុំលេងឲ្យធ្ងន់ដៃ ទន្ទឹមនេះ ម៉ុក បានអនុញ្ញាតឲ្យ

ខ្ញុំទៅជួបដើមចោទ ឲ្យដើមចោទនិយាយរឿងឲ្យស្តាប់ ទៅមើលមុង និងអង្រឹងដែលជាវត្ថុតាង។ ខ្ញុំបានវិភាគវត្ថុតាង ខ្ញុំបានសង្កេតដើមចោទសព្វគ្រប់ សង្កេតតាំងពីទឹកមុខ។ ខ្ញុំបានរាយការណ៍សេចក្តីសន្និដ្ឋានរបស់ខ្ញុំ តាមរយៈ វន វ៉េត ព្រោះខ្ញុំមិនចង់ប៉ះទង្គិចអារម្មណ៍របស់ ម៉ុក ថាលេខាវរសេនាតូចរូបនេះបាញ់ខ្លួនឯង។ លទ្ធផល គឺគ្មានអ្នកណាបានដោះលែងចុងចោទទេ។ ខ្ញុំបានដឹងតាម វន វ៉េត ថា ម៉ុក ប្រាប់ ប៉ុល ពត ថាគាត់មិនចេះប្រើខ្ញុំទេ។ ឆ្នាំ១៩៧៦ សុន សេន បានណែនាំខ្ញុំថា នយោបាយបញ្ហាបច្ចេកទេស។

១៦) សូមជូនព្រឹត្តការណ៍សម្រិតសម្រាងផ្ទៃក្នុងបក្ស នៅភូមិភាគនិរតីចាស់ តាមការចងចាំដូចតទៅ៖ ម៉ុក បានចាប់ផ្តើមកម្ចាត់កម្ចាយកម្មាភិបាល ដែលជាអតីតបញ្ញាជននិងអនុធន តាំងតែពីឆ្នាំ១៩៦៨។ ម៉ុក បានដេញកម្មាភិបាល ដែលពីដើមជាសាស្ត្រាចារ្យបឋមភូមិ និងមជ្ឈិមភូមិបួននាក់ឲ្យចេញផុតពីនិរតីតែក្នុងរយៈពេលម្ភៃបួនម៉ោង។ នៅខែកក្កដា ១៩៧១ ម៉ុក សម្រេចផែនការកម្ចាត់កម្ចាយនេះ បានជាមូលដ្ឋាន។ ភូមិភាគពិសេសដែលបង្កើតនៅខែកក្កដា ១៩៧១ ជាកន្លែងប្រមូលផ្តុំសមាសភាពដែល ម៉ុក កម្ចាត់កម្ចាយនេះ មកបម្រើការងារជុំវិញមន្ទីរភូមិភាគ។ នៅភូមិភាគនិរតីចាស់មិនឲ្យចាត់តាំងកម្មាភិបាល ដែលជាអតីតបញ្ញាជន អនុធនឲ្យកាន់កាប់មូលដ្ឋានឃុំ ស្រុក តំបន់ និងកាន់កាប់កងទ័ព។ ឆ្នាំ១៩៧១ រហូតដល់១៧ មេសា ១៩៧៥ ម៉ុក បានបញ្ជាឲ្យកម្ទេចនូវកម្មាភិបាលមួយចំនួន។

១៧) នៅពេលនោះខ្ញុំមិនទាន់ចេះគិតអីវែងឆ្ងាយទេ ចេះតែម្យ៉ាងគិត គឺភ័យខ្លាចជ្រុះ។ ភាសារបស់គេជំនាន់នោះ គឺចលនាវាយជម្រុះ ចលនាវារែងស្តី(?)។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែជឿថា ខ្ញុំអាចរស់បាន គឺអាស្រ័យជាមូលដ្ឋាន ដោយសារបណ្តាំបីម៉ាត់របស់ វន វ៉េត គឺកុំសម្រេចចាប់មនុស្សកុំប៉ះពាល់ជយភណ្ឌ កុំល្មើសស្ត្រីភេទ។

១៨) ខ្ញុំមិនអត្ថាធិប្បាយអំពីការសម្រិតសម្រាំងផ្ទៃក្នុងបក្សនៅភូមិភាគផ្សេងទៀតទេ ព្រោះគ្មានឯកសារ។

១៩) មុន១៧មេសា ១៩៧៥ ការកាប់សម្លាប់មានលក្ខណៈ ៖ ទីមួយ មិនរើសមុខ ពោលគឺមានទាំងប្រជាជនមកពីតំបន់ដី លន់ នល់ ប្រជាជនតំបន់រំដោះថ្មី ប្រជាជនមូលដ្ឋានបង្អែក មានទាំងយុទ្ធជនបក្សជន និងកម្មាភិបាល។ ទីពីរ គឺលក្ខណៈមិនវិទ្យាសាស្ត្រ ពោលគឺឈរទៅលើការសង្ស័យរបស់បុគ្គលថ្នាក់ដឹកនាំភាគ និងឈរតែលើចម្លើយសារភាពដែលចេញពីមន្ទីរនគរបាល។ យើងអាចយល់បានថាគេបញ្ជាឲ្យកាប់សម្លាប់មនុស្សដើម្បីផលប្រយោជន៍សេដ្ឋកិច្ច និងនយោបាយចំពោះមុខ និងយូរអង្វែង

របស់បក្សពួកគេ។

[១១:៥៨:៤១]

**V) មាគ៌ាសកម្មភាពរបស់មន្ទីរនគរបាល**

២០) ប្រធានមន្ទីរនគរបាលគ្មានសិទ្ធិសម្រេចចាប់មនុស្សទេ បក្សជាអ្នកសម្រេច។ បញ្ជាក់ដែលខ្ញុំហៅថា បក្សនៅពេលនោះ គឺសំដៅលេខា និងអនុលេខភូមិភាគ។

២១) ទារុណកម្មលើរូបរាងកាយជាយុទ្ធវិធីមួយដែលគេឲ្យប្រើ ហើយច្រើនតែចៀសមិនរួចទៅទៀត។ បញ្ជាក់អំពីបញ្ហាទារុណកម្មនៅម-១៣(ក) ខ្ញុំបានទទួលការណែនាំតាំងពីដំបូងពី ឆាយ គឹមហ៊ុំរ ហៅ ហុក បន្ទាប់មកពី វន វ៉េត។

២២) កម្ទេចមនុស្សដែលកាលនោះ គេហៅថា គិញ ឬហៅថា ជនក្បត់បដិវត្តន៍ ជាគោលការណ៍ដែលបក្សសម្រេច។ ក្នុងន័យអនុវត្តជាក់ស្តែង ឲ្យតែបក្សចាប់ប្រគល់មកឲ្យនគរបាលហើយ នគរបាលត្រូវតែសួរចម្លើយ រួចហើយកម្ទេច។

២៣) អាកប្បកិរិយាដឹកនាំនិងការធ្វើការងាររបស់ខ្ញុំ ខ្ញុំចេះគិតគូរ គ្រប់គ្រងខ្លួនឯងបាន មិនឲ្យសុភាសិតខ្មែរដៀលបានថា “គេឲ្យដើរមុខមិនចេះបង់បោយ គេឲ្យដើរក្រោយមិនចេះរើក”។

**ការកាប់សម្លាប់ក្រោយ១៧ មេសា ឆ្នាំ១៩៧៥**

**I. រយៈកាលពេល១៧ មេសា ១៩៧៥ ដល់៣០ មីនា ១៩៧៦**

២៤) ជម្លៀសប្រជាជន និងបណ្តេញជនបរទេសចេញពីកម្ពុជា ជាផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគេហៅថា ផែនការត្រៀមឈ្នះ។ វគ្គសិក្សាថ្ងៃ២៤/៦/៧៥ ដល់២៧/៦/៧៥ បានបង្ហាញខ្លឹមសារនេះក្នុងឯកសារទីពីរ ដែលមានចំណងជើងថា “ទស្សនៈសភាពការណ៍បច្ចុប្បន្ននៃបដិវត្តន៍របស់យើង និងវិធានការយើងមួយចំនួន” ពីទំព័រ ERN00078019 ដល់ 00078023 ខ្មែរ។

២៥) នៅក្នុងឱកាសជម្លៀសនេះ គេប្រើកម្លាំងកងទ័ព។ កងទ័ពត្រូវបានគេបញ្ជាឲ្យប្រើអំពើហិង្សារួចផ្សំនឹងពាក្យភូតភរ ដើម្បីបំភ័យ និងបណ្តេញប្រជាជន។ ដំបូងឲ្យចេញផុតពីផ្ទះ ពីទីក្រុង រួចហើយចេះតែដេញតទៅទៀត រហូតដល់ជនបទ។

[១១:០១:១៣]

២៦) ក្នុងរយៈពេលជម្លៀសនោះ កងទ័ពត្រូវបានគេបញ្ជាឲ្យចាប់នាយទាហាន នាយប៉ូលិស អ្នករដ្ឋការស៊ីវិល ដែលមានបណ្តាសក្តិធំ និងកំពូលដឹកនាំពុទ្ធសាសនាយកទៅកម្ទេចជាសម្ងាត់។

២៧) ប្រជាជនដែលត្រូវបានជម្លៀសទៅដល់ជនបទ ត្រូវអង្គការភូមិភាគចាត់ចែងឲ្យកម្មាភិបាលមូលដ្ឋានកត់ឈ្មោះ ស្នួរប្រវត្តិរូប ដើម្បីជ្រើសរើសរកសមាសភាពដែលត្រូវកម្ទេចតទៅទៀត។ នៅភូមិភាគនិរតី ខាងជើងផ្លូវលេខ៤ ស៊ី អនុលេខាភាគ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងចលនាកាប់សម្លាប់នេះ។ សង្កេត៖ ក្រោយមកបក្សប្រគល់តំបន់១៥ មក ស៊ី ដើម្បីបង្កើតទៅជាភូមិភាគបស្ចិម។

២៨) ទូទាំងប្រទេសកម្ពុជា មនុស្សដែលមានអំណាចពេញបរិបូរណ៍ ទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរយៈកាលទីមួយនេះ គឺ ប៉ុល ពត លេខាបក្ស, នួន ជា អនុលេខា, សោ ភឹម លេខាបូព៌ា, ម៉ុក លេខានិរតីចាស់និងថ្មី, វន វ៉េត លេខាភាគពិសេស, សុន សេន អនុលេខាភាគពិសេស, កុយ ធួន លេខាឧត្តរ, កែ ពក អនុលេខាឧត្តរ, ស៊ី អនុលេខានិរតីចាស់ និងលេខាបស្ចិម, ញឹម លេខាពាយ័ព្យ។

សូមបញ្ជាក់ថា មុននិងក្រោយ១៧ មេសា បន្តិច កងទ័ពគ្រប់គ្រងពលជារបស់ភូមិភាគ។ ចាប់ពី ១៧ មេសា មក ដែនដីកម្ពុជា លើកលែងតែភ្នំពេញចេញ ជារបស់ភូមិភាគ។ កម្លាំងជួរទាំងមូល ដែលរួមមានបក្ខជន សម្ព័ន្ធយុវកក និងមហាជចម្រើនជារបស់ភូមិភាគ ប្រជាជនចាស់ក៏ស្ថិតនៅក្នុងក្តាប់ដៃភូមិភាគ។ ដូច្នេះប្រជាជនរាប់លាននាក់ដែលជម្លៀសទៅ គឺអ្នកដប់នាក់នេះឯង ជាអ្នកចាត់ចែង សម្លាប់អ្នកណា ទុកអ្នកណា គឺដប់នាក់នេះឯងជាអ្នកសម្រេច។ ខ្ញុំមិនមានឯកសារសម្រាប់អះអាងតួលេខអ្នកដែលស្លាប់នៅពេលដំបូងនេះទេ តែខ្ញុំជឿថាប្រហែលជាអាចរាប់ឃើញសែន។

២៩) កម្មករដែលជម្លៀសចេញពីភ្នំពេញ បក្សឲ្យ ចេង អន ប្រមូលដឹកយកមករោងចក្រវិញនៅខែឧសភា ១៩៧៥។ ខ្ញុំសូមបញ្ជាក់ដោយឡែកថា ដោយខ្ញុំប្រាថ្នាគេចចេញពីការងារនគរបាលស្រាប់ ខ្ញុំបានអង្វរ ចេង អន ឲ្យជួយសុំអង្គការឲ្យបានទៅធ្វើការនៅខាងឧស្សាហកម្មជាមួយគាត់។ ចេង អន អបអរ តែ សុន សេន បដិសេធ។

៣០) ថ្ងៃខែមិនចាំ គ្រាន់តែក្រោយ១៧ មេសា បន្តិច ភូមិភាគពិសេសត្រូវបានលុប។ ដីតំបន់១៥ អង្គស្នួល កណ្តាលស្ទឹង ពញាឮ និងដង្កោ ត្រូវបានប្រគល់ទៅឲ្យ ស៊ី ដោយបក្សចាត់តាំងភូមិភាគមួយថ្មីហៅថាបស្ចិម។ ដីតំបន់២៥ ស្អាង កោះធំ លើកដែក កៀនស្វាយ ត្រូវប្រគល់ទៅឲ្យ ម៉ុក ដើម្បីចាត់តាំងទៅជាភូមិភាគនិរតីថ្មី។ បញ្ជាក់៖ តាមព័ត៌មានដែលខ្ញុំបានមកនៅពេលក្រោយៗទៀតថា គណៈតំបន់២៥ ត្រូវវិរុះទាំងស្រុង។

៣១) កុយ ធួន និងកម្លាំងគាត់ស្ទើរតែទាំងអស់ត្រូវបានដកចេញពីភូមិភាគឧត្តរ យកមកពង្រាយ

តាមក្រសួង។ កុយ ធួន ខ្លួនឯងនៅខាងពាណិជ្ជកម្ម ដែលភាគច្រើនជាភាគឧត្តរ។ ក្រសួងផ្សេងទៀត ដូចជាថាមពល ដឹកជញ្ជូនជើងទឹកជាដើម សុទ្ធតែមានពួកឧត្តរ។ សឿ វ៉ាស៊ី ហៅ ឌឿន ត្រូវបានបក្សយកទៅប្រើនៅ៨៧០។ ជ ឆាន ហៅ ស្រេង ត្រូវបានទុកនៅមូលដ្ឋាន ជាអនុលេខា កែ ពក។

៣២) កងទ័ពទាំងបួនភូមិភាគ ដែលវាយចូលភ្នំពេញ បូព៌ា ភូមិភាគពិសេស និរតី និងឧត្តរ ត្រូវបានជ្រើសរើសប្រមូលផ្តុំជាកងទ័ពមជ្ឈិម ដែលគ្រប់គ្រងផ្ទាល់ដោយ សុន សេន ប្រធានសេនាធិការ។

៣៣) មន្ទីរ និងក្រសួងជុំវិញ៨៧០ បានដំណើរការតាំងពីក្រោយ១៧ មេសា មកម្ល៉េះ តែគណៈកម្មាធិការនៃក្រសួងទាំងអស់នេះត្រូវបានកែសម្រួលបណ្តើរៗ រហូតអង្គប្រជុំអចិន្ត្រៃយ៍ថ្ងៃ១៩ ២០ និង ៣១ មេសា ទើបបានសម្រេចចាត់តាំងជាផ្លូវការ។

៣៤) ទន្ទឹមគ្នានឹងការរៀបចំខាងចាត់តាំង កងទ័ពមជ្ឈិម មន្ទីរ និងក្រសួងជុំវិញ៨៧០បែបនេះ សមាសភាពមេទាហាន មេប៉ូលិស មេគិញ និងអ្នករដ្ឋការស៊ីវិល ត្រូវបានគេស្រាវជ្រាវរកចាប់ខ្លួនតទៅទៀត ក្នុងនោះមានមួយចំនួនត្រូវបានបញ្ជូនដល់ស-២១។ ឈាមប្រជាជនកម្ពុជានៅតែហូរ ទាំងនៅជនបទ ទាំងនៅភ្នំពេញអត់មានពេលស្ងាងសោះ។

**II. រយៈកាលពី៣០ មីនា ១៩៧៦ ដល់ ៦ មករា ១៩៧៩**

៣៥) ឯកសារថ្ងៃ៣០ មីនា ១៩៧៦ ជាឯកសារដែលត្រូវបានសម្រេចនិងកំណត់ឡើងនៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានចាត់តាំងភូមិភាគនានា សម្រាប់គ្រប់គ្រងមូលដ្ឋានជនបទទូទាំងប្រទេស បានចាត់តាំងមន្ទីរ និងក្រសួងនានាសម្រាប់ដំណើរការការងាររដ្ឋ បានចាត់តាំងតំបន់ឯករាជ្យព្រោះលក្ខណៈពិសេសនៃតំបន់នោះ បានចាត់តាំងកងទ័ពមជ្ឈិម គ្រប់កងពលដោយប្រធានសេនាធិការ។ បញ្ជាក់៖ ឯកសារថ្ងៃ៣០ មីនា ១៩៧៦ ខ្ញុំទើបតែឃើញនៅ អ.វ.ត.ក នេះ។

៣៦) ឯកសារនេះ បានប្រគល់អំណាចសម្រេចកម្ទេចទៅឲ្យមនុស្សបួនក្រុម គឺអចិន្ត្រៃយ៍ភាគ គណៈមន្ទីរមជ្ឈិម អចិន្ត្រៃយ៍ មានន័យថា អចិន្ត្រៃយ៍មជ្ឈិម សេនាធិការ។ បើគិតជាបុគ្គលវិញមានដប់មួយនាក់ គឺ៖ ១) ប៉ុល ពត ,២) នួន ជា, ៣) សោ ភឹម, ៤) ម៉ុក, ៥) សុន សេន, ៦) ខៀវ សំផន, ៧) យ៉ា ៨) រស់ ញឹម, ៩) កែ ពក, ១០) ស៊ី, ១១) សែ។

[១១:០៨:២៤]

៣៧) គោលការណ៍បែងចែកអំណាច ជាគោលការណ៍ម៉ឺងម៉ាត់។ ក្រៅពីមនុស្សដប់មួយនាក់នេះ គ្មាននរណាមានសិទ្ធិនេះទេ។ ឧទាហរណ៍ កុយ ធួន ជាសមាជិកមជ្ឈិមពេញសិទ្ធិមែន តែជារដ្ឋមន្ត្រី

ដូច្នេះគ្មានសិទ្ធិសម្រេចកម្មេចទេ។ ណាត អតីតលេខាស-២១ ត្រូវបក្សមានវិធានការដោយសារ ណាត សម្រេចអត្តនោម័តិឲ្យចាប់មនុស្ស។

សំណួមពរទីពីរនៃកថាខណ្ឌទីមួយនេះ ដែលថែងអំពីសិទ្ធិសម្រេចកម្មេចនេះ បានសរសេរថា “ដើម្បីពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង”។ ប្រជាធិបតេយ្យសង្គមនិយម ឬប្រជាធិបតេយ្យប្រមូលផ្តុំ គឺសមូហភាពដឹកនាំបុគ្គលទទួលខុសត្រូវដោយឡែក។ សមូហភាព គឺបក្សទាំងមូលដែលតំណាងឲ្យលេខាបក្ស គឺ ប៉ុល ពត។ ចំណែកបុគ្គល បើនិយាយក្នុងក្របខ័ណ្ឌសិទ្ធិសម្រេចកម្មេចនេះ គឺលេខាភាគនីមួយៗ គឺប្រធានមន្ទីរមជ្ឈិម និងប្រធានសេនាធិការ មានន័យថា បើបុគ្គលមិនគោរពការដឹកនាំរបស់សមូហភាពទេ បុគ្គលនោះនឹងត្រូវទទួលវិន័យ។ ឧទាហរណ៍ កង ចាប ហៅ សែ លេខាភូមិភាគឧត្តរថ្មី ពិតជាមានសិទ្ធិសម្រេចកម្មេចមនុស្សទៅតាមមាគ៌ាបក្ស។ ដល់ សែ ទៅចាប់ប្អូន បងប្អូនរបស់ប្រពន្ធ ខៀវ សំផន សែត្រូវបាន ប៉ុល ពត មានវិធានការ គឺឲ្យគេចាប់សែប្រគល់មកឲ្យស-២១ បងប្អូនប្រពន្ធ ខៀវ សំផន ត្រូវបាន ប៉ុល ពត បញ្ជាឲ្យដោះលែង។

សង្កេត៖ ស៊ី លេខាបស្ចិម ក៏មានបញ្ហារបៀបនេះដែរ។ បើនិយាយតាមភាសាសាមញ្ញ គឺគេមិនទុកឲ្យកាំបិតចិតដងឯងទេ។

៣៩) បន្ទាប់ពីថ្ងៃ៣០ ខែមីនា ១៩៧៦ ការសម្រិតសម្រាំងមនុស្សនៅក្នុងជួរបដិវត្តនដើរតួសំខាន់ណាស់ គេបោសសម្អាតម្តងមួយភូមិភាគរហូតដល់គ្រប់ភូមិភាគ។ គេបោសសម្អាតម្តងមួយក្រសួងរហូតគ្រប់ក្រសួង។ គេបោសសម្អាតម្តងមួយកងពលរហូតគ្រប់កងពល។ អាចនិយាយបានថា ការសម្រិតសម្រាំងផ្ទៃក្នុងបានចាប់ផ្តើមឡើងពីខែមេសា ១៩៧៦ ដោយព្រឹត្តិការណ៍សំខាន់ពីរ។ មួយ) ព្រឹត្តិ-ការណ៍បោកគ្រាប់បែកក្រោយវាំង ថ្ងៃ២ មេសា ១៩៧៦។ ពីរ) កុយ ធួន ត្រូវបានដាក់ឃុំក្នុងផ្ទះពីថ្ងៃ៨ ខែ៤ ឆ្នាំ១៩៧៦។

៤១) តាមរយៈសេចក្តីសារភាពរបស់អ្នកបោកគ្រាប់បែក នាំឲ្យគេអាចចាប់ ចក្រី នៅថ្ងៃ១៩ ឧសភា ១៩៧៦។ ចាប់ ចក្រី និងចាប់ ស្ទួស នៅ ហៅ ឈូក ជាទ្វាររបើកនាំឲ្យគេឈានចូលបោសសម្អាតបូព៌ា។

៤២) ចំណែកខ្សែ កុយ ធួន គេសឡូវឯកសារយូរហើយ គេរង់ចាំតែចម្លើយ កុយ ធួន ប៉ុណ្ណោះ។ សូមបញ្ជាក់ជូនការសង្កេតថា សូមជូនជាការសង្កេតថា ២៥ មករា ១៩៧៧ ធួន ត្រូវបានបញ្ជូនមកដល់ស-២១។ ២៩ មករា ៧៧ ធួន សរសេរសេចក្តីសារភាពលើកទីមួយចប់។ ៣១ មករា ១៩៧៧ ខ្សែរបស់

ធួន ទាំងនៅភ្នំពេញ ទាំងនៅឧត្តរ ឲ្យតែ ធួន ឆ្លើយដាក់សុទ្ធតែត្រូវបានចាប់មកស-២១ ទាំងអស់។

៤៣) ការសម្រិតសម្រាំងខ្មែរ កុយ ធួន នេះនាំឲ្យខ្ញុំតក់ស្លុតម្តងទៀតជាលើកទីពីរ។ កត់ស្លុតលើកនេះធ្ងន់ធ្ងរណាស់។ ខ្ញុំចោទជាបញ្ហាក្នុងគំនិតថា ហេតុដូចម្តេចបានជាកសិករភូមិភាគឧត្តរត្រូវតែស្លាប់? កសិកររបស់ ម៉ុក ចេះតែត្រូវ? ចេះតែរីកមុខមាត់? ពួកអ្នកដែលមកជាប់អស់នេះ ភាគច្រើនណាស់ដែលខ្ញុំធ្លាប់ស្គាល់។ ខ្លះធ្លាប់ជាប់គុកព្រៃសជាមួយខ្ញុំ។ ធ្លាប់ឡើងចុះផ្ទះឪពុកម្តាយខ្ញុំ។ ខ្ញុំនឹកអាណោចអាធ័មក្នុងចិត្តឥតឧបមា។ តែចេះតែគិតមិនអស់មិនហើយថា ជនបដិវត្តន៍ដែលលះបង់អ្វីៗទាំងអស់ដើម្បីប្រជាជន បែជាមកស្លាប់ក្នុងឋានៈក្បត់បក្សនៅកន្លែងមួយដែលខ្ញុំជាកូនចៅអ្នកឧត្តរដែរមិនដឹងនឹងធ្វើម៉េចជួយបាន។ ខ្ញុំនៅចាំមិនភ្លេចទេ ថ្ងៃមួយខ្ញុំលើកអំពីរឿងមិត្តម្នាក់ជាមួយ សុន សេន។ គាត់កំហែងខ្ញុំពីចុងម្ខាងខ្សែទូរស័ព្ទថា "ឌុច អ៊ំា! ចម្លើយអា ឃួន ណ៎ា។ ឃួន ជាឈ្មោះបដិវត្តន៍មួយរបស់ កុយ ធួន"។ ថ្ងៃក្រោយមកទៀត ពេលសន្ទនានឹងខ្ញុំអំពីបញ្ហាមនុស្សម្នាក់។ គាត់បានធ្វើសតិអារម្មណ៍ខ្ញុំដោយនិយាយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។

[១១:១៣:៤១]

៤៤) ខ្ញុំនៅចងចាំថាភូមិភាគឧត្តរត្រូវបានប្រែឈ្មោះមកជាភូមិភាគកណ្តាលនៅពេលនោះឯង។

៤៥) គេចាប់មនុស្សរបស់ កុយ ធួន គេយកមនុស្សរបស់ ម៉ុក មកដាក់ជំនួស។ ឧទាហរណ៍ គេយកកូនប្រសារទីពីររបស់ ម៉ុក មកកាន់កាប់កងពល៤៥០។ ក្រោយដែលគេចាប់អ្នកឧត្តរបាត់ទៅ។ គេយកអ្នកកំពតមកធ្វើលេខាស្រុកស្ទោងជំនួសអ្នកកំពង់ចាម។ គេដាក់កូនស្រុករបស់ ម៉ុក មកក្តាប់ភូមិកំពង់ចិន ភូមិស្រុករបស់ខ្ញុំ ជំនួសកូនចៅអ្នកកំពង់ចិន។ តាមការវិភាគពិចារណារបស់ខ្ញុំឡើងវិញ ខ្ញុំជឿជាក់ថា កាប់សម្លាប់ខ្មែរគេឯង ដើម្បីដាក់ខ្មែររបស់ ម៉ុក។ នេះជាក្រឹត្យក្រមនៃការសម្រិតសម្រាំងជំនាន់នោះ។ ខ្ញុំគិតថា ហ្នឹងហើយដែលទ្រឹស្តីរបស់ពួកមហារបដិវត្តន៍វប្បធម៌ ហៅថា កម្ទេចលោកចាស់កសាងលោកថ្មី។

៤៦) បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកមនុស្សរបស់ ម៉ុក ថាជាកំពូលមនុស្សដែលចេះដោះស្រាយគ្រប់បញ្ហា។ សង្កេត៖ សូមលើកយកសម្តី ប៉ុល ពត ដែលនិយាយនៅក្នុងពិធីបុណ្យខួប ២៧ មេសា ៧៨ មករំឭកសរសេរជូនដូចតទៅ៖ "យើងទៅរកឯណាឲ្យវិទ្យាសាស្ត្រ ជាងអ្នកដែលធ្វើស្រែចេះធ្វើស្រែបានស្រូវហូប។ អ្នកច្បាំងដែលចេះវ៉ៃខ្មាំងឈ្នះ"។

៤៧) សូមលើកយករឿងពិតពីររឿង យកមកលាតត្រដាង។ មួយ) អ្នកកំពត ដែលចាត់តាំងទៅ

ធ្វើលេខាស្រុកស្មោងបានបង្ខំឱ្យកសិករទៅរកផ្តៅសោម យកមកចងកណ្តាប់។ ស្រុកខ្ញុំទៅរកផ្តៅសោមឯណាបានស្រួលនោះ មិនងាយទេ។ ពីរ) នៅពេលដែលខ្ញុំរាយការណ៍ជូន សុន សេន អំពីកម្មាភិបាលបង្អត់បាយប្រជាជន គាត់ឆ្លើយតាមទូរស័ព្ទមកភ្លាមថា “នេះមកពីយើងចាប់ខ្មាំងមិនទាន់អស់”។ ក្រោយមក ខ្ញុំបានរាយការណ៍ជូន សុន សេន ទៀត តាមប្រសាសន៍ម្តាយខ្ញុំម្តងទៀតថា “ពួកនិរតីក៏បង្អត់បានប្រជាជនដែរ” លោកនេះ សុន សេន នៅស្ងៀម។

៤៨) ខ្ញុំជឿថា យកកម្មាភិបាលពីកន្លែងផ្សេងមកគ្រប់គ្រងប្រជាជន ជាពិសេសគ្រប់គ្រងផ្ទាល់ជាលេខាសហករណ៍ ជាការចាត់តាំងមួយខុសឆ្គងធ្ងន់ធ្ងរណាស់។ មាគ៌ាបក្សវាឧក្រិដ្ឋស្រាប់ទៅហើយ ដល់យកមនុស្សពីចម្ងាយមកកាន់កាប់ មកកាច់ប្រជាជនឱ្យបាក់បែបនេះនាំឱ្យវិនាសហិនហោចគ្រប់វិស័យទាំងអស់ ជាពិសេសហិនហោចអាយុជីវិតទាំងស្រស់ៗអស់ជាងមួយលាននាក់។ ប្រជាជនភូមិណាក៏ដូចភូមិណាសុទ្ធតែរងកាំដូចប្រជាជនភូមិខ្ញុំអ៊ីចឹង។ នេះតាមខ្ញុំវិភាគនិងសន្និដ្ឋាន។

បន្ទាប់ពីភូមិភាគកណ្តាលគេបោសសម្អាតភូមិភាគបស្ចិម ដំបូងគេពុះពារទាមទារឲ្យ ស៊ី ប្រគល់មនុស្សខ្លះ ដែលអាចជាគន្លឹះឈានទៅចាប់ ស៊ី បាន។ ដូចជាប្រធានមន្ទីរភាគ ដែលជាប្អូនថ្លៃ ស៊ី និងប្រធានមន្ទីរនគបាលជាដើម តាមយុទ្ធវិធីមុននឹងកាប់ឫស្សីត្រូវឆ្ការបន្លា។ សូមបញ្ជាក់ថា ស៊ី ជាមនុស្សស្រែកឃ្លានកាន់កាប់សម្លាប់ដូច ពក និង ម៉ុក ដែរ តែ ស៊ី បែជាធ្វើឲ្យគេមិនស្រណុកចិត្ត ព្រោះ ស៊ី មានចេតនារើរុះកម្លាំងរបស់ ប៉ាល់ អនុលេខាបស្ចិម ដែល ប៉ុល ពត និង នួន ជា ជឿទុកចិត្ត។

[១១:១៧:១៣]

៥០) ស៊ី ត្រូវបានចាប់ខ្លួនមុនថ្ងៃ១៧ មេសា ១៩៧៨ បន្តិច។ ម៉ុក ត្រូវបានតែងតាំងជាលេខាបស្ចិមមួយជាន់ទៀត។ ប៉ាល់ នៅជាអនុលេខាដដែល។ កម្លាំង ស៊ី ដែលនៅសេសសល់ គេរើរុះ។

៥១) ក្រោយចាប់ ស៊ី គេចាប់ ញឹម។ គេចាប់ ញឹម ប្រហែលក្នុងខែ៥ ៧៨។ គេចាប់ ញឹម គេដាក់ ម៉ុក ឲ្យធ្វើលេខាពាយ័ព្យមួយជាន់ទៀត ដែល ម៉ុក ខ្លួនឯងនិយាយថា គេឲ្យធ្វើគ្រូសង្គ្រាជច្រើនវត្ត។ អនុលេខាភាគ គេយកមនុស្សពីបស្ចិមយកទៅដាក់។ សមាជិក គេយកមនុស្សពីនិរតីយកទៅដាក់។ កម្មាភិបាលថ្នាក់ក្រោម តាំងពីឃុំឡើងទៅ សុទ្ធតែជាមនុស្សរបស់និរតីនិងបស្ចិម។ តាមសម្តីដែលពួកគេដំណាលពីការបិទកម្មាភិបាលទៅពាយ័ព្យ គឺដឹកទៅទាំងឡានៗរហូតខូងដី។ និយាយនេះ វាហួសការពិត តែវាបង្ហាញឲ្យឃើញថា ពួកគេ ខ្លួនគេក៏គេហួសចិត្ត។

៥២) ការបោសសម្អាតនៅបូព៌ា ខែ៦ ៧៨ គេបោសសម្អាតបូព៌ាដោយទ្រង់ទ្រាយធំដែលមិន

ផ្តាច់មាន។ យុទ្ធជនប្រមាន៣០០ ត្រូវបញ្ជូនមកឲ្យស-២១ កម្ទេចមិនបាច់សួរចម្លើយ។ កម្មាភិបាលតំបន់ កម្មាភិបាលភូមិភាគ កម្មាភិបាលយោធា សុទ្ធតែបញ្ជូនមកឲ្យកម្ទេច។ សួរចម្លើយ គេលែងគិតគូរហើយ។ ចំណែក សោ ភឹម ដែលមិននឹកស្មានថា ប៉ុល ពត សម្រេចកម្ទេចគាត់។ គាត់ឲ្យគេជូនមកសុំជួប ប៉ុល ពត។ បានដំណឹងថា សោ ភឹម មកសុំជួប ប៉ុល ពត បញ្ជាឲ្យកម្លាំងតាមចាប់ សោ ភឹម រហូត សោ ភឹម បាញ់សម្លាប់ខ្លួនឯង។ សូមបញ្ជាក់ថា បើតាមខ្ញុំចាំ ពេលដែលមិនទាន់ចាប់ សោ ភឹម បាន ប៉ុល ពត បានឲ្យបាចខិត្តប័ណ្ណតាមឧទ្ធម្ភាគចក្រ ទន្ទឹមនេះកម្លាំងទ័ពរបស់ ប៉ុល ពត ត្រូវបានកម្លាំងដែលស្មោះត្រង់នឹង សោ ភឹម រួមជាមួយនឹងប្រជាជនប្រដាប់អាវុធតបតវិញ។

៥៣) ថ្ងៃ១១ ខែ១០ ឆ្នាំ៧៨ ទើបគេចាប់ កង ចាប ហៅ សែ បញ្ជូនមកស-២១។

៥៤) ថ្ងៃ២ វិច្ឆិកា ១៩៧៨ ទើបចាប់ ទើប វន វ៉េត ត្រូវចាប់បញ្ជូនមកស-២១។

៥៥) បើគិតត្រឹមថ្ងៃ២ វិច្ឆិកា មានការប្រែប្រែខាងសារជាតិនៃអង្គការចាត់តាំងគ្រប់ផ្នែក។ អចិន្ត្រៃយ៍មជ្ឈិមក៏ប្រែប្រួល។ សមាជិកមជ្ឈិមក៏ប្រែប្រួល។ គណៈកម្មាធិការភាគ តំបន់ ស្រុក ឃុំ ក៏ប្រែប្រួល។ គណៈកម្មាធិការមន្ទីរ ក្រសួង ក៏ប្រែប្រួល។ កងទ័ពមជ្ឈិមក៏ប្រែប្រួល។

[១១:២០:១៩]

៥៦) អចិន្ត្រៃយ៍ដែលចាត់តាំងដោយមហាសន្និបាតឆ្នាំ១៩៧៦ មានប្រាំពីរនាក់គឺ៖

១) ប៉ុល ពត លេខា, ២) នួន ជា អនុលេខាទីមួយ, ៣) សោ ភឹម អនុលេខាទីពីរ, ៤) អ៊ីង ជឿន ហៅ ម៉ុក អនុលេខាទីបី, អៀង សារី សមាជិកអចិន្ត្រៃយ៍ពេញសិទ្ធិ, វន វ៉េត សមាជិកអចិន្ត្រៃយ៍ត្រៀម,សុន សេន សមាជិកអចិន្ត្រៃយ៍ត្រៀម។

មហាសន្និបាតឆ្នាំ១៩៧៨ ដែលជាមហាសន្និបាតវិសាមញ្ញបានសម្រេចចាត់តាំងគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មីដូចតទៅ៖

១) ប៉ុល ពត លេខា, ២) នួន ជា អនុលេខាទីមួយ, អ៊ុំង ជឿន អនុលេខាទីពីរ, ៤) អៀង សារី មិនដឹងជាឡើងជាអនុលេខាទីបី ឬនៅជាសមាជិកពេញសិទ្ធិ។ ៥) សុន សេន មិនដឹងឡើងទៅជាពេញសិទ្ធិ ឬក៏នៅត្រឹមតែត្រៀម។ ៦) ខៀវ សំផន មិនដឹងឡើងផ្លោះទៅជាពេញសិទ្ធិ ឬនៅត្រឹមត្រៀម។

៥៧) គណៈកម្មាធិការមជ្ឈិមទាំងបីកម្រិតខាងក្រោម គឺសមាជិកមជ្ឈិមពេញសិទ្ធិ សមាជិកមជ្ឈិមត្រៀម និងជំនួយការមជ្ឈិមដែលនៅសល់ មិនដល់ដប់នាក់ផងត្រូវបានចាត់តាំងបន្ថែម។ មហាសន្និបាតលើកនេះ ដោយជ្រើសរើសកម្មាភិបាលនិរតី និងបស្ចិមស្មើរទាំងអស់ ជាពិសេសនិរតី។

៥៨) គណៈកម្មាធិការមន្ទីរក្រសួងជុំវិញ៨៧០ ក៏ផ្លាស់ប្តូរមូលដ្ឋាន ដូចជា ឧស្សាហកម្ម ថាមពលជាដើម។

៥៩) គណៈកម្មាធិការភូមិភាគ គណៈកម្មាធិការតំបន់ គណៈកម្មាធិការស្រុក គណៈកម្មាធិការឃុំក៏ផ្លាស់ប្តូរដល់ឫសគល់តាមខេត្តផ្សេងភាគច្រើន ដូចជា៖ កំពង់ធំ កំពង់ចាម ព្រៃវែង ស្វាយរៀង ពោធិសាត់ បាត់ដំបង។

[១១:២២:២៦]

៦០) កងទ័ពមជ្ឈិម បើតាមខ្ញុំចាំនៅសល់តែកងពល១៦៤ កងពល៥០២ និងកងពល៨០១។ សូម្បីតែកងពល៧០៣ ដែល ប៉ុល ពត សរសើរពេញទំពោងមាត់កាលពីប្រជុំអចិន្ត្រៃយ៍ថ្ងៃ៩ តុលា ៧៥ ក៏បាត់ស្រមោល បាត់ទាំងលេខកង បាត់ទាំងឈ្មោះលេខា។ ចំណែកកងខ្លះដូចជា៣១០, ៤៥០, ១៧០, ២៩០ ដែលគេដកអាវុធ យកយុទ្ធជន និងកម្មាភិបាលទៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំង ខ្ញុំក៏ខ្ញុំឮថាគេប្រមូលយកមកទៅកម្ទេចទាំងឈុតៗមុនថ្ងៃ៦ មករា ១៩៧៨។

៦១) ប្រជាជនកម្ពុជាដែលត្រូវបាត់បង់ (អ៊ំ សុំទោស)។

៦១) ប្រជាជនកម្ពុជាដែលត្រូវបានចាប់បង្ខំទាំងកម្រោលឲ្យរស់នៅនិងធ្វើការងារតែក្នុងវណ្ណៈពីរ គឺវណ្ណៈកសិករ និងវណ្ណៈកម្មករ ដែល ប៉ុល ពត ហៅជាផ្លូវការកាលពីថ្ងៃ៦ មករា ៧៨ ថាជាកសិករសមូហភាព កម្មករសមូហភាព។ តាមពិតជាកម្លាំងដែលទ្រុឌទ្រោមខាងសុខភាព ហត់ហេវខាងកម្លាំងកាយកម្លាំងចិត្ត អស់សង្ឃឹមក្នុងជីវិត មិននឹកស្មានថា មានអ្នកមករំដោះខ្លួនផង។

៦២) សេចក្តីរំឭកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្លះ។ ថ្ងៃ២០ កក្កដា ១៩៦២ ទូ សាមុត បាត់ខ្លួន។ ចុងខែកុម្ភៈ ឆ្នាំ១៩៦៣ មហាសន្និបាតវិសាមញ្ញប្រថាប់ត្រាឲ្យ ប៉ុល ពត ឡើងជាលេខាបក្សរំលង នួន ជា។ ឆ្នាំ១៩៦៨ ម៉ា ម៉ង់ ស្លាប់ ម៉ុក ឡើងជាលេខានិរតីរំលង ប្រសិទ្ធ ហៅ ចុង។ ឆ្នាំ១៩៧៤ ចុង ត្រូវកម្ទេច។ ខ្ញុំនៅតែយល់ថាមក ម៉ុក ចាក់រុក។ ឆ្នាំ១៩៨៤ ឬ៨៥ ប៉ុល ពត បោះបង់ កែ ពក។ ខ្ញុំយល់ថានេះក៏ជាឧបាយកល ម៉ុក។ ឆ្នាំ១៩៩៤ ឬ៩៥ ប៉ុល ពត លែងឲ្យ សុន សេន ប្រកាន់តួនាទីដឹកនាំ។ នេះក៏ខ្ញុំគិតថា មកពី ម៉ុក ចាក់រុក។ ឆ្នាំ១៩៩៧ ប៉ុល ពត កម្ទេច សុន សេន និងក្រុមគ្រួសារ នេះជាព្រឹត្តិ-ការណ៍ចុងដែល ប៉ុល ពត បញ្ជាសម្លាប់មនុស្ស។ ខ្ញុំយល់ថា នេះមកពីទំនាស់ ប៉ុល ពត និង សុន សេន វាទុំហើយ តែម្យ៉ាងទៀត ខ្ញុំនៅតែយល់ថា នេះជាល្បិចដែល ម៉ុក ធ្លាប់ប្រើហូរហែពីមុនមក គឺយកដៃ ប៉ុល ពត កម្ទេចខ្មាំងសត្រូវរបស់ខ្លួន។ ប៉ុល ពត ធ្លាប់ចំណាប់ ម៉ុក ធ្វើមទ្ទិញប្រកាសកាត់ទោស ប៉ុល

ពត។ ម៉ុក បញ្ជាឲ្យគេសម្លាប់ សារឿន, សាន និង ឃន។ ម៉ុក ប្រកាសធ្វើសង្គ្រាមតទៅទៀតក្នុងវត្ថុបំណងប្រោសរបបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះឲ្យឡើងវិញ។

៦៣) បើនិយាយ ប៉ុល ពត វិញ តាំងពីបាត់បង់ ទូ សាមុត ទៅ គាត់ជាអ្នកធំបង្អស់ គាត់លើកទ្រឹស្តី លើកមាគ៌ាកម្ចាត់កម្ចាយមនុស្ស។ កាប់សម្លាប់មនុស្សយ៉ាងសាហាវបំផុត លក្ខណៈសម្បត្តិដប់ជ្រើសរើសកម្មាភិបាល រូបភាពហាក់ដូចជាទន់ភ្លន់ មានហេតុផល តែជាក់ស្តែងសាហាវណាស់។ ឯងល្អ ឯងអាក្រក់ អញជារង្វាស់តែមួយគត់។ តែម្យ៉ាងទៀតខ្ញុំនៅតែយល់ថា ប៉ុល ពត បានប្រើល្បិចសម្ងាត់ ដែល ស្តាលីន បានប្រើសម្លាប់ ត្រុតស្គី ដើម្បីសម្លាប់ ហាំង ង៉ោ និងសម្លាប់ប្រពន្ធខ្ញុំ និងខ្ញុំ តែវាស៊យស្លាប់តែប្រពន្ធខ្ញុំ។ គេសម្លាប់ ហាំង ង៉ោ ព្រោះរឿងខ្សែភាពយន្តវាលពិឃាត គេប្រាថ្នាជីវិតខ្ញុំ និងប្រពន្ធខ្ញុំ ជាពិសេសដើម្បីបំបិទមាត់រឿងស-២១។ ទោះបីបីនាក់នេះគ្មានលទ្ធភាពសម្លាប់គេក៏ដោយ។

៦៤) តម្រាយប្រវត្តិសាស្ត្រដែលខ្ញុំរំលឹកយកមករាយការណ៍នេះ ជាគោលអាងនូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដែលថាបក្សកុម្មុយនីស្តកម្ពុជា យកការកាប់សម្លាប់ដោះស្រាយគ្រប់បញ្ហា។ ដើម្បីសម្រេចមហិច្ឆតារបស់ពួកគេ គឺកសាងសន្តតិវង្សនៅកម្ពុជា។ គំនូរចំអកដែលមានចំណងជើងថា "ថ្ងៃអន្សាររបស់បក្សកុម្មុយនីស្តកម្ពុជា" ដែលខ្ញុំបានដាក់ជូនអង្គជំនុំជម្រះនេះរួចហើយ ជាការបកស្រាយលោកទស្សនៈរបស់ខ្ញុំ ចំពោះប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដូចដែលរាយការណ៍ខាងលើ។

៦៥) ប៉ុល ពត ប្រាថ្នាសោយរាជ្យដោយទុកឲ្យ ម៉ុក និងកម្លាំងគាត់វ៉ាប់រងខាងយោធា និងកសិកម្ម។ ប៉ុល ពត រំពឹងសោយរាជ្យក្រោយស្លាកបដិវត្តន៍វណ្ណៈអធនដ៏បរិសុទ្ធ។

៦៦) ចំណែក ម៉ុក វិញ មួយជីវិតគាត់ គាត់មិនសុខចិត្តនៅក្រោមអ្នកណាទេ។ ម៉ុក តាំងខ្លួនជាកំពូលកសិករ ជាបិតាសច្ចធម៌។ សម្តីគាត់ គឺ "នៅពីលើ ម៉ុក មានមួក នៅពីលើមួក មានមេឃ"។ តាមខ្ញុំសង្កេតសម្តីនេះ មិនធម្មតាទេ។ គាត់ប្រើព្យញ្ជនៈ "ម" "ម៉"។

[១១:២៨:១២]

### III) សរុបពី១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩

៦៧) ពេលមួយរយៈកាលពី ១៧ មេសា ១៩៧៥ រហូតដល់ ៦ មករា ១៩៧៩ ជារយៈកាលដែលបក្សកុម្មុយនីស្តកម្ពុជា មានអំណាចទាំងស្រុកលើទឹកដីកម្ពុជាទាំងមូល។

មួយ) បក្សកុម្មុយនីស្តកម្ពុជាបានប្រឹងប្រែងអស់លទ្ធភាព ដើម្បីប្រែក្លាយប្រជាជនគ្រប់ស្រទាប់វណ្ណៈឲ្យទៅជាកសិកម្មសមូហភាព កម្មករសមូហភាព។ អ្នកដែលមិនព្រមក្លាយខ្លួនទៅជាកម្មករ កសិករ

ឬក៏អ្នកដែលប្រឹងទៅមិនរួច សុទ្ធតែទទួលរងគ្រោះថ្នាក់ កាប់សម្លាប់។ ទីពីរ) នៅក្នុងជួរ បក្សបានសម្រិតសម្រាំងដោយកម្ចាត់កម្ចាយកម្លាំងគេឯងគ្រប់គ្នា និងកាប់សម្លាប់គេឯងគ្រប់គ្នា ហើយដាក់កម្លាំងរបស់ខ្លួន តាំងពីសហករណ៍ សហជីពរហូតដល់អចិន្ត្រៃយ៍មជ្ឈិម។

៦៨) អ្នកដែលមានសិទ្ធិអំណាចពេញបរិបូរ។ យោងតាមខ្លឹមសារនៃឯកសារ ថ្ងៃ៣០ មីនា ១៩៧៦ បើគិតសរុបតាំងពីថ្ងៃ១៧ មេសា ៧៥ រហូតដល់ថ្ងៃ៦ មករា មានដប់បីនាក់គឺ៖ ១) ប៉ុល ពត, ២) នួន ជា, ៣) សោ ភឹម, ៤) អ៊ុំង ជឿន ហៅ ម៉ុក, ៥) វន វ៉េត, ៦) សុន សេន, ៧) ខៀវ សំផន, ៨) កុយ ធួន, ៩) ម៉ែន សាន ហៅ យ៉ា, ១០) វស់ ញឹម, ១១) កែ ពក, ១២) ជូ ជេត ហៅ ស៊ី, ១៣) កង ចាប។

**អំពីសន្តិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា**

[១១:៣០:០៨]

៦៩) មន្ទីរសន្តិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានយ៉ាងតិចណាស់-- សូមទោស សូមអានម្តងទៀត។

៦៩) មន្ទីរសន្តិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានយ៉ាងតិចណាស់មាន ១៩៦។

**I) ទិដ្ឋភាពរួមនៃមន្ទីរសន្តិបាលទាំងអស់មានលក្ខណៈដូចគ្នា**

**អំពីខ្សែចាត់តាំងការងារ**

៧០) មន្ទីរសន្តិបាលនីមួយៗ ស្ថិតនៅក្នុងការចាត់តាំងមួយច្បាស់លាស់ តាមខ្សែចាត់តាំងរបស់បក្ស។ ឧទាហរណ៍ មន្ទីរសន្តិបាលស្រុក ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លេខាស្រុក មិនមែនស្ថិតនៅក្រោមការគ្រប់គ្រងគណៈកម្មាធិការស្រុកទេ។

៧១) ចម្លើយសារភាពរបស់មន្ទីរសន្តិបាល ជាឯកសារសម្ងាត់ ដែលត្រូវតែប្រគល់ឲ្យមេផ្ទាល់របស់ខ្លួន ដោយផ្ទាល់ដៃ ឬតាមនីរសារ ដែលមេចាត់តាំងឲ្យមកទទួល។ គឺមេជាអ្នកចាត់ចែងផ្ញើទៅលើក្នុងឋានៈជាឯកសារផ្លូវការក្នុងបក្ស។

៧២) មន្ទីរសន្តិបាលនៅជនបទ។ ទោះបីខាងចាត់តាំងស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លេខាស្រុក របស់លេខាតំបន់ ឬរបស់លេខភូមិភាគក៏ដោយ ក៏ចម្លើយណាដែលចាំបាច់ យ៉ាងហោចណាស់ ចម្លើយសារភាពដែលចាំបាច់ត្រូវបានគេបញ្ជូនតាមខ្សែចាត់តាំងរបស់បក្សទៅដល់ ប៉ុល ពត។ នេះជាគោលការណ៍ដែលមិនអាចល្មើសបាន។

ឧទាហរណ៍៖ ថ្ងៃ៥ ខែ៩ ២០០៧ ខ្ញុំបានរាយការណ៍ជូនសហចៅក្រមស៊ើបសួរអំពីចម្លើយចេញពីមន្ទីរនគរបាលតំបន់៣២, បស្និម (ឯកសារ D16.2)។ ឯកសារ D58/II ជាចម្លើយសារភាពដែលចេញពីមន្ទីរសន្តិបាលតំបន់២១ បូព៌ា។ ឯកសារE52/4.62 ម៉ុក ចារដោយផ្ទាល់ដៃលើក្របចម្លើយសារភាព ដែលផ្ញើមក ប៉ុល ពត។ D32/4 ឬ ហៅថា D43/4 ជាលិខិតអម ដែល សែ, កង ចាប លេខាឧត្តរ៨០១ លេខាឧត្តរថ្មី៨០១ ផ្ញើចម្លើយសារភាពរបស់ សាន់ អៀប ហៅ ខុន និង ស៊ើយ ហៅ ផង់ មក ប៉ុល ពត។ សូមបញ្ជាក់ឯកសារទាំងបួននេះ ពិតជាដល់ដៃ ប៉ុល ពត ដើម្បី ប៉ុល ពត ចាត់ចែង។

៧៣) ចំណែក ស-២១ ដែលស្ថិតនៅក្រោមការគ្រប់របស់ សុន សេន ក៏អ៊ីចឹង៖

ចម្លើយសារភាពណា ដែល សុន សេន ចាប់អារម្មណ៍ សុន សេន ចារពីលើក្របជូន ប៉ុល ពត ពិនិត្យ និងសម្រេចជាបន្ទាន់។ ឧទាហរណ៍៖ E3/20 ចម្លើយ ហេង ពេជ ហៅ ឆន។ D93/III ចម្លើយ ឡុង មុយ ហៅ ជួន សង្កេត ដោយឡែក E3/86 សុន សេន ចារសូមសេចក្តីសម្រេចរបស់ នួន ជា ពេលនោះ នួន ជា ជារដ្ឋមន្ត្រីទីមួយស្តីទី និយាយឲ្យចំ គឺលេខាបក្សស្តីទី។ បក្សឲ្យតម្លៃទៅលើចម្លើយសារភាព។

[១១:៣៣:៣២]

៧៤) ស-២១ ពិតជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ដែលជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមបក្សមែន។ តាមពិត សុន សេន ជាបុគ្គលទីប្រាំពីរ ឯ សោ ភឹម ជាបុគ្គលទីបី ម៉ុក ជាបុគ្គលទីបួន។ បើអះអាថា ស-២១ ធំជាងមន្ទីរសន្តិបាលផ្សេងទៀត ព្រោះហេតុផល សុន សេន នោះក៏គួរតែអះអាងថា មន្ទីរសន្តិបាលបូព៌ាធំជាងគេ ព្រោះហេតុផល សោ ភឹម។ បន្ទាប់មកពីមន្ទីរសន្តិបាលនិរតី ព្រោះហេតុផល ម៉ុក។ តាមពិតវាមិនមានលំដាប់ដូចឋានៈអ៊ីអ៊ីចឹងទេ។

មន្ទីរសន្តិបាលទាំងអស់ស្មើភាពគ្នាចំពោះមុខបក្សដោយចម្លើយសារភាព។ ឧទាហរណ៍៖ D32/2.4 ឬហៅ D43/4 បក្សចាប់អារម្មណ៍មែនទែន។ ជាក់ស្តែង សែ ចារលិខិតអមផ្ញើមកនៅថ្ងៃ១៧ មេសា ១៩៧៨ នួន ជា អានចប់នៅថ្ងៃ១៩ មេសា ១៩៧៨។ E3/416 ជាឯកសារ ស-២១ ប៉ុល ពត ចាប់អារម្មណ៍មែនទែន។ ចម្លើយសារភាពដែលចេញពីមន្ទីរសន្តិបាលតំបន់-៣២ បស្និម ទើបណែនាំឲ្យ សុន សេន យកទៅណែនាំស-២១។ ពេលនោះ ណាត និងខ្ញុំ។ នៅក្នុងកំណត់ហេតុសួរចម្លើយ D16/2។

**សិទ្ធិសម្រេចកម្មេច និងការងារស្នូលរបស់មន្ទីរសន្តិបាល**

៧៦) មន្ទីរសន្តិបាលគ្មានសិទ្ធិសម្រេចកម្ទេចទេ និយាយឲ្យចំប្រធានមន្ទីរសន្តិបាលណាក៏ដោយក៏គ្មានអំណាចចេញបញ្ជាអត្តនោម័តិឲ្យចាប់មនុស្សដែរ។ ឯកសារថ្ងៃ៣០ មីនា ១៩៧៦ ជាគោលចារឹកធំបំផុត អ្នកដែលល្មើសពិតជាបក្សមានវិធានការ។ ណាត លេខាស-២១ ជាឧទាហរណ៍ជាក់ស្តែងស្រាប់។ អង្គប្រជុំថ្ងៃ១៩ ថ្ងៃ២០ និងថ្ងៃ២១ ១៩៧៦ ហាមមិនឲ្យប្រើ ណាត ឲ្យក្តាប់កម្លាំង។ បញ្ជាក់៖ បើប្រើពាក្យចាប់ក្នុងន័យប្រតិបត្តិការបច្ចេកទេសតាមបញ្ជាច្បាស់លាស់ នោះមាន។

៧៧) មន្ទីរសន្តិបាលត្រូវរង់ចាំទទួលមនុស្ស ដែលខាងលើបានបញ្ជាច្បាស់លាស់ឲ្យរង់ចាំ។ មនុស្សដែលខាងលើប្រគល់ឲ្យត្រូវតែកម្ទេចនៅពេលចុងបញ្ចប់។ យកមនុស្សសំខាន់ ដែលកំពុងយកទៅកម្ទេចជាបទល្មើស។ ក្នុងការអនុវត្តជាក់ស្តែងប្រធានមន្ទីរសន្តិបាលដឹងច្បាស់ជាងគេ នៅឈ្មោះមនុស្សដែលអង្គការត្រូវការចម្លើយជាចាំបាច់ ដូច្នេះត្រូវធានាចំពោះមុខបក្សកុំឲ្យដាច់ចម្លើយ។ ពេលយកមនុស្សទៅកម្ទេចម្តងៗត្រូវមានការចាត់តាំងច្បាស់លាស់ ជាកម្រិតពួក ជាកម្រិតក្រុម ជាកម្រិតអនុសេនាតូចដោយប្រធានពួក ប្រធានក្រុម ប្រធានអនុសេនាតូចទទួលខុសត្រូវលើការងាររបស់ខ្លួនហ្មត់ចត់ នេះជាវិន័យយោធា។

ឧទាហរណ៍៖ នៅស-២១ ប្រធានអនុសេនាតូចកងពិសេស ពេលយកមនុស្សចេញទៅកម្ទេចម្តងៗ ត្រូវប្រកាន់តួនាទីរបស់ខ្លួនជាបញ្ជាការប្រតិបត្តិការ។

[១១:៣៧:១៧]

**អំពីទារុណកម្មលើរូបរាងកាយ**

៧៨) ទារុណកម្មលើរូបរាងកាយ ជាយុទ្ធវិធីដែលអនុញ្ញាតឲ្យធ្វើ។ ក្នុងការជាក់ស្តែងច្រើនតែចៀសមិនរួច។ ទន្ទឹមនេះជាគោលការណ៍ ដែលបក្សទាំងមូលដឹងឮ។

ឧទាហរណ៍៖ D43/4 ឯកសារថ្ងៃ២៦ តុលា ៧៧ ត្រង់ទំព័រ ERN00173920 អ្នកសួរបញ្ជាក់ថា គេបានធ្វើទារុណកម្ម ចម្លើយសារភាពបញ្ជូនទៅភូមិភាគកណ្តាល សំណុំរឿងលេខ០០២។ D43/4 ឯកសារថ្ងៃ២៨ តុលា ២៩៧៧ ត្រង់ទំព័រ ERN00174762 អ្នកសួរបញ្ជាក់ថា គេបានធ្វើទារុណកម្មចម្លើយសារភាពនេះត្រូវបញ្ជូនទៅភូមិភាគពាយ័ព្យ សំណុំរឿងលេខ០០២។ ដូច្នេះ ទារុណកម្មលើរូបរាងកាយពិតជាត្រូវបានអនុវត្តគ្រប់មន្ទីរសន្តិបាល បើមិនដូច្នេះទេបក្សមិនឲ្យស-២១ ជូនព័ត៌មានរបៀបនេះទេ។

ម្យ៉ាងទៀតអ្នកសួរចម្លើយមានកម្រិតប្រហែលគ្នាបីជំនាន់ហើយ ជំនាន់សីហនុ, លន់ នល់ ការងារសួរចម្លើយវាជាការងាររបស់អធិការនគរបាល ឬសក្តិមួយប៉ូលិស។ ក្នុងសម័យខ្មែរក្រហម វាជាការងាររបស់អ្នកសួរ។ កាលខ្ញុំជាប់គុក ខ្ញុំមិនដែលឃើញសក្តិពីរ សក្តិបីណាម្នាក់ទៅអើតខ្ញុំទេ មកអើតខ្ញុំទេ។ ប្រធានមន្ទីរសន្តិបាលខ្មែរក្រហម ទាំងគេ ទាំងខ្ញុំ ខ្ញុំជឿថា គ្មានអ្នកណាម្នាក់មិនប្រកាន់តួនាទីដឹកនាំទេ។

**III) ទិដ្ឋភាពដែល ស-២១ ប្លែកពីមន្ទីរសន្តិបាលផ្សេងទៀត**

៨០) មន្ទីរស-២១ ប្លែកគេដោយសារសមាជិកមជ្ឈិមទាំងអស់ត្រូវបានឃុំខ្លួន សួរចម្លើយ និងកម្ទេចនៅទីនោះ។ បញ្ហានេះពិត។ មូលហេតុសំខាន់ គឺ ប៉ុល ពត ចាត់ទុកពួកនេះជាបន្លាក្នុងភ្នែក ដែលគាត់ត្រូវតាមដាន ដើម្បីមានវិធានការទាន់ពេលវេលា។

ឧទាហរណ៍៖ កុយ ធួន ២៥ មករា ១៩៧៧ កុយ ធួន ត្រូវបានបញ្ជូនមកដល់ស-២១។ ២៩ មករា ១៩៧៧ ធួន សរសេរសារភាពចប់។ ៣១ មករា ១៩៧៧ សម្រិតសម្រាំងខ្សែ ធួន តាមចម្លើយធួន។ ផ្ទុយទៅវិញ មន្ទីរសន្តិបាលទាំង១៩៥ ផ្សេងទៀតទូទាំងប្រទេស មិនមានមន្ទីរសន្តិបាលណាមួយបានកម្ទេចសមាជិកមជ្ឈិមបក្សទេ។ នេះជាបញ្ហាពិត បញ្ហានេះក៏ពិតដែរ។ បើតាមខ្ញុំវិភាគមន្ទីរសន្តិបាលទាំងអស់ត្រូវបានទទួលបញ្ជាឲ្យកម្ទេចមនុស្សដែលភាគច្រើនជាប្រជាជនស្លូតត្រង់ស្អាតស្អំ សុចរិត អស់ប្រមាណមួយលាននាក់។ ខ្ញុំមិនជឿទាល់តែសោះថា មនុស្សជាងមួយលាននាក់ នេះមានបាតដៃ ប្រលាក់ឈាម ដូចកម្មាភិបាលមជ្ឈិមរបស់ ប៉ុល ពត។ នឹកដល់បញ្ហានេះ ខ្ញុំតក់ស្លុតណាស់។

៨១) មនុស្សនៅតាមភូមិភាគ ភាគច្រើនត្រូវបានបញ្ជូនមកស-២១ ក្នុងនោះមានទាំងប្រធានមន្ទីរសន្តិបាលផង នេះជាការពិត។ មូលហេតុមកពី ប៉ុល ពត មានបំណងចង់យកព័ត៌មាននៅតាមភូមិភាគនិយាយឲ្យចំ គឺតាមដានលេខាភាគនានា ដែល ពត មិនទុកចិត្ត។ មនុស្សដែលបញ្ជូនចេញពីភូមិភាគមានខ្លះមកដោយសារ ប៉ុល ពត ទាមទារតាមចម្លើយចេញមកពីស-២១ តែក៏អាចមានខ្លះទៀតដែល ប៉ុល ពត ទាមទារតាមចម្លើយដែលភូមិភាគជូនមក។

ទន្ទឹមនេះ តាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ គ្មានលេខាភាគណាមានអំណាចទាមទារឲ្យលេខាបក្ស ឬលេខាភាគផ្សេងទៀតបញ្ជូនទៅឲ្យខ្លួនបានទេ។ ការប្លែកគ្នារវាងស-២១ និងមន្ទីរសន្តិ-បាលផ្សេងទៀត វាចេញមកពីអំណាចទាំងអស់ត្រូវបានប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃលេខាបក្ស។ គឺពិតមិនមែនជាអំណាចរបស់ប្រធានស-២១ ទៅលើប្រធានមន្ទីរសន្តិបាលទាំង១៩៥ នោះទេ។

៨២) លើសពីនេះទៅទៀត ខ្ញុំសង្កេតឃើញថា នៅជនបទមានរូបភាពមួយប្លែកពីស-២១ គឺមន្ទីរ

សន្តិបាលតម្រូវឲ្យទទួលយកមនុស្សមកទុកមកមួយរយៈ ដើម្បីឲ្យមនុស្សអស់នេះឃើញសព្វគ្រប់ ទើបខាងលើឲ្យចេញទៅវិញ។ ខ្ញុំសរសេរនេះ គឺសរុបតាមរបាយការណ៍ដែលភ្នាក់ងាររបស់សហចៅក្រមស៊ើបសួរចុះទៅជនបទ ចងក្រង និងប្រមូលបាន។ ខ្ញុំសន្និដ្ឋានថា នេះជារូបភាពព្រមាន ដូចគ្នានិងការដែលបក្សឲ្យសាក្សី KW-30 ទាំងនៅក្នុងម-១៣ មួយរយៈ រួចទើបបក្សបញ្ជូនទៅពោធិ៍សាត់ ទៅរស់នៅទីនោះក្នុងឋានៈជាពាក់កណ្តាលអ្នកទោស។ ខ្ញុំចាប់អារម្មណ៍ថា ប្រហែលជានៅជនបទ បក្សប្រើរូបភាពនេះជំនួសរូបភាពព្រៃស របស់ស-២១។

[១១:៤៣:០៩]

៨៣) ឧក្រិដ្ឋកម្មនៅមន្ទីរស-២១។ រំឭកកាលបរិច្ឆេទខ្លះ ១៥ សីហា ១៩៧៥ សុន សេន ឧទ្ទេសនាមឲ្យមានការកកើតមន្ទីរស-២១។ ខែតុលា ឆ្នាំ១៩៧៥ ខ្ញុំបំពេញការងារនៅស-២១ ក្នុងឋានៈជាអនុប្រធាន។ ខែ៣ ឆ្នាំ១៩៧៦ ខ្ញុំឡើងធ្វើជាប្រធាន ៨៨។ ពីថ្ងៃ១៥ សីហា ឆ្នាំ១៩៧៥ ដល់ ខែតុលា ១៩៧៥ ការងារស្នូលរបស់ខ្ញុំ គឺដើរប្រមូលឯកសារពីផ្ទះអ្នកធំ និងពីគ្រឹះស្ថានសាធារណៈនៃរបប លន់ នល់។ ការពិនិត្យចម្លើយដែល៧០៣ គេសួរ និងលើកទិសការងារឲ្យគេសួរបន្តជាការងារដែលមេតម្រូវបន្ថែម ពិសេស គឺឯកសារ E5/2.1 ដែលជាចម្លើយរបស់ ស ភន។

៨៤) ខែតុលា ឆ្នាំ១៩៧៥ ដល់ ខែមីនា ១៩៧៦ រយៈកាលដែល ណាត ធ្វើប្រធាន។ ខ្ញុំចូលកាន់ការជាអនុប្រធាន។ មានពីរចំណុចដែលសូមបញ្ជាក់គឺៈ មួយ) ទាមទារទៅខាងតំបន់២៥ សុំចាប់អ្នកនេះ តាមដានអ្នកនោះជារបៀបធ្វើការរបស់ ណាត មិនមែនជារបៀបធ្វើការងាររបស់ខ្ញុំទេ។ នៅម-១៣ គ្មានបក្សឯណាអនុញ្ញាតឲ្យខ្ញុំទាក់ទងមូលដ្ឋានរបៀបនេះទេ។ ពីរ) តាមឯកសារដែលត្រូវបានបង្ហាញតាំងពីរយៈកាលស៊ើបសួរ តែសំខាន់ក្នុសវនាការដេញដោលនេះ ខ្ញុំបានវិភាគឃើញថា ណាត សម្រេចចាប់មនុស្សអត្តនោម័តិអស់ ៦២នាក់ អំពើនេះជាការល្មើសមាគ៌ា។ ខ្ញុំមានហេតុផលគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថា អង្គការចាប់អារម្មណ៍ ណាត ចំពោះបទល្មើសនេះមួយផងដែរ។

ចំណុចទាំងពីរខាងលើនេះ ខ្ញុំសូមបដិសេធមិនទទួលស្គាល់។

៨៥) ឧក្រិដ្ឋកម្មទៅលើជីវិតមនុស្សយ៉ាងតិចណាស់ ១២.៣៨០នាក់ ខ្ញុំនៅតែទទួលស្គាល់ និងទទួលស្គាល់ជារៀងរហូត។

៨៦) រូបភាពនិងទិដ្ឋភាពផ្សេងៗទៀតនៃឧក្រិដ្ឋកម្មរបស់ស-២១ ទាំងនៅភ្នំពេញ ទាំងនៅព្រៃស ទាំងនៅជើងឯក ដែលបានដេញដោលក្នុងអង្គសវនាការនេះរួចហើយ ខ្ញុំសូមគោរពជូនអង្គសវនាការ

វិភាគនិងសម្រេច។

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធានសូមអនុញ្ញាត សូមឲ្យជនជាប់ចោទបន្ថយល្បឿនតិចទាន ព្រោះអ្នកបកប្រែតាមមិនទាន់ទេ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ សូមបន្ថយល្បឿន និយាយឲ្យបានយឺតជាងនេះទៅបន្តិច ព្រោះអ្នកបកប្រែ បកអត់ទាន់ទេ។ ចាប់ពីចំណុចអំមិញ។

[១១:៤៥:00]

**ជនជាប់ចោទ៖**

**អំពីគោលជំហរ និងអាកប្បកិរិយារបស់ខ្ញុំ**

**I) ចំពោះប្រជាជនកម្ពុជាទូទាំងប្រទេស**

មុនថ្ងៃជម្នះរបស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជាបានប្រកាសជាឱឡារិកថា នឹងកាត់ទោសតែជនមហាក្បត់តែប្រាំពីរនាក់ទេ។ ជាក់ស្តែង បក្សបានជម្លៀសប្រជាជនទាំងបង្ខំ ព្រមទាំងបានសម្លាប់មនុស្សរាប់សែននាក់។ គឺមនុស្សដែលមិនបានប្រព្រឹត្តបទល្មើសអ្វីក្រោយ ១៧ មេសា សោះ។ ការកាប់សម្លាប់បានបន្តម្តងហើយម្តងទៀត ឥតស្រាកស្រាន្តរហូតអស់ជាងមួយលាននាក់។ ក្នុងចំណោមប្រជាជនក្រៅជួរ គេកាប់សម្លាប់អ្នកណាដែលពុំព្រមដាក់ខ្លួនឲ្យទៅជាកសិករ កម្មករ ឬក៏ធ្វើទៅពុំរួច។ រីឯអ្នកនៅក្នុងជួរវិញ គេចាប់ចងកាប់សម្លាប់បក្ខជនខ្សែផ្សេង ដែលមិនមែនជាខ្សែរបស់គេ ដើម្បីដាក់កម្លាំងគេជំនួសវិញ។ មហាវិនាសកម្ម ទាំងក្នុងជួរ និងក្រៅជួរ ពិតជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាតែម្នាក់ឯងគត់។

ខ្ញុំនៅតែស្មោះត្រង់ និងសេចក្តីប្រកាសរបស់ខ្ញុំ ក្នុងអង្គសវនការនេះ ដែលខ្ញុំបានអះអាងថា ប៉ុល ពត ប៊ានភ្លើតភ្លើនលើកមាគ៌ាមហាឧក្រិដ្ឋយ៉ាងនេះ គឺមកពីគាត់អាងលើកម្លាំង ជាពិសេស គឺកម្លាំងបក្សដែលមានកម្លាំងបក្ខជនរាប់ម៉ឺននាក់ស្តាប់បញ្ជាគាត់។ ខ្ញុំនៅតែទទួលស្គាល់ថា ក្នុងចំណោមកម្លាំងទាំងអស់នេះរបស់ ប៉ុល ពត មានខ្ញុំម្នាក់។ ក្នុងស្មារតីនេះហើយ ដែលខ្ញុំសូមទទួលខុសត្រូវខាងផ្លូវចិត្តចំពោះប្រជាជនកម្ពុជាទូទាំងប្រទេសដែលបានស្លាប់បាត់បង់ជីវិតពី ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ ខ្ញុំពិតជាមានវិប្បដិសារីយ៉ាងធ្ងន់ធ្ងរ និងតក់ស្លុតឥតឧបមាចំពោះមហាវិនាសកម្មនេះ។

ខ្ញុំយល់ថា ខ្ញុំយល់ច្បាស់ថា ទ្រឹស្តីមនោគមវិជ្ជាណាក៏ដោយ ដែលនិយាយអំពីស្នេហាប្រជាជន ទៅតាមទស្សនៈវណ្ណៈ និងតស៊ូវណ្ណៈ ពិតជានាំឲ្យហិនហោចខ្លោចផ្សាកទីបំផុតគ្មាន។ ខ្ញុំនៅតែប្រកាន់ថា ការសម្រេចជ្រើសរើសផ្លូវដើរ គឺសម្រេចតែមួយដង្ហើមទេ បើខុស គឺឈឺចាប់ខ្លោចផ្សាពោរពេញទៅដោយវិប្បដិសារីអស់មួយជីវិត។

ជំនឿដែលជឿថា បានរួមចំណែករំដោះជាតិ ប្រជាជន បម្រើប្រជាជន ម្ល៉ោះហើយបានឧទ្ទិសកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ព្រមទាំងបានលះបង់អ្វីៗទាំងអស់ រហូតដល់ត្រៀមលះបង់អាយុជីវិត ដើម្បីជាតិប្រជាជន តែបែរជាធ្លាក់ខ្លួនក្នុងអង្គការឧក្រិដ្ឋមួយ ដែលកម្ទេចប្រជាជនខ្លួនឯងយ៉ាងរង្គោះរង្គាល និងដកខ្លួនថយក៏ថយមិនរួច ដូចស្ពឺមួយគ្រាប់ក្នុងតួម៉ាស៊ីនដែលកំពុងដើរ។

[១១:៤៦:២២]

**II) ចំពោះជនរងគ្រោះនៅស-២១ និងក្រុមគ្រួសារ**

ខ្ញុំនៅតែប្រកាសទទួលខុសត្រូវតែម្នាក់ឯងគត់ លើការបាត់បង់អាយុជីវិតយ៉ាងតិច១២.៣៨០នាក់ អស់លោកទាំងអស់នេះមុននឹងស្លាប់ទៅពិតជាបានរងទុក្ខវេទនាដ៏ភ្មុំរ៉ៃ និងអមនុស្សធម៌រាប់មិនអស់។ ខ្ញុំនៅតែសុំខមាទោសចំពោះវិញ្ញាណក្ខន្ធនៃអ្នកដែលស្លាប់បាត់បង់ទៅ ដោយសេចក្តីគោរពលំអុតលំឱនបំផុត។ ខ្ញុំបានអធិដ្ឋានចំពោះព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់វិញ្ញាណក្ខន្ធទាំងអស់នោះ ដោយព្រះទ័យអនុគ្រោះ។ ចំពោះអ្នកដែលរួចជីវិតផុតពីសេចក្តីស្លាប់ ខ្ញុំនៅតែទទួលស្គាល់ថា ឧក្រិដ្ឋកម្មទាំងអស់របស់ស-២១ ទៅលើអស់លោក ទទួលស្គាល់ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត ចំពោះក្រុមគ្រួសារជនរងគ្រោះ ខ្ញុំនៅតែប្រកាន់អាកប្បកិរិយាឱនលំទោន សូមអនុញ្ញាតទុកទ្វារសូមទោសឲ្យនៅចំហហើយនិងសូមរំលែកទុក្ខសោកដ៏សែនខ្លោចផ្សារភ្មុំរ៉ៃរបស់អស់លោកគ្រប់ពេលវេលា។

**III) ដើម្បីសម្តែងវិប្បដិសារីដ៏សែនចុកចាប់ទាំងអស់នេះ**

ខ្ញុំបានសហការពេញទំហឹងជាមួយតុលាការដោយស្មោះត្រង់ និងគ្រប់ពេលវេលា អស់ចំនួន១០ឆ្នាំ ៦ខែ ១៧ខែ រួចមកហើយ ទាំងក្នុងរយៈកាលស៊ើបសួរ រួមទាំងការស៊ើបសួរនៅតុលាការយោធាផងទាំងក្នុងរយៈកាលសវនាការនេះផង។ ចុងបំផុត ខ្ញុំបានលើកសំណូមពរដោយសុទ្ធចិត្តចំពោះអ្នកជំនាញខាងចិត្តសាស្ត្រ ដើម្បីយល់ថា ខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យមនុស្សជាតិទាំងមូល លោកទទួលស្គាល់ខ្ញុំជាមនុស្សម្នាឡើងវិញ? ដើម្បីរួមចំណែករំលែកទុក្ខសោករបស់ប្រជាជនកម្ពុជា ខ្ញុំសូមសន្យាថា ទៅថ្ងៃមុខទោះជាក្នុងករណីណាក៏ដោយ ខ្ញុំនឹងធ្វើអ្វីៗទាំងអស់ដែលប្រជាជនខ្ញុំត្រូវការ ដើម្បីប្រជាជនខ្ញុំ សូម

តុលាការមេត្តាពិចារណា និងសម្រេចសេចក្តីលើបញ្ហាបន្ថែមនេះ ដោយយោបល់អនុគ្រោះ។

ធ្វើនៅថ្ងៃទី២៣ វិច្ឆិកា ២០០៩, ហត្ថលេខា,កាំង ហ្គេកអ៊ាវ ហៅ ឌុច។

[១១:៥២:១៥]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព, ខ្ញុំអាននេះ គឺអានតែអត្ថបទសុទ្ធ។ ប៉ុន្តែ នៅក្នុងអត្ថបទរបស់ខ្ញុំមានកំណត់ចុងទំព័រ ចំនួន៣៤ ដែលខ្ញុំសូមអានកំណត់ចុងទំព័រនេះម្តងមួយៗជូន។

១) កំណត់ចុងទំព័រលេខ១ កម្លាំងបដិវត្តន៍ គឺកងទ័ព កងឈ្លប និងខ្សែត្រៀម ប្រជាជន និងសេនាជនតំបន់រំដោះ។

២) មនុស្សប្រាំបីនាក់ ដែល វន វ៉េត យល់ព្រមដោះលែង មកពីគាត់ជឿថា មិនមែនខ្មាំង។

៣) ទីមួយ គឺមន្ទីរនគរបាលតំបន់២៥ គ្រប់គ្រងដោយ ម៉ឹង សំណាង ហៅ គេង ឈ្មោះមន្ទីរ ១៥។ ទីពីរ គឺមន្ទីរនគរបាលតំបន់៣២ ភូមិភាគនិរតីចាស់គ្រប់គ្រងដោយ តាំង ខែត ហៅ ខាន់ ទីបី គឺមន្ទីរនគរបាលភូមិភាគនិរតី គ្រប់គ្រងដោយកម្មាភិបាលខ្មែរមកពីហាណូយ ដែល ម៉ុក លេខានិរតីចាស់រំសាយចាស់មុនកំណើត ម-១៣។

៤) ប្រជាជនមូលដ្ឋានបង្អែក គឺប្រជាជនដែលឧបត្ថម្ភបដិវត្តន៍តាំងពីមុនរដ្ឋប្រហារ ១៨ មីនា។

៥) ចំនួនអ្នកស្លាប់មិនច្បាស់ ព្រោះគេលាក់។

៦) ក្នុងនេះមានពីរនាក់ឆ្លើយដាក់ ស ភន អភិបាលរងខណ្ឌដូនពេញនារបប លន់ នល់ បានចាត់តាំងគេឲ្យចូលមកបង្កប់។ សូមអានឯកសារ E5/2.1 និង E5/2.29 បន្ថែម។

៧) មុនរដ្ឋប្រហារ ១៨ មីនា សក្តិ៣ សេរី សយ ជាមេបញ្ជាការ និងជាចៅហ្វាយស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ មុនរដ្ឋប្រហារបុរសនេះ រស់ដោយសារល្បែងស៊ីសង។

៨) ម៉្យាងទៀត ប្រពន្ធរបស់បុរសនេះជាប្អូនស្រីបង្កើតរបស់មេឃុំ ឃុំអមលាំងម្នាក់ ដែលមានអំណាចពិតប្រាកដ។ គេទាំងពីរនាក់ជឿថា បុរសនេះឡើងចុះផ្ទះ សេរី សយ ញឹកញាប់ ហើយជាអ្នកយកការណ៍របស់ សេរី សយ តាំងពីពេលនេះមក។

៩) ខ្លឹមសារនៃសេចក្តីសារភាពនេះ បានធ្វើឲ្យខាងលើពេញចិត្ត។ ប៉ុន និង ខ្ញុំ ជឿថាខ្លឹមសារផែនការ ដែលសារភាពអាចពិត ៥០ភាគរយ ដូចជាយុទ្ធវិធីសម្លាប់កុម្មុយនីស្ត ដោយចាក់ថ្នាំតាមសរសៃឈាមជាដើម។ ឈ្មោះអ្នកបង្រៀនបុរសនេះ ខ្ញុំជឿថាពិតត្រឹមតែ៣០ភាគរយប៉ុណ្ណោះ ព្រោះ

គាត់ជាតំណាងតាំងពីសម័យសង្គមរាស្ត្រនិយម។

[១១:៥៥:00]

១០) អត្ថបទដែលសរសេរភ្ជាប់ឧបសម្ព័ន្ធ D21។ សូមអានវាក្យទី៥ និងទី៦។

១១) បុគ្គលនេះខ្ញុំមិនសួរចម្លើយទេ តែស្លាប់មុន១៧ មេសា ដោយខ្វះម្ហូបអាហារ និងជំងឺ។

១២) ឧបសម្ព័ន្ធរបស់ D21 ។ សូមអានវាក្យទី៦ ចំណុចទី៤ ERN 00146679។

១៣) ឧបសម្ព័ន្ធ D24 ។ សូមអាចវាក្យទី៥ ចំណុចនៅនិរតី ERN 00146678។

១៤) ឧបសម្ព័ន្ធ D21 ។ សូមអានវាក្យ៥ ចំណុចនៅនិរតី ERN 146678។

១៥) D11/9 ERN 00146481 ជាខ្មែរ។

១៦) ក្នុងសៀវភៅកំណត់ដៅរបស់ ម៉ម ណៃ ERN 00077661 ដល់ 00078056។ ខ្ញុំសូមអានលេខ ERN ម្តងទៀត។ ERN 00076 សុំទោសម្តងទៀត ERN 00077661 ដល់ 00078656។

១៧) សឹម ម៉េល ហៅ ម៉ាន អនុសេនាធំមួយរូបរបស់ស-២១ រាយការណ៍នៅពេលឆ្លើងជីវទស្សនៈបដិវត្តន៍ឆ្នាំសិក្សា១៩៧៥។

១៨) យកតាមសម្តី ខឹម ពីន លេខាកងពល៧០៣ បន្តពី ណាត។

១៩) យកតាមសម្តីមិត្ត ហ៊ឹ អនុលេខាស-២១ និងយកតាមសម្តី យូ ប៉េងគ្រី ហៅ ម៉ុន បុគ្គលិក ស-២១។

២០) ខ្ញុំជួប ចេង អន នៅផ្ទះប្រពន្ធគាត់នៅភូមិទន្លេស្ងួតក្នុងតំបន់១៥ ពេលនោះ ចេង អន អបអរ ហើយក៏សន្យាថាថ្ងៃ៣១ ឧសភា ជួបគ្នា។ ថ្ងៃ៣១ ឧសភា គាត់បានឲ្យនីរសារគាត់ជិះម៉ូតូទៅប្រាប់ខ្ញុំថាអង្គការមិនយល់ស្របទេ។

២១) នួង សួន ហៅ ជ័យ ត្រូវបានលេខាតំបន់ត្រូវបានបក្សដកមកកាន់ឃ្លាំងប្រាក់។ បន្ទាប់មកត្រូវបានចាត់តាំងខាងកសិកម្ម។ សុខ ប៊ុតចំរើន អនុលេខា និង ហួត សេ សមាជិកតាមដំណឹងគឺត្រូវបានម៉ុក ប្រគល់ឲ្យនគរបាលនិរតីថ្មី។ នៅ ផន ហៅ សុខ ត្រូវបាន សុន សេន ប្រគល់ឲ្យ ណាត។

២២) ឧទាហរណ៍គណៈកម្មាធិការបក្សក្រសួងថាមពល ដំបូងចាត់តាំង ណុប មឿន ហៅ កៅ រិត ជាលេខា បន្ទាប់មកដក កៅ រិត ទៅធ្វើលេខាពាណិជ្ជកម្មដាក់ ឆាយ គឹមហ៊ែរ ហៅ ហុក ជាលេខាថាមពល ណាត អតីតលេខា ស-២១ ត្រូវបានហាមមិនឲ្យក្តាប់កម្លាំង ទំព័រទី៤។

២៣) វេជ្ជបណ្ឌិត រ័ត្ន គត់ សាស្ត្រាចារ្យមហាបរិញ្ញា ទិត ម៉ម អធិការនគរបាល ឈិត អ៊ីវ

ហៅ ឆាត សក្តិពីរ សុង ហាក់ ដែលពួកកម្មាភិបាលច្រឡំថា សុង សាក់ ម្ចាស់អតីតធនាការភ្នំពេញ សុទ្ធតែមានឈ្មោះក្នុងបញ្ជី *អេសថ្វេនធីវ័នព្រីហ្សិនណឺលីស*។

[១១:៥៩:៣៥]

២៤) អចិន្ត្រៃយ៍ភាគ គឺសំដៅលេខាភាគ ដោយភូមិភាគនានាមានការវិវត្តន៍។ សុំលម្អិតដូចតទៅ ព្លិសាន យ៉ា ដែល នួន ជា ទទួលខុសត្រូវក្រោយពេលចាប់ យា នៅថ្ងៃ២០ ខែកញ្ញា ១៩៧៦។ បូព៌ា ភឹម ដែល នួន ជា ទទួលខុសត្រូវក្រោយពេល សោ ភឹម ធ្វើអត្តឃាត។ និរតីថ្មី ម៉ុក។ ស៊ី បស្ចិម បន្ទាប់ពីចាប់ ស៊ី នៅខែ៤ ឆ្នាំ១៩៧៨ ម៉ុក ឡើងជាលេខានិរតីថ្មីផង បស្ចិមផង។ ពាយ័ព្យ ញឹម ត្រូវចាប់ប្រហែលក្នុងខែឧសភា ១៩៧៨ ម៉ុក ឡើងជាលេខាពាយព្យមួយជាន់ទៀត។ ឧត្តរថ្មី សែ បន្ទាប់ពីចាប់ សែ ថ្ងៃ១១ ខែតុលាការ ១៩៧៨ ម៉ុក ជាលេខានិរតី បស្ចិម ពាយ័ព្យ និងឧត្តរថ្មី ភូមិភាគកណ្តាល កែ ពក។

២៥) D49 ទំព័រ៥ កំណត់ហេតុសួរចម្លើយ ខៀវ សំផន ថ្ងៃ១៤ ខែ១២ ០៧ សំណុំរឿងលេខ ០០២។ ប្រធានមន្ទីរភាគដែលជាប្អូនថ្លៃរបស់ ស៊ី ឈ្មោះ សួន ឈ្មោះពេញលេញខ្ញុំមិនស្គាល់ទេ។ ប្រធានមន្ទីរនគរបាលភូមិភាគបស្ចិមឈ្មោះ ម៉ម រឿន ហៅ វី មនុស្សក្នុងស្រុកភូមិជាមួយប្រពន្ធខ្ញុំ។

បំណងរបស់ ស៊ី ក្នុងការរើសរុះកម្លាំងរបស់ ប៉ាល់ លេចភេទឲ្យគេសម្គាល់បានច្រើនណាស់ ជាពិសេសក្នុងសន្និបាទភាគដែល ប៉ុល ពត ចុះទៅធ្វើអធិបតី ស៊ី បាននិយាយក្នុងសេចក្តីរាយការណ៍សរុបការងារថាកុំឲ្យឃើញតែកូនក្ដួយខ្លួនឯង។ សេចក្តីរាយការណ៍នេះចុះក្នុងទស្សនាវដ្តីទង់បដិវត្ត។

២៨) នៅពេលចាប់ ញឹម គេមិនទាន់ចាប់ គង់ សុផល ហៅ កឹ ទេ កឹ ចាប់ជាមួយ វន វ៉េត នៅមន្ទីរ៨៧០ ថ្ងៃ២ ខែវិច្ឆិកា ១៩៧៨។ ម្យ៉ាងទៀត តាមដំណឹងដែលខ្ញុំទើបបានឮ ខ្ញុំឮថាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យបានចាប់អាវុធតស៊ូការពារកម្លាំងខ្លួន បានរហូតដល់ពេលកងទ័ពវៀតណាមចូលទៅដល់បានចាប់ដៃគ្នាតស៊ូប្រឆាំងនឹង ប៉ុល ពត តទៅទៀត។ ខ្ញុំគ្រាន់តែកត់ចំណាំព័ត៌មាននេះទុក។

២៩) គិតតាមពេលដែល សុខ ក្នុល ហៅ ពាម ប្រធានមន្ទីរភាគបូព៌ាមកដល់ស-២១ថ្ងៃ៥ មិថុនា ១៩៧៨។

៣០) យកតាមសម្តីមិត្ត លីន ជនជាតិភាគតិចគណៈកម្មាធិការស-៧១។

៣១) លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ត្រង់មាត្រា២១ និង២២។

៣២) យកតាមការយល់ដឹងផ្ទាល់ខ្លួន និងបទសម្ភាសន៍ អៀង សារី ជាមួយនឹង ស្ទីវ ហេដឌ័រ

ទំព័រ៥៤ សម្ភាសន៍ថ្ងៃ១៧ ខែធ្នូ ១៩៨៦។

៣៣) ឈ្មោះសមាជិកមជ្ឈិម ដែលខ្ញុំធ្លាប់ឮគឺ ខៀវ សំផន, ពក, ប៉ាល់, សារុន, សំ ប៊ិត, មាស មុត, ស៊្វ ម៉េត និង សឿង។

[១២:០៣:៥៣]

លោកប្រធានជាទីគោរព, ខ្ញុំអានចប់ហើយឯកសារនេះ ខ្ញុំសូមលើកសំណូមពរមួយ គឺគោរពជូនឯកសារនេះជូនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមទទួលយកនូវឯកសារ សេចក្តីថ្លែងបិទកិច្ចពិភាក្សាដេញដោលរបស់ជនជាប់ចោទដែលបានធ្វើការថ្លែងរួចហើយ រួមទាំងឯកសារភ្ជាប់ជាមួយតាមការស្នើសុំនេះ។

លោក ផារី យកឯកសារពីជនជាប់ចោទ ដើម្បីរៀបចំដាក់បញ្ចូលទៅក្នុងសំណុំរឿង។

ឥឡូវនេះដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ហើយអង្គជំនុំជម្រះប្រកាសឈប់សម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ និងសាមនាទីរសៀលនេះអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទ ទៅកាន់កន្លែងសម្រាកឬក៏នាំទៅកាន់មន្ទីរឃាំង ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាកិច្ចបន្តនេះសូមអញ្ជើញមេធាវី ការពារក្តីឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន, សូមគោរពលោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិ។ សូមគោរពអង្គសវនាការទាំងមូល។ យើងខ្ញុំជាមេធាវីការពារជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ តទៅនេះចំពោះឃ្លាថា “ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦” ដោយឃ្លានេះវែង ហើយត្រូវ ប្រើឃ្លានេះជាញឹកញាប់ ដូច្នេះចាប់ពីពេលនេះតទៅ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានថា ប្រើឃ្លាឱ្យខ្លី គឺប្រើឃ្លាថា “ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិតែប៉ុណ្ណោះ”។

ជាបឋម ខ្ញុំសូមអនុញ្ញាតពីតុលាការដើម្បីជម្រាបជនរួមជាតិ ក៏ដូចជាអង្គសវនាការទាំងមូលឱ្យបានជ្រាប បានយល់ និងមានអធ្យាស្រ័យចំពោះមេធាវីការពារជនជាប់ចោទ ព្រោះភារកិច្ចរបស់មេធាវីការពារជនជាប់ចោទ ពិតជាមិនបម្រើសំណូមពរ មិនបម្រើផលប្រយោជន៍ឱ្យជនរួមជាតិ ដែលមានជីដូនជីតា ម្តាយឪពុក បងប្អូន កូនចៅ ញាតិមិត្ត ដែលបានបាត់បង់ជីវិតយ៉ាងវេទនា និងអយុត្តិធម៌បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះទេ។

សូមបងប្អូនជនរួមជាតិទាំងអស់មេត្តាយោគយល់ និងមានអធ្យាស្រ័យដល់យើងខ្ញុំជាមេធាវីការពារជនជាប់ចោទ ហើយយើងខ្ញុំក៏សូមចូលរួមចូលរួមមរណទុក្ខយ៉ាងក្រៀមក្រំបំផុត និងសូមបួងសួងឱ្យវិញ្ញាណក្ខន្ធបងប្អូនទាំងនោះបានទៅកាន់នៅទីដ៏សែនសុខកុំបីឃ្លាំងឃ្លាតឡើយ។

តុលាការជាទីគោរព, ក្រោយថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្រ១៧ មេសា ១៩៧៥ គួរណាស់តែប្រជាជនកម្ពុជា បានឡើងកាន់កាប់ជោគវាសនាជាតិខ្លួនដោយខ្លួនឯង លែងមានចក្រពត្តិនិយមណា លែងមានអាណានិគមចាស់ថ្មីណា លែងមានអនុត្តរភាពវាទីនិយមណា មកចាត់ចែងវាសនាជាតិខ្លួនជួសខ្លួនទៀតឡើយ។

[១៣:៣៦:២៦]

ថ្ងៃជ័យជម្នះនេះ ប្រជាជនកម្ពុជាសង្ឃឹមថា ខ្លួនពិតជាបានរស់នៅក្នុងសុខសន្តិភាព ឯករាជ្យ និងសេរីភាព ដើម្បីកសាងជាតិមាតុភូមិ ដែលធ្លាប់មានអរិយធម៌ដ៏ល្បីល្បាញនោះឡើងវិញ។ ពិសេសប្រជាជននៅរដ្ឋធានីភ្នំពេញ បានត្រេកអរទទួលស្វាគមន៍អបអរសាទរនិងជ័យជម្នះនេះដោយញញឹម ហើយសង្ឃឹមថា

ខ្មែរឈប់បង្ហូរឈាមខ្មែរទៀតហើយ ខ្មែរពិតជាបានរស់នៅដោយមានសាមគ្គីភាពរឹងមាំ ចាក់ស្រេះយ៉ាងស្អិតរមួតលើមាតុភូមិអង្គរជាទីស្រឡាញ់របស់ខ្លួន។

តែប៉ុន្មាននាទីប៉ុណ្ណោះ សេចក្តីសង្ឃឹមទាំងប៉ុន្មានត្រូវរលាយហិនហោច ខ្ទេចខ្ទីរគ្មានសល់ ដោយរំពេចនោះប្រទេសកម្ពុជាទាំងមូល បានក្លាយទៅជាមហាគុកឥតជញ្ជាំង។ ពួកខ្មែរក្រហមបានជម្លៀសប្រជាជនពីទីក្រុង ពីទីរួមខេត្តនានាឱ្យទៅនៅជនបទ។ នៅតាមសហករណ៍នីមួយៗគ្មានវត្តអារាម គ្មានសាលារៀន គ្មានមន្ទីរពេទ្យ គ្មានផ្សារ។ល។ គឺមានតែការបង្ខិតបង្ខំឱ្យធ្វើការជាទម្ងន់ ដោយបង្អត់អាហារ មានទុក្ខភ័យ សោកនាដកម្ម វិនាសព្រាត់ប្រាស កាប់សម្លាប់រាល់ថ្ងៃ ឱ្យបងសម្លាប់ប្អូន កូនសម្លាប់ឪពុក ដោយគ្មានមេត្តាករុណា ដែលមនុស្សជាតិនាសតវត្សរ៍ទី២០នេះ គ្មាននរណាម្នាក់នឹកស្មានដល់។

ភ័ស្តុតាងជាក់ស្តែងនៃអំពើឧក្រិដ្ឋទាំងនោះបានបន្សល់ទុកនៅរហូតបច្ចុប្បន្នដូចជា៖

វាលពិឃាដ មានចំនួន៣៨៨កន្លែង ដែលមានរណ្តៅសាកសពរួមរហូតដល់១៩.៧៧៣ រណ្តៅ គឺក្នុងព្រះរាជាណាចក្រកម្ពុជា មាន១៧០ស្រុក ហើយស្រុកណាក៏មានរណ្តៅសាកសពរួមដែរ។ បូជនីយដ្ឋាន តម្កល់ឥដ្ឋិធាតុជនរងគ្រោះដែលបងប្អូននៅរស់បានកសាងឡើងមានចំនួន៨១កន្លែង។ មន្ទីរសន្តិសុខ ឬគុក ជាកន្លែងយកមនុស្សទៅកម្ទេចមាន១៩៦កន្លែង ដែលក្នុងចំនួននេះមានស-២១ ផងដែរ។

ខ្ញុំសូមអនុញ្ញាតជម្រាបកន្លែងនេះថា ការពិតស្រាវជ្រាវ អ្នកស្រាវជ្រាវមិនទាន់ស្រាវជ្រាវរកអស់នៅឡើយទេ។ ជាក់ស្តែង តាមខ្ញុំពិនិត្យឃើញថានៅខេត្តព្រៃវែងបាត់មន្ទីរសន្តិសុខនៅស្រុកបាភ្នំទាំងអស់ ដូចជា ដែលខ្ញុំស្គាល់ គុកជ្រួល នៅខាងកើតភ្នំឈើកាច់។ គុកលើកំពូលភ្នំឈើកាច់គេហៅថា អាហ្វីង គុកធំណាស់ គេហៅថាគុកតំបន់២៤ ក៏មិនឃើញមានដែរ។

[១៣:៤០:០៨]

អ៊ីចឹងយើងខ្ញុំពិនិត្យឃើញថា ក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ ប្រជាជនកម្ពុជាប្រមាណមួយលានប្រាំពីរសែននាក់ ត្រូវបានកាប់សម្លាប់ដោយអយុត្តិធម៌បំផុត។ ក្នុងអំឡុងពេលនោះ ពួកខ្មែរក្រហមបានបង្កើត មន្ទីរឃុំឃាំង និងគុករាប់រយកន្លែង ដែលបានរៀបចំឡើងតាមបែបផែនមួយស្រដៀងៗគ្នា គឺទីមួយ មានការចាប់ខ្លួន។ ទីពីរ ការឃុំខ្លួនរួចធ្វើទារុណកម្មដើម្បីសួរចម្លើយ។ ទីបី គឺការប្រហារជីវិត គឺគុកណាក៏ដូចជាគុកណាមានសភាពដូចគ្នាបែបនេះ។

កន្លងមក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ខ្លួនខ្មែរក្រហមឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានស-២១ ឬបច្ចុប្បន្នហៅថា គុកទួលស្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យយកមកធ្វើការកាត់សេចក្ដី។ ក្នុងចំណោមគុករាប់រយ ស-២១ ជាគុកធំជាងគេ និងសម្លាប់មនុស្សបានច្រើនជាងគេឬ បានជាចាប់ប្រធានស-២១ មកធ្វើការកាត់សេចក្ដីតែម្នាក់ឯង? រីឯប្រធានគុកដទៃទៀតកំពុងរស់នៅសោយសុខជួបជុំគ្រួសារ មានសេរីភាពបរិបូណ៌ មានគុកខ្លះបានសម្លាប់មនុស្សរាប់សិបដងលើសស-២១ ចុះហេតុអ្វីក៏ប្រធានគុកទាំងនោះបានរួចខ្លួន?

គុកនីមួយៗមានការធ្វើទារុណកម្មដូចគ្នា មានការកាប់សម្លាប់ដូចគ្នា ក្រោមបញ្ជាអង្គការតែមួយដូចគ្នា ហេតុអីក៏គេរួចខ្លួនទាំងអស់គ្នាមកជាប់តែ តាឌុច ម្នាក់ដែលស-២១ សម្លាប់បានតិចជាងគេយកមកកាត់សេចក្ដីតែម្នាក់ឯង មកទទួលថ្មបាក់តែម្នាក់ឯង នេះឬជាយុត្តិធម៌គំរូសម្រាប់តុលាការកម្ពុជា?

អង្គសវនាការជាទីគោរព, ក្រោយពីបានពិនិត្យយ៉ាងហ្មត់ចត់នូវរឿងក្ដី ក្រោយពីបានតាមដានស្ដាប់ដោយយកចិត្តទុកដាក់នូវចម្លើយសាក្សី និងអ្នកជំនាញផ្សេងៗ ហើយពិសេសក្រោយពីបានតាមដានស្ដាប់យ៉ាងយកចិត្តទុកដាក់បំផុតនូវសេចក្ដីសន្និដ្ឋានរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញារួចមក មេធាវីការពារសូមលើកឡើងនូវមតិមួយចំនួនជូនតុលាការក៏ដូចជាជូនអង្គសវនាការទាំងមូលធ្វើការពិចារណា ថ្លឹងថ្លែង រកយុត្តិធម៌តាមច្បាប់ដូចតទៅៈ

[១៣:៤៤:០០]

**អំពីអង្គច្បាប់**

ចំពោះការចោទប្រកាន់តាមច្បាប់ជាតិ ខ្ញុំសូមលើកអំពីអញ្ញត្រកម្ម។ ដោយអនុវត្តតាមវិធាន៨៩ អនុវិធាន១ ចំណុច ខ មេធាវីការពារសូមលើកឡើងនូវអញ្ញត្រកម្មទាក់ទងនឹងការរំលត់បណ្ដឹងអាជ្ញាដែលបានចោទប្រកាន់ជនជាប់ចោទ ពីបទឧក្រិដ្ឋកម្មតាមច្បាប់ជាតិថា ជនជាប់ចោទបានរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ តាមរយៈការប្រព្រឹត្តិបទល្មើសមនុស្សឃាតមាត្រា៥០១ និង៥០៦ និងបទល្មើសនៃការប្រព្រឹត្តិទារុណកម្មមាត្រា៥០០ និងបទល្មើសឧក្រិដ្ឋកម្មនានា ដែលបានចែង និងផ្ដន្ទាទោស ដោយមាត្រា៣(ថ្មី) ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ផ្ដន្ទាទោសលើបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តក្នុងសម័យកាលដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ។

**លោក វីលៀម ស្មីត៖**

សូមអនុញ្ញាតលោកប្រធាន អម្បាញ់មិញ ខ្ញុំអត់ទទួលបាននូវសំឡេងបកប្រែ។ ដូច្នេះហើយគឺខ្ញុំអត់បានស្តាប់ឮទៅលើចំណុចចុងក្រោយ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវី ចាប់ពីឃ្លាអំមិញម្តងទៀត ដើម្បីឲ្យអ្នកបកប្រែអ្នកស្តាប់បាន ហើយនិងបកប្រែបាន។ ហើយសូមឲ្យបន្ត។

**លោក ការ សាវុត្ថ៖**

ដែលបានចែង និងផ្តន្ទាទោសដោយមាត្រា៣(ថ្មី) ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ផ្តន្ទាទោសលើបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តក្នុងសម័យកាលដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យ។

បញ្ហានេះ មេធាវីការពារក្តីយល់ឃើញថា តាមរយៈមាត្រា៣ និងមាត្រា៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ហើយដែលឋិតក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានពន្យារពេលបន្ថែមសាមសិបឆ្នាំទៀត។ បញ្ហាដដែលនេះ មេធាវីការពារយល់ឃើញផងដែរថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រង់មាត្រា១០៩ បានចែងថា អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានថិរវេលាដប់ឆ្នាំចំពោះបទឧក្រិដ្ឋ។ ដូច្នេះមេធាវីការពារក្តីយល់ឃើញថា ផ្អែកតាមមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បានផុតរលត់អស់រយៈពេល ១៥ឆ្នាំ ៩ខែ ១៤ថ្ងៃ រួចទៅហើយ គិតមកដល់ពេលដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានអនុម័តកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ នោះ។

ខ្ញុំសូមអនុញ្ញាតជម្រាបបន្ថែមទៀតថា បញ្ហាអញ្ញត្រកម្មនេះ មេធាវីការពារក្តីបានធ្វើសារណាជូនតុលាការរួចហើយ សូមតុលាការមេត្តាពិចារណាតាមការគួរ។ ម្យ៉ាងទៀត យើងខ្ញុំពិនិត្យឃើញថាធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្មតាមច្បាប់ជាតិ មាត្រា៥០០ ចែងពីការធ្វើទារុណកម្ម ឯមាត្រា៥០១ និង ៥០៦ ចែងពីការធ្វើមនុស្សឃាត។ ដល់ទៅច្បាប់ អ.វ.ត.ក ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រង់មាត្រា៥(ថ្មី) ក៏បានចែងពីការធ្វើមនុស្សឃាត និងពីការធ្វើទារុណកម្មដែរ។ ដូច្នេះបទល្មើសឧក្រិដ្ឋកម្ម

តាមច្បាប់ជាតិ និងឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ មានធាតុផ្សំដូចគ្នា ឬក៏ថាត្រួតគ្នា ឬក៏ថាជាន់គ្នា គឺមានចែងពីការធ្វើទារុណកម្ម និងពីការធ្វើមនុស្សឃាតដូចគ្នា។

[១៣:៥០:៣១]

នេះជាហេតុផលបញ្ជាក់ច្បាស់ថា បើចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិហើយ គឺមិនបាច់ចោទប្រកាន់ពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិទៀតទេ។ ហេតុនេះ សូមតុលាការមេត្តាពិចារណា និងសម្រេចតាមឆន្ទានុសិទ្ធិ។

សេចក្តីសន្និដ្ឋាន មេធាវីការពារយល់ឃើញថា ជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនអាចត្រូវបានជំនុំជម្រះចំពោះបទឧក្រិដ្ឋទាំងឡាយណាតាមច្បាប់ជាតិបានឡើយ។ ដូច្នេះ ការសម្រេចណាមួយផ្ទុយពីនេះ គឺជាការរំលោភទៅលើវិធានអាជ្ញាបញ្ញោ ព្រោះអាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ សម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ត្រូវផុតរលត់អស់រយៈពេល១៥ឆ្នាំ ៩ខែ ១៤ថ្ងៃ រួចទៅហើយ ហើយក៏ជាការរំលោភទៅលើគោលការណ៍គ្រឹះស្តីពីអនុភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌផងដែរ។ ហេតុនេះមេធាវីការពារ សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាប្រកាស និងសម្រេចថា បទល្មើសមនុស្សឃាត និងការប្រព្រឹត្តិទារុណកម្ម ដូចមានចែងក្នុងមាត្រា៥០០, ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានផុតអាជ្ញាយុកាល។

ចំណុច ខ មេធាវីសូមលើកឡើងចំពោះការចោទប្រកាន់តាមច្បាប់អន្តរជាតិ អំពើឧក្រិដ្ឋកម្មសង្គ្រាម។ មេធាវីការពារយល់ឃើញថា ចំពោះអំពើហិង្សាយោធារវាងកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម គឺជារឿងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងរដ្ឋាភិបាលវៀតណាម ដែលបានបង្កើតជម្លោះនេះឡើង វាមិនមែនជារឿងដែលលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអ្នកបង្កើតជម្លោះនេះឡើងទេ។ ឯកងទ័ពវៀតណាម និងប្រជាជនវៀតណាមដែលបញ្ជូនមកកម្ទេចនៅស-២១ គឺបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិប-តេយ្យជាអ្នកសម្រេច មិនមែនលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច មានសិទ្ធិសម្រេចអំពីបញ្ហានេះទេ។

[១៣:៥៣:៤១]

មេធាវីការពារក្តីសូមរំឭកថា ឌុច មិនបានបដិសេធទាំងអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាមរបស់គាត់ ចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលបង្កឡើងដោយជម្លោះនោះទេ។ ទាក់ទងនឹងកាលបរិច្ឆេទពិតប្រាកដនៃថ្ងៃចាប់ផ្តើមជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជា

ប្រជាធិបតេយ្យនិងវៀតណាម មេធាវីការពារក្ដីពឹងផ្អែកទាំងស្រុងទៅលើគតិបណ្ឌិតរបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែមេធាវីការពារក្ដីសូមបញ្ជាក់ថា មានភាពស្រពេចស្រពិលពាក់ព័ន្ធនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ មុនចុងឆ្នាំ១៩៧៧។

ពាក់ព័ន្ធនឹងប្រធានបទដដែលនេះ មេធាវីការពារក្ដីសូមបញ្ជាក់ថា អ្នកជំនាញ ណាយ៉ាន់ ចាន់ដា ដោយផ្អែកលើបទសម្ភាសន៍នានារបស់គាត់ជាមួយមេដឹកនាំវៀតណាម បានគូសបញ្ជាក់នៅក្នុងអំឡុងពេលផ្ដល់សក្ខីកម្មរបស់គាត់ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា នៅឆ្នាំ១៩៧៧ អាជ្ញាធរក្រុងហាណូយ មិនមានបំណងធ្វើសង្គ្រាមពិតប្រាកដណាមួយទេ។ ក្រុងហាណូយ គ្រាន់តែចង់ផ្ដល់សញ្ញាមួយឱ្យខ្មែរក្រហមតែប៉ុណ្ណោះ។ ពោលគឺទើបតែនៅចុងឆ្នាំ១៩៧៧ទេ ដែលវៀតណាមបានធ្វើការសន្និ-ដ្ឋានថា វាមិនមែនជាការភ័ន្តច្រឡំរវាងគ្នា ឬបញ្ហាដំណោះស្រាយលើភាពមិនចុះសម្រុងមួយចំនួនពាក់ព័ន្ធនឹងព្រំដែននោះទេ។ ឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម ខាតរ៉ាយថ៍ លោក ណាយ៉ាន់ ចាន់ដា ក៏បានធ្វើការអះអាងផងដែរថា ការទម្លាក់គ្រាប់បែក ការវាយលុកលុយទ្រង់ទ្រាយធំរបស់កម្លាំងវៀតណាម ទើបតែកើតមានឡើងនៅអំឡុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៨ ប៉ុណ្ណោះ ពោលគឺនៅក្រោយការប្រកាសផ្ដាច់ទំនាក់ទំនងការទូត នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។

ដូច្នេះ ទោះយ៉ាងក្ដីមេធាវីការយល់ឃើញថា ជនជាប់ចោទទើបតែបានទទួលដំណឹងថាមានជម្លោះប្រដាប់អាវុធអន្តរជាតិរវាងរបបកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមចាប់ពីថ្ងៃប្រកាសផ្ដាច់ទំនាក់ទំនងការទូត នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ប៉ុណ្ណោះ។ មេធាវីការពារក្ដីសូមបញ្ជាក់ទៀតថា នៅក្នុងច្បាប់អន្តរជាតិ ការស្គាល់ព្រឹត្តិការណ៍នៃអង្គហេតុដែលបង្ហាញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ គឺជាការចំបាច់ក្នុងការរកឱ្យឃើញពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទឧក្រិដ្ឋសង្គ្រាម។

មេធាវីការពារក្ដីសូមបញ្ជាក់ថែមទៀតថា ក្នុងសេចក្ដីថ្លែងរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឌុច បានប្រាប់ថា គាត់មិនដែលបានដឹងអំពីទំនាស់ព្រំប្រទល់រវាងកម្ពុជានិងវៀតណាម មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។ អត្ថិភាពនៃជម្លោះបែបនេះ នៅក្នុងខេត្តមណ្ឌលគីរីទាក់ទងនឹងបន្ទាត់ប្រេវីយេ ត្រូវបានអ្នកជំនាញ ណាយ៉ាន់ ចាន់ដា បញ្ជាក់ទៀតថា ពិតជាបានកើតមានប្រាកដមែន។ លោកបានលើកឡើងផងដែរថា ទំនាស់ទាំងនេះ គឺគ្រាន់តែជាការលបវាយឆ្មក់គ្នាតាមបែបធម្មតារវាងប្រទេសទាំងពីរតែប៉ុណ្ណោះ តែមិនមែនជាការជម្លោះប្រដាប់អាវុធអន្តរជាតិ ក្នុងន័យដែលចែងដោយអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩នោះទេ។

[១៣:៥៩:០១]

ម្យ៉ាងទៀត មេធាវីការពារក្តីយក់ឃើញថា ពាក្យសម្តីរបស់ ឌុច ក៏គួរឲ្យជឿដែរ បើគិតពីការអនុវត្តដ៏ហ្មត់ចត់នូវគោលនយោបាយសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ហើយក៏គួរឲ្យជឿថែមទៀតដែរបើនិយាយពីបញ្ហាទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម។ លើសពីនេះទៅទៀត ពាក្យសម្តីរបស់ ឌុច ស្របគ្នានឹងពាក្យសម្តីរបស់សាក្សីឈ្មោះ សួស ធី ដែលសម័យនោះ សួស ធី លោកមានតួនាទីជាអ្នកចុះបញ្ជីឈ្មោះអ្នកទោសចូលស-២១។ សួស ធី បានអះអាងថា ក្នុងឆ្នាំ១៩៧៦ ឬក៏ ១៩៧៧ ពុំមានឈ្លើយសឹកជនជាតិវៀតណាមទេ គឺដល់ពេលមានជម្លោះប្រដាប់អាវុធផ្ទុះហើយទេ ទើបមានឈ្លើយសឹកវៀតណាមមកដល់ស-២១។ លើកពីនេះទៅទៀត សេចក្តីថ្លែងទាំងនេះមានខ្លឹមសារសមស្របនឹងបញ្ជីអ្នកទោសនៅស-២១ ដែលគេពិពណ៌នាថា ជាទាហានវៀតណាមនៅស-២១។ បញ្ជីនេះត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញានៅក្រោមលេខកូដ E68 ឧបសម្ព័ន្ធ២៨។

សេចក្តីថ្លែងទាំងនេះបង្ហាញថា ទំនងជាមានទាហានវៀតណាមតែពីរនាក់ប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន ហើយឃុំឃាំងនៅស-២១ មុនថ្ងៃ៣១ ខែធ្នូ ឆ្នាំ១៩៧៧។ អាស្រ័យហេតុនេះ ដោយសារគោលនយោបាយសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា និងដោយសារភាពស្ងាមស្ងាត់របស់ប្រទេសកម្ពុជា និងវៀតណាម ជុំវិញបញ្ហាអត្ថិភាព និងចរិតលក្ខណៈពិតនៃភាពតានតឹងរវាងប្រទេសទាំងពីរក៏ដូចជាភាពអវត្តមានរបស់ទាហានវៀតណាមនៅស-២១ មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧នោះ មេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាមិនបានបង្ហាញអ្វីឲ្យបានលើសពីវិមតិសង្ស័យដែលថា ឌុច បានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងប្រទេសទាំងពីរមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។

ចំពោះការរំលោភលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ១៩៤៩ គឺបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាអ្នករំលោភ មិនមែនលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទេ ព្រោះបក្សជាអ្នកដឹកនាំ បក្សជាអ្នកបញ្ជាឲ្យធ្វើ បក្សជាអ្នកទទួលខុសត្រូវ។ ឯកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានៅរស់បីនាក់ គឺ នួន ជា, អៀង សារី, និង ខៀវ សំផន ហើយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានបួននាក់នៅរស់មួយនាក់ គឺ អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារបរទេស។ ហេតុនេះ សូមឲ្យយករឿងជម្លោះប្រដាប់អាវុធនេះទៅដាក់ក្នុងសំណុំរឿងលេខ០០២ ទើបត្រឹមត្រូវ ព្រោះអ្នកទទួលខុសត្រូវនៅរស់នៅក្នុងសំណុំរឿងលេខ០០២ ឯ ឌុច គាត់មិនត្រូវទទួលថ្នបាក់ចំពោះអ្នកដែលបង្កើតជម្លោះប្រដាប់អាវុធនេះទេ។

[១៤:០២:០៨]

ចំណុចធំទីបី ខ្ញុំសូមលើកពីការទទួលខុសត្រូវ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់បង្កើតឲ្យមាន អ.វ.ត.ក។ យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ដែលគេហៅថាកិច្ចព្រមព្រៀងត្រង់មាត្រា១ បានចែងថា គោលបំណងរបស់កិច្ចព្រមព្រៀងនេះគឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប-តេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។

[១៤:០៥:០២]

យោងតាមមាត្រា១ នៃច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និយាយឲ្យខ្លីថាច្បាប់ អ.វ.ត.ក ចុះថ្ងៃទី២៧ ខែ១០ ២០០៤ បានចែងថា ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាប់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។

អ៊ីចឹងខ្ញុំសូមសង្កត់ធ្ងន់ថា ច្បាប់នៃការទោសមេដឹកនាំខ្មែរក្រហមមាត្រា១នេះ គឺគេឲ្យយកតែមេដឹកនាំពីរជំពូកទេមកកាត់ទោស។ ជំពូកទី១ គឺមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹង មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានប៉ុន្មាននាក់? សហព្រះរាជអាជ្ញាត្រូវចោទប្រកាន់ទាំងអស់ អ្នកណាស្លាប់សុំព្រះរាជអាជ្ញាសុំឲ្យតុលាការរំលត់បណ្ដឹងអាជ្ញា។

ជំពូកទីពីរ គឺជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ អ៊ីចឹង មានប៉ុន្មាននាក់ចោទប្រកាន់ទាំងអស់។ អ្នកណាស្លាប់ សហព្រះរាជអាជ្ញាសុំឲ្យតុលាការរំលត់បណ្ដឹងអាជ្ញា។ នេះជាភារកិច្ចរបស់សហព្រះរាជអាជ្ញា។ តែសហព្រះរាជអាជ្ញាមិនបានបំពេញភារកិច្ចនេះទេ។ សហព្រះរាជអាជ្ញាមិនគ្រាន់តែមិនបានបំពេញភារកិច្ចនេះប៉ុណ្ណោះទេ តែសហព្រះរាជអាជ្ញាអត់បានរាយមួយឈ្មោះ

ទេ ថាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានប៉ុន្មាននាក់។ សហព្រះរាជអាជ្ញាអត់ប៊ានថាទេ។ មិនដឹងអ្នកណាខ្លះទេ។

ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនោះ មានប៉ុន្មាននាក់ក៏សហព្រះរាជអាជ្ញាអត់បានរៀបរាប់ឈ្មោះដែរ។ បើវាមិនដឹងឈ្មោះទាំងអស់អ៊ីចឹង ចេះតែដើរចាប់ប៉ាតណាប៉ាតណឹក៏ហាក់ដូចជាមិនសមរម្យ។

[១៤:០៧:៥១]

ចំណុច ខ អំពីគោលបំណងនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម។ ការកាត់ទោសមេដឹកនាំខ្មែរក្រហម រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានគោលបំណងធំៗបីយ៉ាង៖ ទីមួយ ដើម្បីរកយុត្តិធម៌ជូនដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលនៅរស់សល់ពីការកាប់សម្លាប់។ អ៊ីចឹងអាក្នុងគោលបំណងទីមួយនេះ វិញ្ញាណក្ខន្ធដែលស្លាប់រាប់លាននាក់ ទាំង១៩៦ គុក អ្នកស្លាប់ គេទទួលយកបានលុះត្រាតែកាត់សេចក្តីនេះត្រឹមត្រូវយុត្តិធម៌ ចំជនក្នុងជំពូកទីមួយ និងជំពូកទីពីរ។ បើយកអ្នកខុសពីនេះមកកាត់សេចក្តី នោះវិញ្ញាណក្ខន្ធអ្នកទាំងនោះមិនអាចទទួលយកបានទេ។

គោលបំណងទីពីររបស់រដ្ឋាភិបាល គឺថែរក្សាសន្តិភាព ស្ថិរភាពនៃនយោបាយ និងឯកភាពជាតិ គឺមានន័យថាដើម្បីកុំឲ្យរបបដ៏ឃោឃៅនេះកើតមាននៅលើទឹកទីកម្ពុជាជាលើកទីពីរទៀត ហើយគោលបំណងទីបី គឺរដ្ឋាភិបាលឲ្យគោរពអធិបតេយ្យភាពជាតិខ្មែរ។

ឥឡូវ ខ្ញុំសូមលើកអំពីមេដឹកនាំជាប់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ។ តើអ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ? ខ្ញុំបាទសូមអនុញ្ញាតជម្រាបត្រង់ទំព័រទី៥៤ កថាខណ្ឌ១២៤-- ២៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ បានបញ្ជាក់យ៉ាងច្បាស់ថា ការស៊ើបសួរបានបង្ហាញថា ទោះជា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ពាក់ព័ន្ធនឹងមាត្រា១(ថ្មី) នៃច្បាប់បង្កើតឲ្យមាន អ.វ.ត.ក ខាងលើ ឃើញថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ព្រោះមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមានគ្នាប្រាំពីរនាក់គឺ៖

១) ប៉ុល ពត ជាលេខា, ២) នួន ជា អនុលេខាទីមួយ, ៣) សោ យ៉ាន់ ហៅ ភឹម ជាអនុលេខាទីពីរ, ៤) អ៊ីង ធឿន ហៅ ម៉ុក ជាអនុលេខាទីបី, ៥) អៀង សារី ហៅ បងវ៉ាន់ ជាសមាជិក

ពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍, ៦) វន វ៉េត ហៅ វ៉ន ជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍, ៨) សុន សេន ហៅ បងខៀវ ជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍។

[១៤:១១:៣៦]

ខ្ញុំបាទសូមអនុញ្ញាតជម្រាបថា ហេតុអីបានជាយើងថាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ហ្នឹងយកអចិន្ត្រៃយ៍ទាំងប្រាំពីរនាក់ហ្នឹង។ ពីព្រោះក្នុងរបបកុម្មុយនីស្តគ្មានអាណាធំជាងបក្សទេ គឺបក្សដឹកនាំ បក្សមិនឲ្យធ្វើ គឺគ្មានអាណាប៊ានធ្វើទេ តែប៊ានធ្វើគឺកំបុតកអ៊ីចឹងតែម្តង។ អ៊ីចឹងហើយបានជានៅក្នុងហ្នឹង ក្នុងរបបបក្សកុម្មុយនីស្តកម្ពុជាហ្នឹង អ្នកដែលធំ អ្នកដែលជាម្ចាស់មាគ៌ាឧក្រិដ្ឋកម្មហ្នឹងគឺមានតែប្រាំពីរនាក់នេះឯង ដែលជាគណៈអចិន្ត្រៃយ៍។ ហ្នឹងមានតែប្រាំពីរនាក់ហ្នឹង។

ដូច្នេះ ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យដែលមានចំនួនប្រាំពីររូបនេះគឺពុំមានឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ទេ។ ជារួមក្នុងចំណោមឯកសារទាំងអស់ដែលសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតចាត់ទុកជាបានការ សុទ្ធតែបានបង្ហាញថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមានឈ្មោះតែប្រាំពីរនាក់នេះឯង។ ហើយក៏គ្មានឯកសារណាមួយបង្ហាញថាមានឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនោះទេ។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលជាម្ចាស់មាគ៌ាឧក្រិដ្ឋកម្មមានគ្នាតែប្រាំពីរនាក់ លុះមកដល់ឆ្នាំ១៩៨៧ អានេះតាមឯកសារនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដោយ *ឌីស៊ីខេម (DC-Cam)* គឺទើបតែនៅឆ្នាំ១៩៧៧ នេះ ទើបសម្រេចបន្ថែមបីនាក់ទៀត គឺ កែ ពក, ខៀវ សំផន និង រស់ ញឹម។ អ៊ីចឹង ទោះបីថែមបីនាក់ទៀត ក៏គ្មានឈ្មោះ ឌុច ដែរ។

ដូច្នេះ ការចោទប្រកាន់ទាំងឡាយណា ដែលថា ឌុច ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ គឺជាការភ័ន្តច្រឡំ។ មេធាវីការពារមិនអាចទទួលបាន ទទួលយកបានជាដាច់ខាត។

អំពីជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ តើអ្នកណាខ្លះជាជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភទាំងនោះ? ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ គឺមានពីររយៈកាល គឺខ្ញុំចែកជាពីររយៈកាល។

[១៤:១៤:៤២]

រយៈកាលទីមួយ ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៣០ មីនា ១៩៧៦។ ហ្នឹងជារយៈកាលទីមួយ ១៧ មេសា ៧៥ ដល់ ៣០ មីនា ៧៦។ ព្រោះនៅថ្ងៃទី១៧ មេសា ១៩៧៥ ពេលកងទ័ពខ្មែរក្រហមចូលដល់ក្រុងភ្នំពេញភ្លាម ឧក្រិដ្ឋកម្មក៏ចាប់ផ្ដើមភ្លាម។ ដោយមានរូបចំហ គឺជម្លៀសប្រជាជន ដោយប្រើកម្លាំងកម្រោល និងរូបភាពលាក់បិទបាំង គឺលួចសម្លាប់ស្ងាត់ៗ ក្នុងទិសដៅច្បាស់លាស់មួយ គឺធ្វើឲ្យប្រជាជនទាំងមូលឲ្យទៅជាទាសករ នៅតាមសហករណ៍ តាមផែនការដែលបានគ្រោងទុក ដូចដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ កក្កដា ២០០៨ ត្រង់កថាខណ្ឌទី១៥ និងទី១៦។ ហើយស្របគ្នាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៨ សីហា ២០០៨ ត្រង់កថាខណ្ឌទី១០ និងទី១១ ដែលបានកំណត់ច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជាជាអ្នកបញ្ជា។ ខាងសហព្រះរាជអាជ្ញាក៏បានបញ្ជាក់ច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជាជាអ្នកបញ្ជា ខាងសហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់ច្បាស់ថា បក្សកុម្មុយនីស្តជាអ្នកបញ្ជា គឺមិនមែន ឌុច ជាអ្នកបញ្ជាទេ។ ហើយច្បាប់អ្នកបញ្ជានោះយ៉ាងណា យើងខ្ញុំនឹងបកស្រាយប្រហែលជានៅថ្ងៃស្អែក។

ពិសេស ត្រង់កថាខណ្ឌទី១២ នៃដីកាបញ្ជូនទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ៨ សីហា ២០០៨ បានលាតត្រដាង បង្ហាញយ៉ាងច្បាស់ក្រឡែតថា ការកាប់សម្លាប់ក្រៅច្បាប់ដែលមានលក្ខណៈនយោបាយនេះ ប្រព្រឹត្តឡើងជាដំបូងដោយអង្គភាពយោធា។ អ៊ីចឹង គឺបញ្ជាក់ច្បាស់ហើយ ការកាប់សម្លាប់ក្រៅច្បាប់នេះប្រព្រឹត្តឡើងដោយអង្គភាពយោធា។ ចុះឯ ឌុច ជានគរបាល មិនមែនជាយោធាទេ អ៊ីចឹង ឌុច អត់បានកាប់សម្លាប់ក្រៅច្បាប់ ដែលមានលក្ខណៈនយោបាយនេះទេ។

[១៤:១៧:២៩]

មុននិងក្រោយ ១៧ មេសា ១៩៧៥ អង្គភាពយោធាគ្រប់កងពល និងរដ្ឋអំណាចគ្រប់ភូមិភាគស្ថិតនៅក្រោមបញ្ជារបស់លេខា និងអនុលេខាភូមិ ឬបើនិយាយឲ្យចំ គឺជាកម្មសិទ្ធិរបស់លេខា និងអនុលេខភូមិភាគ។ បានសេចក្ដីថា អង្គភាពយោធាទាំងអស់គេមានម្ចាស់របស់គេ។ អ៊ីចឹង ម្ចាស់នោះអ្នកណា? គឺលេខា និងអនុលេខាភូមិភាគ គេមានទ័ពរបស់គេ។ អ៊ីចឹង ទ័ពរបស់គេ លេខា និងអនុលេខាភូមិភាគហ្នឹង គេចង់ឲ្យបញ្ជាឲ្យកាប់សម្លាប់អ្នកណា អាហ្នឹងស្រេចនឹងគេ វាមិនមែន តាឌុច នេះទេ។

ភូមិភាគដែលរួមគ្នាវាយភ្នំពេញមាន ភូមិភាគបូព៌ា ឈ្មោះ សោ យ៉ាន់ ហៅ ភឹម ជាលេខា។ ភូមិភាគពិសេស មានឈ្មោះ វន វ៉េត និង សុន សេន។ ភូមិភាគនិរតីចាស់ មានឈ្មោះ អ៊ុង ជឿន ហៅ ម៉ុក និង ជូ ជេត ហៅ ស៊ី។ បួនភូមិភាគឧត្តរចាស់ មានឈ្មោះ កុយ ធួន និង កែ ពក។ ចំណែក រស់

ញ៉ឹម ជាលេខាភូមិភាគពាយ័ព្យ គឺវាយផ្ដាច់មុខយកខេត្តបាត់ដំបង ពីព្រោះនៅឆ្នាំ១៩៧៥ ហ្នឹង ១៧ មេសា ហ្នឹង គឺថានៅតែភ្នំពេញមួយទេ ដែលវាយមិនទាន់បែក និងទីរួមខេត្តបាត់ដំបង ក្រៅពីហ្នឹងបែកអស់ហើយ។ អ៊ីចឹងបួនភូមិភាគអំមិញហ្នឹង គេវាយយកភ្នំពេញ ទ័ពទាំងប៉ុន្មានជាកម្មសិទ្ធិរបស់គេ គេឲ្យវាយចូលយកភ្នំពេញ។ ចំណែក រស់ ញ៉ឹម លេខាភូមិភាគពាយ័ព្យ គេវាយផ្ដាច់មុខតែម្នាក់គេយកទីរួមខេត្តបាត់ដំបងនៅឆ្នាំ៧៥ ហ្នឹង។

[១៤:១៩:១៧]

ដូច្នេះ រួមទាំងអស់គ្នា វាយយកភ្នំពេញ និងបាត់ដំបងមានចំនួនដប់នាក់គត់ ដែលអ្នកទទួលខុសត្រូវ៖

គឺ១) ប៉ុល ពត, ២) នួន ជា, ៣) សោ យ៉ាន់ ហៅ ភឹម, ៤) អ៊ុំង ជឿន ហៅ ម៉ុក, ៥) វន វ៉េត, ៦)សុន សេន, ៧) កុយ ធួន, ៨) រស់ ញ៉ឹម, ៩) ជូ ជេត ហៅ ស៊ី, ១០) កែ ពក។ អត់មានឈ្មោះ តា ឌុច ទេ។ ដប់នាក់នេះ បន្ទាប់ពីដណ្ដើមរដ្ឋអំណាចបានហើយ ក៏ចាប់ផ្ដើមផែនការឧក្រិដ្ឋរបស់ខ្លួនភ្លាម។ ដូច្នេះ គឺដប់នាក់នេះហើយ ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី៣០ មីនា ១៩៧៦។

ជារួម នៅក្នុងរយៈកាលទីមួយ ពីថ្ងៃទី១៧ មេសា ៧៥ ដល់ថ្ងៃទី៣០ មីនា ១៩៧៦ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិនោះទេ។ ព្រោះថា៖

ទីមួយ ពីថ្ងៃទី១៧ មេសា ៧៥ និងក្រោយបន្តិចមក ដែលជម្លៀសប្រជាជន សម្លាប់ប្រជាជន គឺដោយអង្គយោធា។ អានេះកថាខណ្ឌទី១២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ឌុច ជានគរបាល មិនមែនជាយោធាទេ ដូច្នេះ ឌុច អត់មានបទល្មើសអីក្នុងថ្ងៃ១៧ មេសា ៧៥ និងក្រោយមកបន្តិចនោះទេ។ ដូច្នេះ ឌុច ដែលជានគរបាលត្រូវបានតែរួចផុតពីបទចោទ ពីព្រោះអង្គភាពយោធាទេ ជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋនៅក្រោមការដឹងនាំរបស់លេខាភូមិភាគ។

ទីពីរ ពេលជម្លៀសប្រជាជនពីភ្នំពេញទៅជនបទ មានសម្លាប់ប្រជាជន ពេលនោះ ឌុច នៅឈរជើងឯអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ដូច្នេះ ឌុច មិនបានចូលរួមជម្លៀសប្រជាជនពីភ្នំពេញ ឬក៏ពីទីរួមខេត្តនោះទេ ព្រោះ ឌុច នៅអមលាំង។ ដូច្នេះចោទប្រកាន់ ឌុច គឺជាការភាន់ច្រឡំ។

ទីបី ឈ្មោះលេខាភូមិភាគ ដែលទទួលខុសត្រូវក្នុងការវាយយកភ្នំពេញនិងបាត់ដំបង ដែលជម្លៀសប្រជាជន កាប់សម្លាប់ប្រជាជន ពេលនោះមានឈ្មោះតែដប់នាក់គត់ ដោយមិនមានឈ្មោះ ឌុច នេះទេ។

[១៤:២២:២០]

ទីបួន ក្រោយ១៧ មេសា ១៩៧៥ រហូតដល់ ថ្ងៃ ៣០ មីនា ១៩៧៦ ឌុច ជាអនុប្រធានស-២១ ឯប្រធាន ស-២១ គឺ អ៊ិន លន ហៅ ណាត។ ឌុច ជាអនុប្រធានស-២១ ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅ ស-២១ ពេលនោះទេ។ ឯអ្នកទទួលខុសត្រូវខ្ពស់បំផុតពេលនោះ គឺ អ៊ិន លន ហៅ ណាត បើទោះបីបើថាយកប្រធានគុកមកពីរយៈពេល ១៧ មេសា ៧៥ រហូតដល់ថ្ងៃទី ៣០ មីនា ១៩៧៩ ក៏មិនត្រូវឈ្មោះ ឌុច ដែល គឺ អ៊ិន លន ហៅ ណាត ដូច្នេះ ឌុច ត្រូវតែបានរួចខ្លួន។

ជារួម ពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៣០ មីនា ១៩៧៦ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ មានឈ្មោះតែដប់នាក់គត់ដូចបានជម្រាបជូនខាងលើ ដោយគ្មានឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទេ។ ដូច្នេះ ក្នុងរយៈកាលទីមួយនេះ ឌុច ត្រូវបានតែរួចខ្លួនពីការចោទប្រកាន់ ព្រោះ ឌុច ជាអនុប្រធានស-២១ ឯអ្នកដែលខ្ពស់បំផុតនៅស-២១ ពេលនោះ គឺ អ៊ិន លន ហៅ ណាត។

[១៤:២៣:៤៨]

អ៊ីចឹង ឥឡូវនេះ ខ្ញុំចូលមកដល់រយៈកាលទីពីរ។ រយៈកាលទីពីរ គឺចាប់ពីថ្ងៃទី៣០ មីនា ១៩៧៦ ដល់ថ្ងៃទី៦ មករា ១៩៧៩។

យោងតាមកថាខណ្ឌទី៣៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៨ សីហា ២០០៨ របស់សហចៅក្រមស៊ើបអង្កេត ដែលបានទទួលស្គាល់ថា បក្សបានបញ្ជាក់អំពីក្របខ័ណ្ឌ ដែលមានសិទ្ធិអំណាចសម្រេចកម្ទេច។ នៅក្នុងកថាខណ្ឌ៣៥ ហ្នឹង គឺសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ច្បាស់ហើយ បក្សបានបញ្ជាក់អំពីក្របខ័ណ្ឌ ដែលមានសិទ្ធិអំណាចសម្រេចកម្ទេច។ អ៊ីចឹង តើជនទាំងឡាយណាខ្លះ ដែលមានសិទ្ធិអំណាចសម្រេចកម្ទេចនោះ? អ្នកដែលមានសិទ្ធិអំណាចសម្រេចកម្ទេច គឺអ្នកទាំងនោះហើយ ដែលជាជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភច្បាប់។ ពីព្រោះបក្សបានប្រគល់សិទ្ធិ បានប្រគល់អំណាចឲ្យជនប៉ុន្មាននាក់ខ្លះ? បន្តិចទៀតនឹងដល់ហើយ គឺប្រគល់សិទ្ធិ អ្នកឯងកាប់អ្នកណា? អ្នកឯងអ្នកទុកអ្នកណា? អ្នកឯងឲ្យអ្នកណារស់? អ្នកឯងឲ្យអ្នកស្លាប់? ទៅលើមនុស្សហ្នឹង។ ហើយអ៊ីចឹងយើងពិនិត្យតទៅទៀត តើមនុស្សមាន តា ឌុច? អើ! បើវាមាន តាឌុច មេធាវីកប់យោបល់

ហើយ ប៉ុន្តែក្រែងលោវាគ្មាន។

[១៤:២៥:៤៤]

យោងតាមសេចក្ដីសម្រេចរបស់គណៈមជ្ឈិម ចុះថ្ងៃទី៣០ មីនា ១៩៧៦ គឺគណៈមជ្ឈិមបានសម្រេចប្រគល់សិទ្ធិឲ្យមនុស្សបួនក្រុម ឬក៏អាចនិយាយយ៉ាងសាមញ្ញថា បក្ស ឬអង្គការបានចាត់តាំងមនុស្សបួនក្រុមឲ្យមានសិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ។ អ៊ីចឹង បក្សគេបានចាត់តាំងមនុស្សបួនក្រុម។ អ៊ីចឹង បួនក្រុមហ្នឹង តើមាន តា ឌុច អេ្ហ?

ក្រុមទីមួយ បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច បានសេចក្ដីថា លេខាភាគអ្នកសម្រេច អាហ្នឹងនៅតាមភូមិភាគ។ ជុំវិញមន្ទីរមជ្ឈិម នៅភ្នំពេញហ្នឹង ជុំវិញមន្ទីរមជ្ឈិមហ្នឹងក្រសួងមន្ទីរទាំងអស់ហ្នឹងត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ តំបន់ឯករាជ្យៗ អ្នកណាសម្រេច? ត្រូវអចិន្ត្រៃយ៍សម្រេច គឺ ប៉ុល ពត។ កងទ័ពមជ្ឈិមអ្នកណាសម្រេច? ត្រូវសេនាធិការសម្រេច។ អ៊ីចឹងយើងមើលរហូតតទៅទៀត តើក្នុងបួនក្រុមហ្នឹង ក្រុមនីមួយៗមានឈ្មោះអីខ្លះ?

អ៊ីចឹង បើតាមសេចក្ដីសម្រេចរបស់គណៈមជ្ឈិម ដែលបានផ្ដល់សិទ្ធិ បានប្រគល់សិទ្ធិឲ្យកម្ទេចមនុស្សទាំងនៅក្នុងជួរ និងទាំងនៅក្រៅជួរអស់រាប់លាននាក់នេះ គឺពួកបួនក្រុមខាងលើនេះឯង។ ដូច្នេះពួកបួនក្រុមនេះ ដែលជាជនទាំងឡាយទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ព្រោះជនទាំងបួនក្រុមនេះហើយ ដែលមានសិទ្ធិសម្រេចកម្ទេចអ្នកណា ឬក៏ទុកអ្នកណា។ ដោយគោរពតាមសេចក្ដីសម្រេចដែលបានកំណត់ឡើងយ៉ាងច្បាស់លាស់របស់គណៈអចិន្ត្រៃយ៍មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា គឺបានផ្ដល់សិទ្ធិឲ្យ បានប្រគល់សិទ្ធិឲ្យ៖

មួយ) គឺអចិន្ត្រៃយ៍ភាគ។ អ៊ីចឹង អចិន្ត្រៃយ៍ភាគជាអ្នកសម្រេចកម្ទេចមនុស្សក្នុងជួរ និងក្រៅជួរក្នុងក្របខ័ណ្ឌមូលដ្ឋាននៃភូមិភាគរបស់ខ្លួន។ អ៊ីចឹង ភូមិភាគទាំងអស់ក្នុងសម័យ ប៉ុល ពត មានប្រាំពីរភូមិភាគ។ ភូមិភាគឦសាន គឺក្រចេះត្រើយខាងកើត ស្ទឹងត្រែងត្រើយខាងកើត រតនគិរី និងមណ្ឌលគិរីដែលមានឈ្មោះ ម៉ែន សាន ហៅ យ៉ា ជាលេខា ជាអ្នកដែលជាអ្នកមានសិទ្ធិសម្រេចកម្ទេច។ អ៊ីចឹង បើនៅភូមិភាគឦសាន គឺ ម៉ែន សាន ហៅ យ៉ា ជាអ្នកមានសិទ្ធិសម្រេចកម្ទេច។ គាត់ចង់ឲ្យងាប់អ្នកណាឲ្យរស់អ្នកណា អាហ្នឹងគឺស្រេចលើគាត់។ ពីរ) ភូមិភាគបូព៌ា៖ ព្រៃវែង ស្វាយរៀង ដែលមានឈ្មោះសោ យ៉ាន់ ហៅ ភឹម ជាលេខា ដែលជាអ្នកមានសិទ្ធិសម្រេចកម្ទេច។ បី) ភូមិភាគនិរតី៖ មាន តាកែវកំពត កំពង់ស្ពឺខាងត្បូង ស្អាង កោះធំ លើកដែក កៀនស្វាយ ដង្កោ កណ្ដាលស្ទឹង ដែលមានឈ្មោះ អ៊ុង

ជឿន ហៅ ម៉ុក ឬក៏ ឈិត ជឿន ហៅ ម៉ុក ជាលេខាភូមិភាគ ដែលជាអ្នកមានសិទ្ធិសម្រេចកម្ទេច។ បួន) ភូមិភាគបស្ចិមៈ កំពង់ស្ពឺខាងជើង ផ្លូវជាតិលេខ៤ កំពង់ឆ្នាំង កោះកុង ដែលមានឈ្មោះ ជូ ជេត ហៅ ស៊ី ជាលេខា ដែលជាអ្នកមានសិទ្ធិសម្រេចឲ្យកម្ទេច។ ប្រាំ ភូមិភាគពាយ័ព្យ មាន ពោធិ៍សាត់ បាត់ដំបង ដែលខេត្តបាត់ដំបងពេលនោះមានទាំងប៉ៃលិន និងបន្ទាយមានជ័យផងដែរ ដែលមានឈ្មោះ រស់ ញឹម ប្អូនថ្លៃ នួន ជា ជាលេខា ដែលអ្នកជាអ្នកមានសិទ្ធិសម្រេចឲ្យកម្ទេច។

ប្រាំមួយ) ភូមិភាគកណ្តាលៈ កំពង់ធំ កំពង់ចាមត្រើយខាងលិច ដែលមានឈ្មោះ កែ ពក ឈ្មោះ កែ វិន ជាលេខា ដែលជាអ្នកមានសិទ្ធិសម្រេចឲ្យកម្ទេច។ ប្រាំពីរ) ភូមិភាគឧត្តរថ្មី មានព្រះវិហារ ឧត្តរមានជ័យ ក្រចេះត្រើយខាងលិច និងស្ទឹងត្រែងត្រើយខាងលិច មានឈ្មោះ កង ចាប ហៅ សែ ជាលេខាដែលជាអ្នកមានសិទ្ធិសម្រេចឲ្យកម្រេច។

ក្នុងភូមិភាគទាំងប្រាំពីរនេះ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនថា ក្រោយពីចាប់ ជូ ជេត ហៅ ស៊ី ឈ្មោះ អ៊ុង ជឿន ហៅ ម៉ុក ឡើងធ្វើជាលេខាភូមិភាគបស្ចិមជំនួស ជូ ជេត ហៅ ស៊ី ហើយបន្ទាប់ពីចាប់ រស់ ញឹម ឈ្មោះ អ៊ុង ជឿន ហៅ ម៉ុក ឡើងធ្វើជាលេខាភូមិភាគពាយ័ព្យជំនួស រស់ ញឹម និងបន្ទាប់ពីចាប់ កង ចាប ហៅ សែ ឈ្មោះ អ៊ុង ជឿន ហៅ ម៉ុក ឡើងធ្វើជាលេខាភូមិភាគឧត្តរថ្មីបន្ថែមទៀត។ ចុងបំផុត អ៊ុង ជឿន ហៅ ម៉ុក ជាលេខាភូមិភាគនិរតី បស្ចិម ពាយ័ព្យ និង ឧត្តរថ្មី។

ដូចនេះ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ពីថ្ងៃទី៣០ មីនា ១៩៧៦ ដល់ ថ្ងៃទី៦ មករា ១៩៧៩ គឺលេខាភូមិភាគទាំងប្រាំពីរនេះឯង។ នេះគ្រាន់តែជាផ្នែកមួយទេ អ៊ីចឹងនៅបីក្រុមទៀត ទាំងអស់វាបួនក្រុម។

[១៤:៣១:៣៣]

អ៊ីចឹង ដោយអនុលោមតាមស្មារតីនៃសេចក្តីសម្រេចរបស់គណៈមជ្ឈិមចុះថ្ងៃទី៣០ មីនា ១៩៧៦ ដដែល គឺបានផ្តល់សិទ្ធិ គឺបានប្រគល់សិទ្ធិឲ្យសម្រេចក្នុងការកម្ទេចមនុស្សក្នុងជួរ និងក្រៅជួរដល់គណៈមន្ទីរមជ្ឈិម។ អ៊ីចឹង គណៈមន្ទីរមជ្ឈិមដែលជាអ្នកមានសិទ្ធិសម្រេចឲ្យកម្ទេចមនុស្សជុំវិញមន្ទីរមជ្ឈិមតាមគោលការណ៍នេះ ខៀវ សំផន ជាអ្នកសម្រេចឲ្យកម្ទេច ព្រោះ ខៀវ សំផន ជាប្រធានគណៈកម្មាធិការមន្ទីរមជ្ឈិម ហៅថាមន្ទីរ៨៧០។ ដូចនេះ ខៀវ សំផន ក៏ជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅច្បាប់ជាតិ និងច្បាប់អន្តរជាតិ ពីថ្ងទី៣០ មីនា ១៩៧៦ ដល់ ថ្ងៃ៦ មករា ១៩៧៩។

ហើយតាមសេចក្តីសម្រេចរបស់គណៈមជ្ឈិមចុះថ្ងៃ៣០ មីនា ១៩៧៦ ដដែល បានប្រគល់សម្រេចក្នុងការកម្ទេចមនុស្សក្នុងជួរនិងក្រៅជួរដល់តំបន់ឯករាជ្យ។ គេហៅថា តំបន់ឯករាជ្យ ឬក៏តំបន់ស្វយ័ត។ តំបន់ឯករាជ្យមាន ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងព្រះវិហារ និងក្រុងកំពង់សោម ឬហៅថា ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ អ៊ីចឹង តំបន់ឯករាជ្យហ្នឹងនេះ គឺអចិន្ត្រៃយ៍ជាអ្នកសម្រេចឲ្យកម្ទេច។ អចិន្ត្រៃយ៍នេះ គឺគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមាន ប៉ុល ពត ហៅ បង ប៉ុល ជាលេខា។

[១៤:៣៣:១៨]

សូមបញ្ជាក់អំពីមូលហេតុតំបន់ឯករាជ្យ ឬតំបន់ស្វយ័ត ដែលឲ្យ ប៉ុល ពត ជាអ្នកសម្រេចកម្ទេច មកពីលេខាតំបន់ឯករាជ្យទាំងអស់មិនទាន់មាននរណាម្នាក់ជាសមាជិកមជ្ឈិមពេញសិទ្ធិ បើមិនទាន់ជាសមាជិកមជ្ឈិមពេញសិទ្ធិទេ អ្នកនោះមិនមានសិទ្ធិសម្រេចកម្ទេច និយាយឲ្យចំ គឺគ្មានសិទ្ធិសម្រេចកម្ទេចមនុស្សទេ។ ទាល់តែសមាជិកមជ្ឈិមពេញសិទ្ធិ អាហ្នឹងបានមានសិទ្ធិសម្រេចកម្ទេច។ អ៊ីចឹង ហើយក្នុងតំបន់ឯករាជ្យនោះ វាអត់មានសមាជិកមជ្ឈិមពេញសិទ្ធិ អ៊ីចឹង គេប្រគល់ឲ្យអចិន្ត្រៃយ៍ គឺឲ្យ ប៉ុល ពត សម្រេចផ្ទាល់។ ដូច្នេះ ប៉ុល ពត ក៏ជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

ទីបួន, ក្រុមទីបួន គឺក្នុងជួរកងទ័ព នៅក្នុងសេចក្តីសម្រេចរបស់គណៈមជ្ឈិម ចុះថ្ងៃទី៣០ មីនា ១៩៧៦ ដដែល បានប្រគល់សិទ្ធិឲ្យសម្រេចកម្ទេចក្នុងជួរកងទ័ពមជ្ឈិម គឺកងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច ហើយច្បាស់លាស់ណាស់ គឺ សុន សេន ជាលេខាសេនាធិការ ដែលជាអ្នកសម្រេចកម្ទេចក្នុងជួរកងទ័ពមជ្ឈិម។ ដូចនេះ សុន សេន ក៏ជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ខ្ញុំបាទសូមអនុញ្ញាតបញ្ជាក់បន្ថែមថា តាមឯកសារ ការប្រជុំអចិន្ត្រៃយ៍ចុះថ្ងៃទី៩ តុលា ១៩៧៥ បានសរសេរថា គឺខ្ញុំនិយាយត្រង់ចំណុចទីពីរ គឺសមមិត្តអនុលេខា១ ហ្នឹង គឺ នួន ជា ជាការងារបក្សសង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ នេះមានន័យថា ក្រៅពីការងារបក្ស១ នួន ជា ត្រូវទទួលខុសត្រូវលើក្រសួងបួន គឺសង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ លើគ្រប់ផ្នែកការងារទាំងអស់ ពិសេសលើការងារសម្រិតសម្រាំងផ្ទៃក្នុងក្រសួង។ បានសេចក្តីថា ក្រសួងទាំងបួននេះ ការងារកម្ទេច ការងារសម្លាប់មនុស្សទាំងបួននេះ គឺ នួន ជា ជាអ្នកសម្រេច។ ពីព្រោះរដ្ឋមន្ត្រីទាំងបួន

ក្រសួងទាំងបួននេះ គ្មាននរណាម្នាក់ចូលជាសមាជិកមជ្ឈិមនៅឡើយទេ ដូចតំបន់ឯករាជ្យដែលតំបន់នោះភូមិភាគនោះមិនទាន់មានអ្នកណាជាសមាជិកមជ្ឈិម។ អ៊ីចឹង ទៅគេប្រគល់ឲ្យ ប៉ុល ពត ជាអ្នកសម្រេច។ អ៊ីចឹង មកក្រសួងបួន អម្បាញ់មិញនេះ វាគ្មាននរណាជារដ្ឋមន្ត្រីមែន ប៉ុន្តែមិនទាន់ចូលជាសមាជិកមជ្ឈិមបក្ស អ៊ីចឹង អ្នកឯងគ្មានសិទ្ធិសម្រេចកម្ទេចមនុស្សទេ។ អ៊ីចឹង ហើយបានជាគេប្រគល់ឲ្យ នួន ជា។

[១៤:៣៦:២៤]

ដូចនេះ កន្លែងនេះយើងអាចទាញមកបានថា បើទាល់តែសមាជិកមជ្ឈិម អាហ្នឹងបានមានសិទ្ធិសម្រេចកម្ទេចមនុស្ស។ អ៊ីចឹង តាឌុច គាត់មានសិទ្ធិសម្រេចកម្ទេចមនុស្សទេ? បើគាត់មិនមែនមជ្ឈិមផងហ្នឹង គ្រាន់តែជាបក្ខជនធម្មតា។ ឃើញច្រងោច្បាស់ក្រឡែត។ ទន្ទឹមគ្នានេះដែរ នួន ជា ត្រូវបានចាត់តាំងបន្ថែមជាបន្តបន្ទាប់ឲ្យធ្វើជាលេខាភូមិភាគពាយ័ព្យ និងបូព៌ា នៅពេលដែលអចិន្ត្រៃយ៍សម្រេចចាប់លេខាភូមិភាគ ដែលចាត់តាំងពីមុនមក។

ប្រការទាំងពីរខាងលើនេះ គឺ នួន ជា ទទួលបន្ទុកលើរដ្ឋមន្ត្រីទាំងបួន និងជាលេខាភូមិភាគបន្ថែមចំនួនពីរភូមិភាគ ដែលជាហេតុផលបន្ថែមបញ្ជាក់ថា នួន ជា គឺជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ សូមអនុញ្ញាតពីលោកប្រធាន គឺសូមដល់ម៉ោង សូមស្នើសម្រាកសិន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវឈប់សម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០១:នាទី)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាបន្តសូមអញ្ជើញមេធាវីការពារក្តីជាតិ បន្តនូវសេចក្តីថ្លែងការណ៍សេចក្តីសន្និដ្ឋានបញ្ចប់កិច្ច

ពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ។

**លោក ការ សាវុត្ថ៖**

សូមអនុញ្ញាតបន្តទៅទៀត។ ជារួមគឺជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ ចាប់ពីថ្ងៃទី៣០ ខែមីនា ១៩៧៦ ដល់ថ្ងៃទី៦ មករា ១៩៧៩ មានចំនួន១១នាក់ គឺ ១) ប៉ុល ពត ២) នួន ជា ៣) សោ យ៉ាន់ ហៅ ភឹម ៤) អ៊ុង ជឿន ហៅ ម៉ុក ៥) សុន សេន ៦) ខៀវ សំផន ៧) ម៉ែន សាន ហៅ យា ៨) ជូ ជេត ហៅ ស៊ី ៩) វស់ ញឹម ១០) កែ ពក ១១) កង ចាប ហៅ សែ។

អម្បាញ់មិញ ខ្ញុំបាទបានជម្រាបហើយ មានពីរយៈកាល រយៈកាលទីមួយ និងរយៈកាលទីពីរ។ ឥឡូវខ្ញុំសូមសរុបទាំងពីររយៈកាល គឺពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។ អ៊ីចឹង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិចាប់ពីថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ មានចំនួន១៣នាក់គត់ គឺ ១) ប៉ុល ពត ២) នួន ជា ៣) សោ យ៉ាន់ ហៅ ភឹម ៤) អ៊ុង ជឿន ហៅ ម៉ុក ៥) វន វ៉េត ៦) សុន សេន ៧) ខៀវ សំផន ៨) កុយ ធួន ៩) ម៉ែន សាន ហៅ យា ១០) កែ ពក ១១) ជូ ជេត ហៅ ស៊ី ១២) វស់ ញឹម ១៣) កង ចាប ហៅ សែ។

ជារួម ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី០៦ មករា ១៩៧៩ ទាំង១៣នាក់ខាងលើនេះ គ្មានឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទេ។ បើយោងតាមមាត្រាមួយថ្មី នៃច្បាប់បង្កើតឲ្យមាន អ.វ.ត.ក ពុំមានពាក់ព័ន្ធដល់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទេ ព្រោះ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ហើយក៏ពុំមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ នោះទេ។

សរុបមក តើអ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរ-ជាតិពីថ្ងៃទី១៧ មេសា ៧៥ ដល់ថ្ងៃទី ៦ មករា ១៩៧៩។

[១៥:០៥:៤៦]

អ៊ីចឹង យើងខ្ញុំសរុបទាំងមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យផង ទាំងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មផង បញ្ចូលគ្នា ក៏ប៉ុន្តែក្នុងនេះមានជនខ្លះគាត់ដើរតួនាទីពីរ គាត់ជាមេដឹកនាំផង គាត់ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មផង ហើយមានអ្នកខ្លះគ្រាន់តែជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ។ ហើយមានអ្នកខ្លះគ្រាន់តែជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មតែប៉ុណ្ណោះ។ អ៊ីចឹង តាមការដែលរៀបរាប់ខាងលើឃើញថា ជនទាំងឡាយដែលទទួលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនោះ សរុបមកមានតែ១៤នាក់គត់ៗ។

ទីមួយ អ្នកដែលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យផង និងជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិផងមានចំនួនប្រាំបួននាក់។ អ៊ីចឹង ជនដែលមានតួនាទីទាំងពីរជំពូកហ្នឹង ទាំងមេដឹកនាំផង ទាំងទទួលខុសត្រូវឧក្រិដ្ឋកម្មផងមានប្រាំបួននាក់គត់។ ១) ប៉ុល ពត ២) នួន ជា ៣) សោ យ៉ាន់ ហៅ ភឹម ៤) អ៊ុង ជឿន ហៅ ម៉ុក ឬក៏ ឈិត ជឿន ហៅ ម៉ុក ៥) វន វ៉េត ៦) សុន សេន ។

សុំកន្លែងនេះអនុញ្ញាតជម្រាបថា បីនាក់ខាងក្រោមនេះទី៧ ទី៨ ទី៩ វា៩នាក់ហ្នឹងគឺថា តាមឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់ *ឌីស៊ីខេម* គេថាថែមបីនាក់ទៀត អ៊ីចឹងវាជាប់ទី៧ ខៀវ សំផន, ទី៨ កែ ពក, ទី៩ រស់ ញឹម។

ទីពីរ អ្នកដែលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យមានតែម្នាក់ទេ គាត់អត់មែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មហ្នឹងទេ គឺ អៀង សារី។

ទីបី អ្នកដែលជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងច្បាប់អន្តរជាតិមានចំនួនបួននាក់ គាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យទេ ក៏ប៉ុន្តែគាត់ជាជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ១) គឺ កុយ ធួន ២) ម៉ែន សាន ហៅ យ៉ា ៣) ជូ ជេត ហៅ ស៊ី ៤) កង ចាប ហៅ សែ។ អ៊ីចឹង អ្នកទាំង១៤នាក់ខាងលើគឺ

ចំណុច ក ត្រូវស្លាប់ ឬកម្ទេចមុនថ្ងៃ៦ មករា ១៩៧៩ អស់ចំនួន៧នាក់ ក្នុង១៤នាក់នេះស្លាប់មុនថ្ងៃ៧ មករា ឬកម្ទេចមុនថ្ងៃ៧ មករា ៧៩ អស់ចំនួន៧នាក់។ ១) សោ យាន់ ហៅ ភឹម ធ្វើអត្តឃាតឆ្នាំ១៩៧៨។ ២) វន វ៉េត ឈ្មោះដើម ពេញ ធួន ចាប់ខ្លួនថ្ងៃ២ វិច្ឆិកា ៧៨ កម្ទេចឆ្នាំ១៩៧៨ហ្នឹង។ ៣) កុយ ធួន ចាប់ខ្លួនថ្ងៃ២៥ មករា ឆ្នាំ១៩៧៧។ ៤) ម៉ែន សាន ហៅ យ៉ា ត្រូវចាប់ខ្លួននៅថ្ងៃ២០ កញ្ញា

១៩៧៦។ ៥) ជូ ជេត ហៅ ស៊ី ចាប់ខ្លួននៅថ្ងៃ១៧ មេសា ៧៨។ ៦) វស់ ញ៉ឹម ហៅ មូល អ៊ុន ហៅ សម្បត្តិ កម្ទេចនៅឆ្នាំ១៩៧៨។ ៧) កង ចាប ហៅ សែ ឈ្មោះដើម ចាន់ សំ ត្រូវចាប់ខ្លួនហើយ កម្ទេចនៅថ្ងៃ៣១ តុលា ១៩៧៨។

[១៥:១០:២៥]

ចំណុច ខ ត្រូវស្លាប់ និងសម្លាប់ក្រោយថ្ងៃទី៦ មករា ១៩៧៩ អស់បួននាក់ទៀត គឺ ១) ប៉ុល ពត ១៩៩៨។ ២) អ៊ីង ជឿន ហៅ ម៉ុក ស្លាប់នៅឆ្នាំ២០០៦។ សុន សេន ត្រូវ ប៉ុល ពត កម្ទេចនៅឆ្នាំ ១៩៩៧។ ៤) កែ ពក ស្លាប់នៅឆ្នាំ២០០២។

ដូច្នេះ ក្នុង១៤នាក់នេះស្លាប់អស់១១នាក់ ដូច្នេះនៅរស់តែបីនាក់ដែលត្រូវយកមកជំនុំជម្រះគឺ៖

១) នួន ជា ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ព្រោះគាត់ជាអនុលេខាទីមួយ និង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់ អន្តរជាតិ ព្រោះ នួន ជា ជាអ្នកត្រួតពិនិត្យ និងតាមដានការអនុវត្តមាគ៌ា ការអនុវត្តសេចក្តីសម្រេច ចិត្តតូចធំរបស់ ប៉ុល ពត។ ជាអ្នកគ្រប់គ្រងលើរដ្ឋមន្ត្រីក្រសួងបួន លើគ្រប់ផ្នែកការងារសំខាន់ៗ ពិសេស ការងារសម្រិតសម្រាំងផ្ទៃក្នុងក្រសួងទាំងបួន និងជាលេខាភូមិភាគពាយ័ព្យ និងបូព៌ាបន្តពីលេខាមុនដែល ត្រូវបានសម្រិតសម្រាំង។

២) ខៀវ សំផន ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ ព្រោះខៀវ សំផន ជាលេខាមន្ទីរ៨៧០ មានសិទ្ធិសម្រេចកម្ទេចជុំវិញមន្ទីរ មជ្ឈិម ហើយនៅឆ្នាំ១៩៧៧ ដែលថា ខៀវ សំផន បានជាប់ជាសមាជិកអចិន្ត្រៃយ៍ ដូច្នេះ ខៀវ សំផន ក៏ត្រូវជាប់ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ១៩៧៧មក។

៣) អៀង សារី ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ព្រោះជាសមាជិកពេញសិទ្ធិនៃ គណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស និងជាឧបនាយករដ្ឋមន្ត្រី។

ជាសេចក្តីសន្និដ្ឋានរួម ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែន ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិនោះទេ ព្រោះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យដែលជាម្ចាស់មាគ៌ាឧក្រិដ្ឋកម្ម មានមនុស្សតែប្រាំពីរនាក់គត់ គឺឥតមានឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទេ។ ទោះបីមកដល់ឆ្នាំ១៩៧៧ បានបញ្ចូលសមាជិកអចិន្ត្រៃយ៍បីនាក់ទៀត មាន កែ ពក ខៀវ សំផន និង វស់ ញ៉ឹម ក៏គ្មានឈ្មោះ ឌុច

ដែរ។ រីឯជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិមានចំនួនមនុស្សតែ១៣នាក់គត់ ក៏មិនឃើញមានឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែរ។

[១៥:១៥:០៥]

ហើយនៅក្នុងឯកសាររាប់ម៉ឺនសន្លឹកក្នុងសំណុំរឿងលេខ០០១ គ្មានឯកសារមួយសន្លឹកណាដែលថា ឌុច ជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនោះទេ។ ឌុច ទទួលខុសត្រូវខ្ពស់បំផុតតែនៅស-២១ ប៉ុណ្ណោះ ពិសេសមនុស្សដែលគេចាប់បញ្ជូនមកស-២១ គឺ ឌុច ទទួលខុសត្រូវ។ តែគេចាប់មកដល់ស-២១ គាត់ទទួលខុសត្រូវតែក្នុងស-២១ទេ គាត់មិនមែនទទួលខុសត្រូវក្នុងក្រុមកម្ពុជាប្រជាធិបតេយ្យទាំងមូលនោះទេ អ៊ីចឹងគាត់ទទួលខុសត្រូវស្អីខ្លះនៅក្នុងស-២១ គាត់ទទួលខុសត្រូវ ព្រោះវិន័យដែលគេដាក់ឱ្យគាត់ គឺខុសត្រូវទីមួយ គឺបញ្ជូនមកហើយកុំឱ្យរត់រួចអាហ្នឹងទីមួយ។ ទីពីរ ទទួលខុសត្រូវក្នុងការធ្វើទារុណកម្ម។ ទីបី ទទួលខុសត្រូវក្នុងការយកចម្លើយឱ្យបាន។ តែយកមកដល់ ស-២១ ហើយគាត់ទទួលខុស ត្រូវហើយ យកចម្លើយឱ្យបាន តែមិនបានចម្លើយគាត់កំបុតកដែរ។ ដោយយកចម្លើយឱ្យបានថាជា សេ.អ៊ី.អា ថាជា កា.ហ្សេ.បេ ឬជាគិញយួន ថាអាណាមួយក៏បានដែរ នេះជា សេ.អ៊ី.អា ក៏បានជា កា.ហ្សេ.បេ ក៏បាន ជាគិញយួនក៏បាន។ អានេះក្នុងការយកចម្លើយ ឱ្យយកឱ្យបានបីហ្នឹង ណាមួយក៏បាន។ ទួលខុសត្រូវទីបួន គឺ ឌុច ទទួលខុសត្រូវថា កុំឱ្យងាប់ដល់ដាច់ចម្លើយ បើអ្នកណាម្នាក់ធ្វើ ទារុណកម្មជនរងគ្រោះ យើង ជំនាន់យើង យើងថាជនរងគ្រោះ ជំនាន់នោះគេហៅថា អ្នកទោស។ ន៎ែ បើ សិនណាជាឱ្យងាប់ដល់ដាច់ចម្លើយ តា ឌុច ត្រូវទទួលខុសត្រូវ។ ទីប្រាំ ឌុច ទទួលខុសត្រូវ សួររួច ត្រូវបញ្ជូនទៅឱ្យគេកម្ទេច គាត់មិនដែលកម្ទេចដៃខ្លួនគាត់ទេ គាត់ត្រូវបញ្ជូនទៅឱ្យគេកម្ទេច។ អាហ្នឹង ទិសរបស់បក្ស បក្សគេឱ្យធ្វើអ៊ីចឹង ធ្វើខុសពីហ្នឹងក៏អត់រស់ ដែរ។

ពាក្យថា “កម្ទេចឱ្យបានឱ្យគេ” គឺកម្ទេចតាមបញ្ជាពីអង្គការ ដែល ប៉ុល ពត ជាមេខ្លាំង មេធំជាងគេ។ បន្ទាប់មកមាន នួន ជា និង សុន សេន ជាអ្នកបញ្ជាទៅ ឌុច ហើយ ឌុច ក៏បញ្ជាបន្តទៅក្រុមកម្ទេច នេះក៏ជាការបញ្ជាក់ថា ឌុច មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ គឺ ឌុច ទទួលបញ្ជាពីថ្នាក់លើរបស់ខ្លួន អ្នកមានសិទ្ធិសម្រេចឱ្យកម្ទេច នឹងមានសិទ្ធិបញ្ជាឱ្យកម្ទេចថែមទៀត អ្នកនេះឯងជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនោះ។ អ្នកដែលគ្រាន់តែទទួលបញ្ជាពីថ្នាក់លើ រួចយក

បញ្ជានេះទៅបញ្ជាបន្ត គឺមិនមែនជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ព្រោះមានគេបញ្ជាពីលើគាត់ទៀត។ គេបញ្ជាមក គាត់ធ្វើខុសបញ្ជា គាត់ត្រូវមានទោស បើសិនជាគាត់ធំជាងគេ បញ្ជាលើគេទោះបីគាត់បញ្ជាខុសក៏គ្មាននរណាធ្វើអីគាត់ដែរ។

បើ ឌុច មានសិទ្ធិសម្រេចឲ្យគេដើរចាប់មនុស្សយកមកកម្ទេចនោះ ទើបជាអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ចុះបើគាត់អត់មានសិទ្ធិផងហ្នឹង គេយកមកឲ្យហើយ ធ្វើម៉េចកុំឲ្យរបួតរបស់គេ របួតរបស់គេកំបុតកដូចគ្នា។ បើកំណត់ថាមេគុកស-២១ គឺជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ដូច្នេះ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមាន១៩៦គុក ត្រូវយកមេគុកទាំង១៩៦ មកធ្វើការកាត់សេចក្តី នោះទើបយុត្តិធម៌ នោះទើបស្មើភាព។

[១៥:១៨:៤០]

បើចោទប្រកាន់ ឌុច ជាមេគុក ត្រូវចោទប្រកាន់មេគុកទាំង១៩៦ ហើយជនទាំងឡាយដែលធំជាងមេគុកមានប៉ុន្មាននាក់ត្រូវចាប់យកមកកាត់សេចក្តីទាំងអស់ នោះទើបស្មើភាព ព្រោះមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់ថា “ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់” ឥឡូវស្មើភាពគ្នាទេ? ត្រឹមត្រូវតាមមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយឬនៅ? បើមេគុក១៩៦ យកតែមេគុកស-២១ ម្នាក់មកកាត់សេចក្តីនោះ។ មេគុក១៩៥នាក់ទៀត ត្រូវរួចខ្លួន។ គុកនីមួយៗទទួលបញ្ជាពីអង្គការតែមួយដូចគ្នា គុកនីមួយៗសុទ្ធតែមានការធ្វើទារុណកម្មដូចគ្នា មានកាប់សម្លាប់ដូចគ្នា ហេតុអ្វីក៏យកតែ ឌុច ម្នាក់មកកាត់សេចក្តី? នេះឬជាយុត្តិធម៌របស់ អ.វ.ត.ក ដែលមានអង្គការសហប្រជាជាតិនៅក្នុងនោះដែរនោះ?

ជាក់ស្តែងជាងនេះទៅទៀត ក្នុងចំណោម១៩៦គុក មានតែ៦៤គុកទេ ដែលមានតួលេខពីចំនួនមនុស្សដែលត្រូវស្លាប់ ហើយនៅក្នុងចំណោម៦៤គុកនេះ ដែលមានតួលេខបញ្ជាក់ពីចំនួនមនុស្សនោះដែលបានស្លាប់គឺស-២១ ស្ថិតក្នុងលំដាប់ថ្នាក់លេខ១០ បើប្រៀបធៀបទៅនឹងគុកចុងជ្រោយ ដែលសម្លាប់ច្រើនជាងគេនោះ គឺគុកចុងជ្រោយនៅភូមិឈើត្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង សម្លាប់មនុស្សដល់ទៅរាប់សិបដងលើសស-២១ ក៏មេគុកនេះមិនត្រូវបានយកមកកាត់សេចក្តីដែរ ព្រោះក្នុងឯកសារខ្លះថា គុកអាដែងណា ចុងជ្រោយហ្នឹងសម្លាប់រហូត១៥នាក់ អ៎!១៥ម៉ឺននាក់ បើ១៥ម៉ឺននាក់មែននេះ ស-២១ មួយម៉ឺនពីរពាន់បីរយប៉ែតសិបនាក់ (១២.៣៨០នាក់) គុណនឹងដប់ ពីរដង

មិនស្មើនឹងចុងជ្រោយមួយផង ហើយចុះហេតុអីក៏មេគុកនោះគេរួចខ្លួន? ហើយចុះអ្នកដែលសម្លាប់បានតិចជាងគេនេះ តែ១២.000នាក់ ម៉េចក៏ជាប់គុក? ដែលខាងសហព្រះរាជអាជ្ញាក៏ដឹងដែរ គាត់ថា គាត់ចង់បានយុត្តិធម៌ ខ្ញុំមេធាវីចង់បានដែរយុត្តិធម៌ឲ្យជនជាប់ចោទដែរ។

[១៥:២១:៣៩]

សូមតុលាការពិចារណាមើល ទំហំនៃព្យសនកម្ម ដូចជាទំហំនៃការខូចខាត១៥ម៉ឺននាក់ និង ១២.៣៨០នាក់ អ្នកណាធំជាង។ ទំហំនៃការអន្តរាយ ទំហំនៃវិនាសកម្ម ទំហំនៃឧក្រិដ្ឋកម្ម តើវាខុសគ្នាប៉ុនណារវាងជីវិតមនុស្ស១២.៣៨០នាក់។ សូមទោសកន្លែងហ្នឹងខ្ញុំមិនមែនមើលងាយជីវិត១២.៣៨០នាក់ទេ តែម្នាក់ក៏ខ្ញុំអាណិតដែរ ជីវិតមនុស្ស។ ក៏ប៉ុន្តែ ខ្ញុំប្រៀបធៀបដើម្បីស្វែងរកយុត្តិធម៌រវាងជីវិតមនុស្សនៅស-២១, ១២.៣៨០នាក់ និងចុងជ្រោយ១៥ម៉ឺននាក់។ តើវាខុសគ្នាប៉ុនណាជីវិតហ្នឹង វាខុសគ្នាឆ្ងាយណាស់។ វាទៅជាមេគុកចុងជ្រោយនោះត្រូវបានរួចខ្លួន។ បើមេគុកចុងជ្រោយត្រូវបានរួចខ្លួនដូច្នេះគុកស-២១ ក៏ត្រូវតែបានរួចខ្លួនដោយស្វ័យប្រវត្តិដូចមេគុកចុងជ្រោយ។ មេគុកដូចគ្នា បើរួចខ្លួនត្រូវរួចទាំងអស់គ្នា បើជាប់គុកត្រូវជាប់ទាំងអស់គ្នា នោះទើបយុត្តិធម៌ដែលអាចទទួលយកបាន។

មេគុកដូចគ្នា អ្នកខ្លះជាប់គុក អ្នកខ្លះទៀតរួចខ្លួន តើយុត្តិធម៌នៅត្រង់ណា? តើការស្វែងរកយុត្តិធម៌ឲ្យជនជាប់ចោទហ្នឹង វាយ៉ាងម៉េចដែរ? នេះជាភារកិច្ចរបស់សហព្រះរាជអាជ្ញា ពេលបើកសវនាការថ្ងៃទី៣០ មីនា ២០០៩ បើកលើកដំបូង ខ្ញុំបានស្នើសុំឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ជូនតុលាការឲ្យបានច្បាស់អំពីមូលហេតុដែលសហព្រះរាជអាជ្ញាមិនចោទប្រកាន់គុកដទៃទៀតនោះ ដើម្បីឲ្យជនជាប់ចោទនេះគេអស់ចិត្ត គេយល់មុននឹងផ្តន្ទាទោសគេៗ មុននឹងយកគេទៅដាក់គុក ឲ្យគេយល់ថាគេហ្នឹងពិតជាខុសមែនអីចេះៗ ហើយចុះបើគេមេគុកដូចគ្នា គេរួចខ្លួន ហើយគេសម្លាប់ច្រើនជាងគាត់។

ម្យ៉ាងទៀត គោលបំណងទីពីររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការកាត់សេចក្តីគឺដើម្បីកុំឲ្យរបបដ៏ឃោរឃៅនេះកើតមាននៅលើទឹកដីកម្ពុជាជាលើកទីពីរទៀត។ ចុះបើសម្លាប់មនុស្សតិចត្រូវជាប់គុក ឯអ្នកសម្លាប់បានច្រើនត្រូវរួចខ្លួន បើអ៊ីចឹង បើមានរបបនេះកើតឡើងទៀតនេះ វាត្រូវតែប្រឹងសម្លាប់ឲ្យបានច្រើនទើបរួចខ្លួន បើសម្លាប់បានតិចមុខជាត្រូវជាប់គុកដូចតា ឌុច អ៊ីចឹង។

ដូច្នេះ ការយក ឌុច មកកាត់សេចក្តីតែម្នាក់ឯងជាការបំពានទៅលើគោលបំណងទីពីររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផង និងជាការបំពានទៅលើមាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រម្ពុជាផង។

អ៊ីចឹង សូមតុលាការមេត្តាពិចារណា ថ្លឹងថ្លែងដូចតទៅ៖

ទីមួយ បើ ឌុច ជាមេគុកស-២១ វាទៅជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ អ៊ីចឹងនែ៎ មេគុកទាំង១៩៥ គឺសុទ្ធតែជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិដូចគ្នាទាំងអស់ ត្រូវតែចាប់យកមកកាត់សេចក្ដីទាំងអស់គ្នានោះទើបយុត្តិធម៌ដែលអាចទទួលយកបាន។

ទីពីរ ផ្ទុយទៅវិញបើមេគុក១៩៥ទៀត មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទេ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅច្បាប់ជាតិ និងអន្តរជាតិទេ អ៊ីចឹងមេគុកស-២១ ក៏មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅច្បាប់ជាតិ និងអន្តរជាតិដែរ។ ដូច្នេះ ត្រូវតែលើកលែងចោទប្រកាន់ ឌុច ដូចមេគុកទាំង១៩៥ ទៀត នោះទើបយុត្តិធម៌។

[១៥:២៦:៤៣]

ខ្ញុំសូមអនុញ្ញាតបញ្ជាក់ឡើងវិញថា មេគុកទាំង១៩៦នាក់ គ្មានមេគុកណាម្នាក់មានសិទ្ធិចាប់មនុស្សណាមកដាក់គុក សួរចម្លើយ ធ្វើទារុណកម្ម រួចសម្លាប់នោះទេ គឺសុទ្ធតែទទួលបញ្ជាពីមនុស្សបួនក្រុម ដូចបានជម្រាបជូនខាងលើដូចៗគ្នា។ ទទួលពីបញ្ជាពីអាបួនក្រុមហ្នឹងដូចគ្នា គុកទាំងអស់ហ្នឹង។ ចុះហេតុអ្វីក៏មកទទួលថ្នបាក់តែម្នាក់ឯង? ចុះហេតុអីបានជា ឌុច ហ្នឹងមកទទួលថ្នបាក់តែម្នាក់ឯង។ អ៊ីចឹងសូមតុលាការពិចារណាមើល លើកលែងចោទប្រកាន់ ឌុច ឬចាប់មេគុក១៩៥ ទៀតមកកាត់សេចក្ដី។

មេធាវីការពារក្ដីយល់ឃើញផងដែរថា ច្បាប់បង្កើតឱ្យមាន អ.វ.ត.ក ជាច្បាប់ពិសេសដែលបានកំណត់ច្បាស់ គឺយកតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតមកកាត់សេចក្ដី។ រីឯអ្នកមិនមែនស្ថិតក្នុងជំពូកទាំងពីរនេះទេ ត្រូវតែបានរួចខ្លួន ទោះអ្នកនោះបានសម្លាប់មនុស្សប៉ុន្មានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រោះច្បាប់កាត់ទោសខ្មែរក្រហមនេះ វាជាច្បាប់ពិសេស តើច្បាប់ហ្នឹងវាពិសេសកន្លែងណា? ច្បាប់ពិសេសហ្នឹងត្រង់ថា វាផ្ទុយពីស្មារតីរដ្ឋធម្មនុញ្ញ១៩៩៣, ៩៨ ហ្នឹងត្រង់មាត្រា៣៨ ដែលបានចែងថា “អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់” តែការពិត អ្នកដែដល់ អ្នករួមប្រព្រឹត្ត អ្នកសមគំនិត អត់ត្រូវបានទទួលទោសទេ គឺត្រូវឱ្យ

ច្បាប់ផ្តន្ទាទោសឲ្យទទួលទោសតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ ជាក់ស្តែងនៅស-២១ តា ឌុច គាត់អត់ដែលបានសម្លាប់អ្នកណាដោយផ្ទាល់ដៃទេ ក៏ប៉ុន្តែកូនចៅគាត់អ្នកសម្លាប់ ដូចជាមាន តយ តេង នៅប្រចាំនៅជើងឯក។ ប្រធានក្រុមជាអ្នកសម្លាប់ហ្នឹង គេមានយកមកកាត់ទោសឯណា អត់យកមកកាត់ទោសទេ ហ្នឹងអ្នកដៃដល់ហើយ។ វាពិសេសអ៊ីចឹង គេផ្តន្ទាទោសតែអាមេធំនោះទេ អាល្អិតល្អោច អង្កាច់អង្កោច កម្មេចកម្ទី ល្អិលល្អក់ អាចក់អាចែម របស់គេ ច្បាប់ហ្នឹងមិនតម្រូវឲ្យយកមកកាត់ទោសទេ។

[១៥:២៩:០០]

ប្រសិនបើសហព្រះរាជអាជ្ញាកំណត់ថា ឌុច ជាអ្នកស្ថិតក្នុងជំពូកណាមួយក្នុងចំណោមអ្នកទទួលខុសត្រូវទាំងពីរជំពូកខាងលើ សូមសហព្រះរាជអាជ្ញាជម្រាបតុលាការ ក៏ដូចជាអង្គសវនាការ ក៏ដូចជាអង្គសវនាការទាំងមូលឲ្យបានច្បាស់លាស់។ ពិសេស តើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនោះកំណត់ពីត្រឹមតួនាទី ឬក៏ពីត្រឹមថ្នាក់ណាឡើងទៅ? ហើយអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មតើកំណត់ពីត្រឹមតួនាទី ឬត្រឹមថ្នាក់ណាឡើងទៅ? បើសហព្រះរាជអាជ្ញា មិនបានកំណត់ឲ្យបានច្បាស់លាស់ អំពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋ-កម្មទេនោះ នាំឲ្យកូនក្តីខ្ញុំបានជាជនជាប់ចោទមិនអស់ចិត្ត ហើយអ្នកដែលបានធ្លាប់បានធ្វើជាខ្មែរក្រហមអ្នកដែលធ្លាប់មានតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយកំពុងរស់នៅសព្វថ្ងៃ ក៏មានការច្បាស់លាស់ក្នុងចិត្ត ព្រោះឮថាៗ ចង់ចាប់អ្នកនេះថែមទៀត ចង់ចាប់អ្នកនោះថែមទៀត អ៊ីចឹងទេនាំឲ្យគេមានអារម្មណ៍មិនល្អ។ អ៊ីចឹងយើងត្រូវបញ្ជាក់ឲ្យច្បាស់ អ្នកណាខ្លះ បញ្ជាក់ឲ្យច្បាស់។

ស-២១ គ្មានសិទ្ធិដើរចាប់មនុស្សយកមកចូលស-២១ ទេ។ គុកស-២១ គឺមជ្ឈិមបក្សជាអ្នកសម្រេចឲ្យចាប់។ តែបក្សសម្រេចឲ្យចាប់ហើយ គឺមិនឲ្យរួចខ្លួនទេ ត្រូវតែចាប់យកមកសួរចម្លើយ រួចកម្ទេច ទោះបីចាប់ច្រឡំក៏ដោយ ក៏ត្រូវកម្ទេចដែរ។ ដូចអង្គការពេលនោះបានលើកពាក្យថា “សូវសម្លាប់ច្រឡំ កុំឲ្យតែលែងច្រឡំ។ ទុកក៏មិនចំណេញ ដកចេញក៏មិនខាត”។ ដូច្នេះ មនុស្សដែលបក្ស ឬអង្គការចាប់បញ្ជូនមកស-២១ គឺបក្ស គឺអង្គការបានសម្រេចរួចហើយ ថាត្រូវតែសម្លាប់។

ដូច្នេះយើងឃើញច្បាស់ថា ស-២១ គ្មានសិទ្ធិដើរចាប់ ហើយក៏គ្មានសិទ្ធិដោះលែងដែរ។ ស-២១ សម្លាប់រួចហើយ ត្រូវតែថត រួចបញ្ជូនរូបថតឲ្យទៅឲ្យ ប៉ុល ពត ឃើញច្បាស់ ទើប ប៉ុល ពត ជឿថាបានកម្ទេចរួចហើយមែន ព្រោះ ប៉ុល ពត មិនចេះតែជឿផ្តាស់នោះទេ។

[១៥:៣២:៣៤]

ដូច្នេះ ស-២១ អនុវត្តបានបញ្ជារបស់អង្គការ ដោយអង្គការ ដោយបក្សជាអ្នកទទួលខុសត្រូវ បើអនុវត្តមិនបានជូនអង្គការ ត្រូវអង្គការកំណត់ថាជាខ្មាំង ដើម្បីកុំឲ្យអង្គការថាជាខ្មាំង ត្រូវខិតខំអនុវត្តឲ្យបានជូនអង្គការ ដើម្បីមានជីវិតរបស់នៅបន្តទៅទៀត។ ជាការពិតហើយ នៅក្នុងគុកស-២១ មានការកាប់សម្លាប់មែន តែអ្នកដៃដល់ អ្នកកាប់សម្លាប់ គឺផ្នែកយាមកាម ដែលទទួលភារកិច្ចយាមកាម ការពារ និងកម្ទេច។ ផ្នែកនេះឈ្មោះ ឃឹម វ៉ាក ហៅ ហ៊ី ជាសមាជិកស-២១ ដែលជាប្រធានផ្នែកនេះ។

ដូច្នេះ ឌុច ពុំដែលបានសម្លាប់ ពុំដែលកម្ទេចអ្នកទោសណាម្នាក់ ដោយផ្ទាល់ដៃនោះទេ។

ជនដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនៅស-២១ ក៏ដូចជាគុកនៅទូលទាំងប្រទេស គឺអ្នកសម្រេចឲ្យចាប់យកមកកម្ទេច គឺអ្នកបញ្ជាឲ្យចាប់យកមកកម្ទេច។ តើអ្នកណាជាអ្នកសម្រេចឲ្យចាប់យកមកកម្ទេច? តើអ្នកណាជាអ្នកបញ្ជាឲ្យចាប់យកមកកម្ទេច? អ្នកបញ្ជា ឬអ្នកសម្រេចឲ្យចាប់យកមកកម្ទេច គឺគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមាន ប៉ុល ពត ជាលេខា ពុំមែនកូនក្តីយើងខ្ញុំនេះទេ។ ដូច្នេះ ឌុច ពុំបានប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬក៏ឧក្រិដ្ឋកម្មសង្គ្រាមដូចការចោទប្រកាន់នោះទេ។

[១៥:៣៤:៣០]

ច្បាប់កាត់ទោសខ្មែរក្រហម គេឲ្យយកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម មកធ្វើការកាត់សេចក្តី។ គេមិនឲ្យយកថ្នាក់ក្រោម ថ្នាក់មធ្យមមកធ្វើការកាត់សេចក្តីនោះទេ ព្រោះថ្នាក់មធ្យម និងថ្នាក់ក្រោម វាអនុវត្តតាមថ្នាក់លើ បើថ្នាក់លើបញ្ជាហើយ ថ្នាក់ក្រោមត្រូវតែធ្វើតាម បើមិនធ្វើតាម វាកំបុតក។ នៅក្នុងសម័យ ប៉ុល ពត លោករស់នៅក្នុងសម័យ ប៉ុល ពត លោកដឹង។ អ៊ីចឹងអ្នកសម្លាប់អ្នកទោស ឬក៏សម្លាប់ជនរងគ្រោះនៅស-២១ ក៏ដូចជាសម្លាប់ប្រជាជនទូទាំងប្រទេសកម្ពុជាអស់រាប់លាននាក់នោះ គឺបក្សកុម្មុយនីស្តកម្ពុជា ដែលដឹកនាំដោយ ប៉ុល ពត ពុំមែន ឌុច កូនក្តីយើងខ្ញុំនេះទេ។

ដូច្នេះ ចាប់ ឌុច កូនក្តីយើងខ្ញុំមកកាត់សេចក្តី គឺជាការភាន់ច្រឡំ ត្រូវចាប់មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលមានមេខ្លោង មេធំ គឺ ប៉ុល ពត មកផ្តន្ទាទោសទើបត្រឹមត្រូវ។ ប៉ុន្តែ គួរឲ្យសោកស្តាយ ទុកឲ្យទាល់តែ អ៊ុង ជឿន ហៅ ម៉ុក នេះចាប់ ប៉ុល ពត យកទៅ

ដាក់ក្នុងគុក វាទាល់ងាប់ បាននាំគ្នាផ្ដើលកាត់ទោស ប៉ុល ពត។

ម្យ៉ាងទៀត បើតាមតម្រាយប្រវត្តិសាស្ត្រ យើងឃើញថា ការជំនុំជម្រះពួកអ៊ីត្លែរ ការទាមទារជំនុំជម្រះក្ដីប្រធានាធិបតី ពីណូចេ នៃប្រទេសឈីលី ការជំនុំជម្រះក្ដីទៅលើប្រធានាធិបតី ស្លូបូដាន មីឡូសីវិច គឺសុទ្ធតែជាកំពូលអ្នកទទួលខុសត្រូវពិតប្រាកដ។ ឥឡូវនេះ តុលាការរកឃើញជាក់ស្ដែងហើយតើ មេដឹកនាំធំបំផុត មេខ្លោងដឹកនាំក្រុមកម្ពុជាប្រជាធិបតេយ្យ ឬក្រុមមេខ្មែរក្រហម ដែលជាកំពូលអ្នកទទួលខុសត្រូវ ដែលជាម្ចាស់មាគ៌ាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាម្ចាស់មាគ៌ាឧក្រិដ្ឋកម្មសង្គ្រាម គឺ ប៉ុល ពត។ ដូច្នេះ ត្រូវចាប់តែ ប៉ុល ពត មួយមកកាត់ទោស វាជាការត្រឹមត្រូវបំផុត។

[១៥:៣៧:១៧]

ដោយផ្អែកតាមស្មារតីមាត្រា៩៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ អំពើដែល ឌុច បានធ្វើឡើង អំពើដែលបានប្រព្រឹត្តឡើងនៅស-២១ មិនទុកជាអំពើល្មើសក្នុងក្រមព្រហ្មទណ្ឌទេ ដោយមាត្រា៩៩ នេះ បានចែងយ៉ាងច្បាស់ថា មិនទុកជាអំពើល្មើសក្នុងបទព្រហ្មទណ្ឌទេ កាលណាបើអំពើទាំងឡាយនោះ ធ្វើតាមបង្គាប់របស់ច្បាប់ ហើយអ្នកបញ្ជាឲ្យធ្វើ ក៏ជាអាជ្ញាធរធម្មានុរូប។ តើអំពើទាំងឡាយនៅស-២១ ធ្វើតាមបង្គាប់ច្បាប់នោះយ៉ាងណា?

ច្បាប់របស់ ប៉ុល ពត កាលណាមនុស្សបញ្ជូនមកស-២១ គឺបក្ស គឺអង្គការបានកំណត់ច្បាស់ថា ជាអ្នកទោស ជាខ្មាំងត្រូវតែសម្លាប់ សូវសម្លាប់ច្រឡំ កុំឲ្យលែងច្រឡំ។ នេះជាច្បាប់របស់បក្ស ជាច្បាប់របស់អង្គការពេលនោះ ព្រោះពេលនោះបក្ស ព្រោះពេលនោះអង្គការជាតុលាការ សម្ដីរបស់បក្ស សម្ដីរបស់អង្គការស្មើសាលក្រមតុលាការបច្ចុប្បន្ននេះ។ គ្មាននរណាហ៊ានប្រឆាំងទេ បក្សឲ្យធ្វើអី ធ្វើហ្នឹង អង្គការឲ្យធ្វើអី ធ្វើហ្នឹង ទើបតែមកយើងក្រោយ ប៉ុល ពត ឥឡូវនេះទេ ដែលយើងអួតថាម៉េចមិនក៏ចេះថាម៉េចក៏មិនចុះ ក៏ប៉ុន្តែបើនៅក្នុងសម័យនុ៎ងដូចគ្នា សាកលមើល៍ ខ្ញុំឲ្យសាកលមើល៍ ហ៊ានទេ?

អ៊ីចឹងអ្ហែ! សម្ដីរបស់អង្គការ សម្ដីរបស់បក្សពេលនោះ ស្មើសាលក្រមតុលាការបច្ចុប្បន្ននេះ។ អង្គការឲ្យសម្លាប់ត្រូវតែសម្លាប់ បើមិនសម្លាប់ អង្គការចាត់ទុកថា ខ្មាំង បើខ្មាំងត្រូវតែកម្ទេចចោល ។

ជាក់ស្ដែងខ្ញុំលើកឧទាហរណ៍ ពេលដេញដោលនៅសម័យសវនាការបានលើកហើយថា ឃើញឪពុកម្ដាយមក កូនដែលជាអង្គការបដិវត្តន៍របស់គេនោះថា អ៊ូ! ថ្ងៃនេះ កូនសប្បាយរីករាយណាស់ អបអរណាស់ បានឃើញពុកនិងម៉ែមក តែថ្ងៃនេះ កូនសូមសម្លាប់ខ្មាំង។ អាហ្នឹងហ៎ា តើអ្នកបញ្ជាឲ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូបនោះយ៉ាងណា? អ្នកបញ្ជាស-២១ គឺ សុន សេន នៅពីលើ សុន សេន មាន នួន ជា

នៅពីលើ នួន ជា មាន ប៉ុល ពត នៅពីលើ ប៉ុល ពត។ល។

អ៊ីចឹង សុន សេន, នួន ជា, ប៉ុល ពត សុទ្ធតែជាអាជ្ញាធរធម្មានុរូប។ អាជ្ញាធរស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ ព្រោះកម្ពុជាប្រជាធិបតេយ្យពេលនោះជារដ្ឋស្របច្បាប់ដែលអង្គការសហប្រជាជាតិទទួលស្គាល់។ ៧៥(?) រហូតដល់៨៩នោះ ប៉ុល ពត អង្គុយនៅកៅអីអង្គការសហប្រជាជាតិទៀត។ អង្គការសហប្រជាជាតិទទួលស្គាល់ ប៉ុល ពត កម្ពុជាប្រជាធិបតេយ្យជារដ្ឋស្របច្បាប់។ អ៊ីចឹងហើយអាជ្ញាធរធម្មានុរូបបញ្ជាហើយ រឿងអី តាឌុច មកខុស។

ដូច្នេះ យើងឃើញថា សម័យនោះកម្ពុជាប្រជាធិបតេយ្យជារដ្ឋស្របច្បាប់ ព្រមទាំងមានមហាអំណាចជាច្រើនទទួលស្គាល់។ ចិនក៏ទទួលស្គាល់ ខាងបារាំងនោះក៏ទទួលស្គាល់ ប៉ុល ពត ដែរ។ ឲ្យ ប៉ុល ពត អង្គុយនៅកៅអីអង្គការសហប្រជាជាតិ។ បាតដៃជើងសុទ្ធតែឈាមហ្នឹងទៅអង្គុយពេញកៅអីសហប្រជាជាតិនោះ។ ដូច្នេះ ឌុច ធ្វើតាមបង្គាប់របស់ច្បាប់ពេលនោះ ធ្វើតាមបញ្ជារបស់អាជ្ញាធរធម្មានុរូបនៅពេលនោះមិនចាត់ទុកជាអំពើល្មើសព្រហ្មទណ្ឌទេ។

[១៥:៤១:៤0]

យើងខ្ញុំជាមេធាវីទទួលស្គាល់ថា បទល្មើសព្រហ្មទណ្ឌនៅស-២១ ក៏ដូចជាគុកនៅទូទាំងប្រទេសវាមានកើតប្រាកដមែន។ ដំរីងាប់យកចង្អេរទៅបាំងក៏វាមិនជិត។ ដូចជនជាប់ចោទធ្លាប់បានលើកជម្រាបជូនតុលាការសម្រាប់ហើយ ថាយកស្លឹកអំពិលពីរសន្លឹកទៅបាំងឯណាជិត ប៉ុន្តែសំខាន់ណោះ តើអ្នកណាជាអ្នកទទួលទោសទាំងនោះ? បើតាមចាស់ពីជំនាន់ដើម គេឲ្យអ្នកណាដែលមានអំណាចបញ្ជាជាអ្នកទទួលទោស។ តាមគំនិតនេះហើយបានជាស្មារតីនៃមាត្រា២៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា២៣៨នោះ បានបញ្ជាក់ច្បាស់ថា បើពិរុទ្ធជននោះវាប្រតិបត្តិតាមបង្គាប់របស់ចៅហ្វាយនាយដែលខ្លួនត្រូវតែស្តាប់ៗ។ រួច តាឌុច ហ្នឹងគាត់ត្រូវតែស្តាប់ហើយ សុន សេន មេគាត់ នួន ជា មេគាត់ ប៉ុល ពត មេធំ អ៊ីចឹងគាត់ត្រូវស្តាប់។

បើមានករណីយ៉ាងនេះ ទោសអាចធ្លាក់តែទៅលើចៅហ្វាយនាយ ដែលជាអ្នកទទួលខុសត្រូវក្នុងការចាត់បង្គាប់នេះដាច់ដោយឡែកតែម្នាក់ឯង។ មាត្រា២៣៣ គេអត់ឲ្យអ្នកដែលធ្វើតាមចៅហ្វាយហ្នឹងទៅទទួលទោសទេ ចៅហ្វាយបញ្ជាត្រូវតែចៅហ្វាយហ្នឹងទទួលខុសត្រូវ។ អាហ្នឹងទៅប្រទេសណាក៏អ៊ីចឹងនៅប្រទេសណាក៏អ៊ីចឹងដែរ ខ្ញុំឃើញនៅសហរដ្ឋអាមេរិក ក៏មានអ៊ីចឹងដែរ ពេលភ្លើងឆេះផ្ទះនោះមិនដឹងពីឆ្នាំណា ខ្ញុំមិនចាំទេ គេយកអាហ្នឹងទៅបាញ់ចោលនោះ។ អ៊ីចឹងអាអ្នកបាញ់ អាអ្នកដែលធ្វើឲ្យ

ភ្លើងឆេះផ្ទះនោះ វាមានទោសអីវា ពីព្រោះវាធ្វើតាមបញ្ជារបស់ចៅហ្វាយ តាមអ្នកដែលបញ្ជា ហើយវាធ្វើតាមបង្គាប់របស់ច្បាប់។

នៅសម័យសង្គមរាស្ត្រនិយមយក ព្រាប អ៊ិន យកទៅបាញ់ចោល។ សម័យ លន់ នល់ បាញ់ មាក់ ធុរ៉ា ចៅបូរី ចោល។ អាអ្នកបាញ់ មាក់ ធុរ៉ា អាអ្នកបាញ់ ព្រាប អ៊ិន គេអត់មានទោសទេ ពីព្រោះច្បាប់វាបញ្ជាឲ្យធ្វើ ពីព្រោះអាជ្ញាធរពេលនោះ វាធម្មានុរូប។ អ៊ីចឹងអ្នកដែលធ្វើតាមបញ្ជា មាត្រា២៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនឲ្យអ្នកដែលប្រព្រឹត្តតាមចៅហ្វាយហ្នឹងមានទោសទេ។ ដូច្នេះ កូនក្ដីខ្ញុំត្រូវតែបានរួចខ្លួន។

[១៥:៤៤:៣៤]

យើងខ្ញុំជាមេធាវី ពិនិត្យឃើញទៀតថា ឌុច ត្រូវតែទទួលរួចផុតពីបទចោទ ព្រោះថាបើ ឌុច មិនអនុវត្តតាម មិនធ្វើតាមបង្គាប់ជានីត្យានុកូលរបស់អាជ្ញាធរជាធម្មានុរូបនោះ ឌុច ក៏ត្រូវមានទោសមជ្ឈិមថ្នាក់ទីបី តាមមាត្រា២៣៦នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ បើគេបញ្ជាឲ្យគាត់ធ្វើ គាត់មិនធ្វើ ក៏គាត់ត្រូវមានទោសដែរ តាមមាត្រា២៣៦។ ពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើ ឌុច មិនធ្វើតាមបញ្ជាទេ ក៏ ឌុច មិនអាចរស់រានមានជីវិតរហូតសព្វថ្ងៃនេះដែរ មិនធ្វើតាមបញ្ជាហ្នឹងកំបុតកបាត់យូរហើយ។

មានតែក្នុងករណីដែលអង្គជំនុំជម្រះបានរកឃើញថា ឌុច បានអនុវត្តលើសពីការបង្គាប់បញ្ជាដោយរំលោភអំណាច។ ឧទាហរណ៍ដូចថា មនុស្សដែលអង្គការមិនឲ្យចាប់ តែ ឌុច បែជាចាប់យកមកសម្លាប់ វាប្រព្រឹត្តលើសអំណាចអ៊ីចឹង នោះទើបត្រូវផ្ដន្ទាទោសតាមមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ មានតែក្នុងករណីហ្នឹងទេ ដែលតុលាការរកឃើញថា ឌុច នេះ អង្គការបក្សអត់បានបញ្ជាធ្វើឲ្យទៅសម្លាប់អ្នកណាទេ ហើយគាត់ទៅសម្លាប់ មានតែក្នុងករណីហ្នឹងទេ ដែលគាត់ធ្វើលើសបញ្ជាអាហ្នឹងផ្ដន្ទាទោសគាត់បាន។

ម្យ៉ាងទៀត បើយោងតាមមាត្រា៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ បានចែងយ៉ាងច្បាស់ថា ច្បាប់នេះ អនុគ្រោះទុកពេលប្រាំមួយខែ ក្រោយពីការចូលជាធរមាន។ ឲ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យវិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ៗចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ បញ្ជាក់ច្បាស់អ៊ីចឹង។ អ៊ីចឹងជនជាសមាជិកអង្គការនយោបាយ

ឬជាកងកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យ។ ដែលបានវិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលមុនថ្ងៃទី៧ ខែមករា ១៩៩៥ គឺច្បាប់នេះពុំយកទោសពៃរ៍ៗ ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តកន្លងមក។ អ៊ីចឹង បើយោងទៅតាមច្បាប់នៃការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឃើញថាកូនក្តីខ្ញុំត្រូវបានរួចខ្លួនដោយពិតប្រាកដ។ ឯកូនក្តីរបស់យើងខ្ញុំបានចូលមករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលតាំងពីមុនច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ចំនួន ពីរឆ្នាំ ប្រាំមួយខែ។ ច្បាប់មិនទាន់ចេញ គាត់មកមុនហ្នឹងពីរខែ ពីរឆ្នាំប្រាំមួយខែ។

[១៥:៤៨:០៥]

ដូច្នេះ ឌុច ទោះបីកន្លងមានទោសពៃរ៍បានប្រព្រឹត្តល្មើសអ្វីក៏ដោយ ក៏ត្រូវបានរួចខ្លួន ព្រោះមាត្រា ៥ នៃច្បាប់នេះបានកំណត់យ៉ាងច្បាស់ថា មិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តកន្លងមក។ ដូចតុលាការបានជ្រាបស្រាប់ហើយថា ក្នុងគោលការណ៍ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិប-តេយ្យឲ្យនៅក្រៅច្បាប់ ចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមានគឺចាប់ពីថ្ងៃ ចាប់ពីឆ្នាំ១៩៩៥មក។ បើជនទាំងឡាយណាដែលជាសមាជិកអង្គការនយោបាយ ជាកម្លាំងយោធារបស់ក្រុមកម្ពុជាប្រជាធិបតេយ្យដែលមិនចូលមករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ហើយនៅតែបន្តការកាប់សម្លាប់យ៉ាងព្រៃផ្សៃតទៅទៀត ទើបចាត់ទុកជននោះថាជាជនល្មើសនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

[១៥:៤៩:១២]

ច្បាប់ហ្នឹងចេញហើយ បើខ្លួនមិនមក ឬខ្លួនចូលហើយនៅតែកាប់សម្លាប់តទៅទៀត អាហ្នឹងបានល្មើសច្បាប់ អាហ្នឹងបានត្រូវយកមកកាត់ទោស។ ជាក់ស្តែងកន្លងមក ដូចតុលាការបានជ្រាបហើយ ឆ្នាំ ១៩៩៧ ប៉ុល ពត ចាប់ សុន សេន, យន់ យ៉ាត ប្រពន្ធ សុន សេន និងគ្រួសារទាំងអស់១១នាក់ បាញ់ចោលទាំងអស់ឆ្នាំ១៩៩៧ ហើយនេះ ហើយយកទៅដាក់នៅលើថ្នល់ឲ្យរថក្រោះកិនចុះកិនឡើងឲ្យទាល់តែខ្ទេចមើលលែងឃើញ។ ន៎ែ! ព្រៃផ្សៃអ៊ីចឹងអាហ្នឹងបានយកមកផ្តន្ទាទោស។ ក៏ប៉ុន្តែកាល ប៉ុល ពត នៅណោះមានអ្នកណាប៉ាន, ៩៧ហ្នឹង។ ពេលនោះ តាម៉ុក នៅឆ្នាំ៩៧ ហ្នឹង ដើមឆ្នាំ៩៨ តាម៉ុក ឃើញអ៊ីចឹង សម្លាប់ សុន សេន។ តាម៉ុក ធ្វើមីទិ្ទងមួយចាប់ ប៉ុល ពត យកមកធ្វើមីទ្ទីងដាក់គុក ដាក់ក្នុងផ្ទះតូចមួយ ដំបូលទាប ឲ្យក្តៅ ធ្វើឲ្យលក្ខខណ្ឌមួយឲ្យ ប៉ុល ពត ឆាប់ស្លាប់ ហើយ តាម៉ុក ធ្វើអ៊ីចឹងដាក់ ចាប់ ប៉ុល ពត មក។ តាម៉ុក ចាប់មេទ័ពបីនាក់។ មេទ័ពសំខាន់របស់ ប៉ុល ពត ហ្នឹង ទាំងប្រពន្ធ ទាំងកូនយកទៅបាញ់ចោលបាត់ អត់មានអ្នកណាធ្វើអី តាម៉ុក ទៀត។ នេះយើងឃើញថាជនល្មើស និងច្បាប់ព្រះ

រាជាណាចក្រកម្ពុជា ដូច ប៉ុល ពត ដូច តាម៉ុក អ៊ីចឹង អាហ្នឹងដែលត្រូវថាវាមិនគោរពច្បាប់ គេត្រូវចាប់យកមកទៀត។

ដូច្នេះ ឌុច គ្មានទោសពៃរ៍អ្វីទាំងអស់ ត្រូវតែបានរួចខ្លួនពីការចោទប្រកាន់ព្រោះក្រោយឆ្នាំ១៩៩៥ មក ឌុច ពុំបានល្មើសនឹងច្បាប់នេះទេ។ម្យ៉ាងទៀត តាមមាត្រា៦ នៃច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិប-តេយ្យឲ្យនៅក្រៅច្បាប់បានចែងថា ចំពោះមេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យមិនអាចមានការអនុ-គ្រោះដូចមានចែងក្នុងច្បាប់នេះឡើយ។ អ៊ីចឹងច្បាប់នេះ តែមេដឹកនាំទេ នៃក្រុមកម្ពុជាប្រជាធិបតេយ្យដែលគេមិនអនុគ្រោះ។ អ៊ីចឹង ច្បាប់នេះគេអនុគ្រោះចំពោះខ្មែរក្រហមទាំងអស់ លើកលែងតែមេដឹកនាំខ្មែរក្រហមប៉ុណ្ណោះដែលគេមិនអនុគ្រោះ។

ឯ ឌុច តុលាការបានជ្រាបស្រាប់ហើយ ជាមេគុកម្នាក់ក្នុងចំណោមមេគុកទាំង១៩៦ គឺមិនមែនជាមេដឹកនាំខ្មែរក្រហមនៃក្រុមកម្ពុជាប្រជាធិបតេយ្យនោះទេ។ ដូច្នេះ ឌុច ត្រូវតែបានរួចខ្លួន និងបើតាមច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់។

ម្យ៉ាងទៀត បើពិនិត្យទៅលើសេចក្តីអំពាវនាវរបស់រាជរដ្ឋាភិបាល ដែលកាលនោះចុះហត្ថលេខាដោយសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទីមួយ និងសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទីពីរ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានអំពាវនាវឲ្យប្រជាជនរហូតដល់នាយទាហាន ពលទាហានដែលកំពុងរស់នៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម ចូលប្រញាប់ប្រញាល់រិះរកគ្រប់វិធីវិលមករួមរស់ក្នុងសង្គមជាតិវិញ រាជរដ្ឋាភិបាលមិនគ្រាន់តែមិនយកទោសពៃរ៍ប៉ុណ្ណោះទេ គឺថែមទាំងរក្សាទុកនូវឋានន្តរសក្តិឲ្យថែមទៀតផង។

[១៥:៥៣:០៤]

ជាក់ស្តែងបច្ចុប្បន្ននេះ នៅក្រសួងការពារជាតិមានទ័ពមួយចំនួនជាអតីតទ័ពរបស់ក្រុមកម្ពុជាប្រជាធិបតេយ្យ។ ដោយឡែកគួរអនិច្ចាដល់ ឌុច ដែលបានចូលមករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលតាំងពីមុនច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់។ តាំងពីមុនសេចក្តីអំពាវនាវនេះជាងពីរឆ្នាំ បែជាមានទោសទៅវិញ។ នេះជាការបញ្ជាក់យ៉ាងច្បាស់ថា ឌុច មិនមែនជាជនរឹងរូសទេ មិនមែនជាជនល្មើសនឹងច្បាប់នោះទេ ព្រោះ ឌុច បានចូលមករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋា-ភិបាលតាំងពីមិនទាន់មានច្បាប់នេះ តាំងពីមិនទាន់មានសេចក្តីអំពាវនាវនេះ។

ជាគោលការណ៍របស់ច្បាប់ព្រហ្មទណ្ឌ អ្នកមានទោសលុះត្រាតែអ្នកនោះប្រព្រឹត្តអំពើប្រឆាំងនឹង

ច្បាប់ តែច្បាប់មិនទាន់កើតផង ឌុច មកមុនច្បាប់នេះទៅហើយ អំពើនេះមិនចាត់ទុកជាបទល្មើសថាត្រូវផ្តន្ទានោះទេ។ បើវាគ្មានទោស វាត្រូវតែបានរួចខ្លួន។

សូមឲ្យតុលាការពិចារណាផងដែរ អំពីខ្លឹមសារនៃកិច្ចព្រមព្រៀងនៅទីក្រុងបារីស ចុះថ្ងៃទី២៣ តុលា ១៩៩១ ស្តីពីបញ្ហាកម្ពុជា មាត្រា២១ ត្រង់មាត្រា២១ នៃកិច្ចព្រមព្រៀងដែលបានគូសបញ្ជាក់ថា "ការដោះលែងឈ្លើយសឹក និងជនស៊ីវិលជាប់ឃុំឃាំងទាំងអស់ត្រូវសម្រេចឡើងក្នុងរយៈពេលដ៏ឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន"។

ឃើញថា មុនពេល ពីមុនមកមានទ័ពគ្រប់ភាគីជម្លោះ និងជនស៊ីវិល ដែលបានជាប់ឃុំឃាំង គឺនៅពេល អ៊ុនតាក់ចូលមក បានដោះលែងអស់គ្មានសល់។ ពីព្រោះគ្រប់ភាគីជម្លោះត្រូវទៅអង្គុយតុចរចានៅហ្សាកាតាក្តី នៅប៉ារីសក្តី នៅប៉ាតាយ៉ាក្តី នៅប៉េកាំងក្តី នៅញូវយ៉កក្តី គឺស្មើភាពគ្នាចំពោះមុខច្បាប់។ ដោយបំភ្លេចចោលទាំងអស់នូវរឿងរ៉ាវពីអតីត។ ក្នុងគំនិតនេះហើយបានជានៅជាក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងបានបញ្ជាក់ច្បាស់ថា រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តច្បាប់ឧក្រិដ្ឋកម្មទៅលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល។

[១៥:៥៦:០១]

ជារួមនៅឆ្នាំ១៩៩១ សន្និសញ្ញាទីក្រុងប៉ារីស បានបង្កើតអ៊ុនតាក់នៅឆ្នាំ១៩៩៣ ដោយបានលើកលែងទោសទាំងអស់ ហើយមានការទទួលស្គាល់ខ្មែរក្រហមជាភាគីមួយឲ្យចូលរួមបោះឆ្នោត។ បានសេចក្តីថា គេលើកលែងទោសអស់ហើយ គ្មាននៅសល់ទោសអ្វីទៀតទេ ព្រោះមនុស្សមានទោស គេមិនឲ្យបោះឆ្នោត ហើយក៏មិនឲ្យឈរឈ្មោះដើម្បីឲ្យបោះឆ្នោតឲ្យដែរ។ គ្រាន់តែខ្មែរក្រហមធ្វើពហិការប៉ុណ្ណោះទេ។

ដូច្នេះ ឌុច ជាខ្មែរក្រហមតូចតាច មិនមែនជាមេខ្មែរក្រហម មិនមែនជាមេក្រុមដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះទេ។ មិនអាចនៅសល់ទោសពៃរ៍អ្វីទៀតទេ ត្រូវតែបានរួចខ្លួនផុតពីបទចោទ។

អាស្រ័យហេតុនេះ មេធាវីការពារ សូមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយកនូវសារណារបស់មេធាវីការពារក្តីស្តីពីអញ្ញត្រកម្ម និងប្រកាសពីការផុតរលត់នៃបណ្តឹងអាជ្ញាសម្រាប់អំពើឃាតកម្ម និងទារុណកម្ម ដូចមានចែងក្នុងមាត្រា៥០០ មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឬប្រកាសមិនទទួលយកបណ្តឹងចោទប្រកាន់ពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិរបស់សហព្រះរាជអាជ្ញា។

ទីពីរ ប្រកាសនិងសម្រេចថា សូមឲ្យអង្គជំនុំជម្រះមេត្តាប្រកាសនិងសម្រេចថា ជម្លោះ-- ចំពោះ

ជម្លោះប្រដាប់អាវុធ ដែលបង្កឲ្យមានឧក្រិដ្ឋកម្មសង្គ្រាម ដែលរំលោភលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ១៩៤៩ គឺជារឿងរបស់កម្ពុជាប្រជាធិបតេយ្យ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និង បក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាលវៀតណាម ដែលជាអ្នកបង្កជម្លោះប្រដាប់អាវុធនេះឡើង មិនមែនលើក កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអ្នកបង្កើតជម្លោះនេះទេ។

សូមឲ្យតុលាការប្រកាសនិងសម្រេចថា លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដូចការចោទប្រកាន់នោះទេ។

ហេតុនេះ សូមអង្គជំនុំជម្រះ មេត្តាលើកលែងចោទប្រកាន់ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពីបទចោទខាងលើ។

សូមអរគុណ ហើយសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យសហមេធាវីអន្តរជាតិមេត្តាធ្វើសេចក្តីសន្និដ្ឋានបន្ត។ សូមអរគុណ។

[១៥:៥៩:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី សហមេធាវីការពារក្តីអន្តរជាតិ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ដោយពិចារណាទៅលើពេលវេលា ខ្ញុំសូមចាប់ផ្តើមនៅថ្ងៃស្អែកព្រឹក ដើម្បីខ្ញុំមិនចាំបាច់មានការកាត់នៅក្នុងការលើកឡើងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដោយសារពេលវេលាខ្លីនេះ។ ហើយខ្ញុំគិតថា ខ្ញុំមិនចង់ដាក់ជូននូវសេចក្តីសន្និដ្ឋានបិទការដេញដោលដោយផ្ទាល់មាត់នៅពេលនេះទេ។ ខ្ញុំសូមលើកឡើងនៅថ្ងៃស្អែកព្រឹក។

**ប្រធានអង្គជំនុំ៖**

ដោយសារសំណើសុំរបស់មេធាវីការពារក្តីអន្តរជាតិ ជាការសមរម្យមួយ ដោយសារពេលវេលាសវនាការនៅរសៀលនេះនៅតែដប់ប្រាំនាទីប៉ុណ្ណោះ។ ហើយដោយសារនៅក្នុងសេចក្តីថ្លែងគឺទាមទារធ្វើនូវសេចក្តីថ្លែងទៅជាប់គ្នា ចៀសវាងការខកខាន វានាំឲ្យមានបញ្ហាលំបាកនៅក្នុងធ្វើសេចក្តីថ្លែងការណ៍បញ្ចប់កិច្ចពិភាក្សារបស់គាត់។ ហើយសំណើនេះសមរម្យ។ អ៊ីចឹងអង្គជំនុំជម្រះសម្រេចផ្អាកដំណើរការសនាវការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅធ្វើសវនាការនៅថ្ងៃស្អែកចាប់ពីវេលា

ម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង១៦:០១នាទីរសៀល)*